**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សន្តតិកម្មតាមមតកសាសន៍

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **រដ្ឋ ផល្លិ**

កញ្ញា **ទេព ច័ន្ទគ្រីស្នា**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ញឹក ឧុធ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **រដ្ឋ ផល្លិ** និង **ទេព ច័ន្ទត្រីស្នា** ជានិស្សិតត្រូវបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តឆ្នាំទី ៤ ជំនាន់ទី ២៣ នាពេលខាងមុខ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា ២០១៩-២០២៣។

យើងខ្ញុំទាំងពីរសូមសម្តែងនូវការគោរព លំឱនកាយ វាចា និងការដឹងគុណយ៉ាងធំធេងជាទីបំផុតជូនចំពោះអ្នកមានគុណទាំងពីរគឺ **លោកឪពុក និងអ្នកម្តាយ** ដែលលោកទាំងពីរបានផ្តល់កំណើត ព្រមទាំងបានចិញ្ចឹមបីបាច់ថែរក្សារូបកូនចាប់ពីថ្ងៃដែលកូនចាប់កំណើត រហូតមកដល់ពេលដែលកូនពេញវ័យ។ លើសពីនេះលោកទាំងពីរបានអប់រំ ប្រៀនប្រដៅ ផ្តល់ដំបូន្មានល្អៗជាច្រើន រហូតដល់រូបកូនទទួលបាននូវភាពជោគជ័យជាមួយ នឹងលទ្ធផលជាទីគាប់ប្រសើរនៅកម្រិតថ្នាក់ឧត្តមសិក្សា។ ប្រសិនបើគ្មានការជួយជ្រោមជ្រែងរបស់លោកទាំងពីរទេរូបកូនក៏គ្មានថ្ងៃនេះដែរ ពីព្រោះព្រហ្មវិហារធម៌ដែលគ្មានអ្វីប្រៀបប្រដូចបាននូវគុណរបស់លោកឪពុក និងអ្នកម្តាយដ៏គោរពក៏ដូចជាទឹកចិត្តលោកមានចំពោះកូនៗ ដែលមិនអាចយកអ្វីមកប្តូរបាន និងមិនអាចបំភ្លេចបានឡើយ រហូតដល់វិនាទីចុងក្រោយនៃជីវិតរបស់កូន។ សូមលោកទាំងទ្វេរទទួលនូវការគោរព និងការដឹងគុណូបការៈដ៏ធំធេងពីសំណាក់កូនៗ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងអណោកចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ដែលបានជួយជ្រោមជ្រែង បង្ហាត់បង្រៀន ផ្តល់ដំបូន្មានល្អៗ តម្រង់ទិសក្នុងការក្រេបយកនូវរាល់ចំណេះដឹងល្អៗដល់ខ្ញុំទាំងពីរនាក់ពីថ្នាក់មូលដ្ឋាន រហូតដល់បញ្ចាប់ថ្នាក់បរិញ្ញាបត្រនេះបានប្រកបឧត្តមភាព កិត្យានុភាព ចំណេះ ជំនាញ និងវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌ដ៏ខ្ពង់ខ្ពស់។

ជាពិសេសសូមថ្លែងអំណរគុណ លោក **ញឹក ឧុធ្ធី** ដែលជាសាស្ត្រាចារ្យដឹកនាំ បានផ្តល់នូវវិធីសាស្រ្ត ក៏ដូចជាគន្លឹះក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ។ លោកបានចំណាយពេលវេលាដ៏មានតម្លៃនៅក្នុងការជួយជ្រោមជ្រែងតាំងពីពេលចាប់ផ្តើមរហូតដល់ទីបញ្ចប់។ ស្នាដៃមួយនេះបានសម្រេចទៅបានដោយលោកសាស្ត្រាចារ្យដឹកនាំបានផ្តល់ជា បច្ចេកទេស និងកម្លាំងចិត្ត ក្នុងការជំរុញឱ្យការស្រាវជ្រាវនេះមានលក្ខណៈល្អប្រសើរ។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួងលើកដៃប្រណម និងប្រសិទ្ធិពរជ័យដល់លោកអ្នកមានគុណទាំងទ្វេរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់សូមប្រសិទ្ធពរជ័យ សេរីមង្គល បវរមហាប្រសើរ មហាវិបុលសុខសុភមង្គល ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សូមស្វាគមន៍ និងជំរាបសួរទៅដល់មិត្តៗនិស្សិត ប្រិយមិត្តអ្នកស្រាវជ្រាវ និងអ្នកដែលចង់ស្វែងយល់នូវប្រធានបទ ក៏ដូចជាឯកសារជំនួយស្មារតីជាទីរាប់អាន។ បន្ទាប់ពីបានសិក្សាអស់រយៈពេល៤ឆ្នាំកន្លងមកនេះ ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្ត ជំនាន់ទី២៣ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា ២០១៩-២០២៣ ដែលទទួលបានឱកាសពីសំណាក់សាកលវិទ្យាល័យឱ្យជ្រើសរើសប្រធានបទមួយ ដែលស្របទៅនឹងមុខជំនាញរបស់យើងខ្ញុំដើម្បីចងក្រងឡើងក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្តនេះ។ ក្នុងឱកាសដ៏ល្អវិសេសវិសាលដែលសាកលវិទ្យាល័យបានអនុញ្ញាត និងបានលើកទឹកចិត្តនេះ បូករួមទាំងការខិតខំប្រឹងប្រែងអស់រយៈពេលនៃការសិក្សា៤ឆ្នាំកន្លងមកនេះ ដោយយើងខ្ញុំបានសម្រេចជ្រើសរើសនូវប្រធានបទស្តីអំពី សន្តតិកម្មតាមមតកសាសន៍មកធ្វើការរៀបរៀងក៏ដូចជាការចងក្រង និងតាក់តែងនូវស្នាដៃនៃការស្រាវជ្រាវនេះឡើងក្នុងការផ្តល់ជាឯកសារជំនួយស្មារតី ឬការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ។

ហេតុដែលជំរុញឱ្យយើងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទនេះមកធ្វើការរៀបរៀង និងចងក្រងឡើងដោយខ្ញុំធ្លាប់បានសិក្សាមេរៀនពាក់ព័ន្ធទៅនឹងប្រធានបទមួយនេះពីមុនមក និងមើលឃើញពីចំណុចខ្វះខាត ក៏ដូចជាមន្ទិលសង្ស័យ ឬភាពមិនច្បាស់លាស់មួយចំនួន ទើបយើងខ្ញុំមានការចាប់អារម្មណ៍ចង់សិក្សាស្វែងយល់ជាពិសេសសង្ឃឹមថានៅក្រោយពេលបានចងក្រង និងស្រាវជ្រាវទៅលើប្រធានបទនេះហើយ នឹងបានរកឃើញនូវចំណុចដែលត្រូវបំពេញបន្ថែម ក៏ដូចជាចូលរួមចំណែកលើកជាយោបល់ និងសំណូមពរមួយចំនួនពាក់ព័ន្ធទៅនឹងប្រធានបទស្តីពី សន្តតិកម្មតាមមតកសាសន៍នេះ។ លើសពីនេះ យើងខ្ញុំក៏សង្កេតឃើញថាវាជាកម្មវត្ថុ ក៏ដូចជាបញ្ហាចម្បងមួយផ្តោតលើគ្រួសារនៅកម្ពុជា ឬ បុគ្គលគ្រប់រូបដែលមានបំណងធ្វើការបែងចែកមត៌កពីសំណាក់បុគ្គលដែលជាម្ចាស់ទ្រព្យតាមឆន្ទៈផ្ទាល់ មុនពេលដែលម្ចាស់ទ្រព្យបានទទួលមរណភាព។ ម្យ៉ាងវិញទៀតក៏មានបំណងចង់ឱ្យស្ថាប័នដែលមានការពាក់ព័ន្ធគួរតែមានការផ្សព្វផ្សាយផ្តល់ព័ត៌មាន ក៏ដូចជាសិក្ខាសាលា និងចែករំលែកនូវការយល់ដឹងឱ្យកាន់តែទូលំទូលាយដល់ប្រជាជនអំពីការធ្វើបណ្តាំ ក៏ដូចជាសារៈសំខាន់នៃការធ្វើសន្តតិកម្មតាមមតកសាសន៍នេះដែលទទួលស្គាល់ដោយច្បាប់ត្រឹមត្រូវ ចៀសវាងក្រោយពេលដែលម្ចាស់បណ្តាំទទួលមរណភាព បែរជាលិខិតបណ្តាំនោះគ្មានសុពលភាព ដោយខុសនូវទម្រង់ ឬបែបបទ នីតិវិធីណាមួយ។

ជាចុងក្រោយយើងខ្ញុំសូមទទួលយក និងរង់ចាំទទួលយកការរិះគន់ពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ សាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ រាល់កំហុសខុសឆ្គងទាំងឡាយដែលកើត

ឡើងដោយអចេតនាណាមួយក្តី ឬ ពាក្យពេចន៍ ឃ្លា វេយ្យាករណ៍ អក្ខរក្រម ដើម្បីជួយកែលំអរកាន់តែល្អ ក៏ដូចជាខ្លឹមសារផ្សេងៗ និងមានភាពសុក្រឹតភាព។

យើងពិតជាមានសេចក្តីសាមន្សរីករាយ និងមោទនៈភាពចំពោះស្នាដៃមួយនេះ ដោយហេតុថាវាជាការស្រាវជ្រាវថ្មីមួយដែលបានប្រព្រឹត្តទៅឡើង ក៏ដូចជាការខិតខំប្រឹងប្រែង ព្យាយាមសិក្សាស្រាវជ្រាវយ៉ាងល្អិតល្អន់ និងការយកចិត្តទុកដាក់ជាទីបំផុតក្នុងការសម្រិតសម្រាំងចម្រាញ់យកខ្លឹមសារដែលមានភាពត្រឹមត្រូវ និងសំខាន់ដើម្បីយកមកចងក្រងធ្វើជាសៀវភៅនេះឡើង។ ក្នុងស្នាដៃនេះផងដែរ យើងបានសរសេររៀបរាប់ពី លក្ខខណ្ឌនៃការធ្វើសន្តតិកម្មតាមមតកសាសន៍ បែបបទនីតិវិធី ទម្រង់ សារៈសំខាន់ អានុភាពលិខិតមតកសាសន៍ និងការទាមទារលើភាគបម្រុងដែលមានចែងក្នុងច្បាប់។ យើងពិតជាសង្ឃឹម និងជឿជាក់យ៉ាងមុតមាំក្នុងចិត្តថាស្នាដៃនេះពិតជាអាចចូលរួមចំណែកក្នុងការផ្តល់ចំណេះដឹងអំពីការបែងចែកមត៌ក (សន្តតិកម្មតាមបណ្តាំ) ទៅដល់បងប្អូនប្រជាពលរដ្ឋ មិត្តអ្នកអាន និស្សិត សិស្សនិស្សិត អ្នកស្រាវជ្រាវជំនាន់ក្រោយៗឱ្យបានដឹង ហើយក៏ដើម្បីចូលរួមលើកស្ទួយវិស័យយុត្តិធម៌ និងជាឧត្តមប្រយោជន៍ដល់ គ្រួសារ សហគមន៍ និងសង្គមឱ្យកាន់តែរីកចម្រើនមួយកម្រិតថែមទៀតដែរ។

ជាទីបញ្ចប់ យើងខ្ញុំសូមលើកដៃប្រណមដោយក្តីគោរព ក៏ដូចជាការយោគយល់ និងខន្តីអភ័យទោសទុកជាមុនពីសំណាក់សិស្សនិស្សិត មិត្តអ្នកអាន សាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវនូវរាល់កំហុសឆ្គងណាមួយ ទាំងអត្ថន័យ ខ្លឹមសារ ប្រយោគ ឃ្លាឃ្លោង អក្ខរាវិរុទ្ធ ការប្រើប្រាស់ពាក្យពេចន៍មិនសមរម្យដែលកើតមានឡើងដោយអចេតនាត្រង់ប្រការណាមួយនៃស្នាដៃមួយនេះ។ យើងខ្ញុំរីករាយក្នុងការទទួលយកនូវការរិះគន់ទាំងឡាយ ក្នុងការស្ថាបនាការស្រាវជ្រាវនេះឱ្យកាន់តែល្អប្រសើរជាងនេះមួយកម្រិតទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី ១**

**សញ្ញាណទូទៅនៃសន្តតិកម្ម**

**ផ្នែកទី ១. សន្តតិកម្ម** ........ ៤

**កថាភាគទី ១. និយមន័យនៃសន្តតិកម្ម** ........ ៤

**កថាភាគទី ២. គោលបំណងនៃសន្តតិកម្ម** ........ ៤

**កថាភាគទី ៣. លក្ខណៈពិសេសនៃសន្តតិកម្ម** ........ ៥

**ផ្នែកទី ២. ប្រភេទ និងសារៈសំខាន់នៃសន្តតិកម្ម** ........ ៥

**កថាភាគទី ១. ប្រភេទនៃសន្តតិកម្ម** ........ ៥

**កថាភាគទី ២. សារៈសំខាន់នៃសន្តតិកម្ម** ........ ៥

១. សារៈសំខាន់នៃសន្តតិកម្មតាមមតកសាសន៍ ........ ៥

២. សារៈសំខាន់នៃសន្តតិកម្មតាមច្បាប់ ........ ៦

**ជំពូកទី ២**

**សន្តតិកម្មតាមមតកសាសន៍**

**ផ្នែកទី ១. សញ្ញាណទូទៅនៃសន្តតិកម្មតាមមតកសាសន៍** ........ ៨

**កថាភាគទី ១. និយមន័យ** ........ ៨

**កថាភាគទី ២. គោលបំណងនៃការធ្វើសន្តតិកម្មតាមមតកសាសន៍** ........ ៩

**ផ្នែកទី ២. លក្ខខណ្ឌគ្រឹះនៃការធ្វើសន្តតិកម្មតាមមតកសាសន៍** ........ ១០

**កថាភាគទី ១. សមត្ថភាពក្នុងការធ្វើមតកសាសន៍** ........ ១០

**កថាភាគទី ២. បុគ្គលដែលអាចធ្វើមតកសាសន៍បាន** ........ ១១

១. នីតិជន ........ ១១

២. អនីតិជនដែលទទួលបានអគ្គាធីនភាព ........ ១២

**ផ្នែកទី ៣. ប្រភេទនៃទម្រង់សន្តតិកម្មតាមមតកសាសន៍** ........ ១២

**កថាភាគទី ១. ទម្រង់នៃមតកសាសន៍ក្នុងស្ថានភាពទូទៅ** ........ ១២

១. មតកសាសន៍ដោយលិខិតឯកជន ..... ១២
ក. អត្ថប្រយោជន៍ ..... ១៣
ខ. គុណវិបត្តិ ..... ១៣
២. មតកសាសន៍ដោយលិខិតយថាភូត ..... ១៣
ក. អត្ថប្រយោជន៍ ..... ១៤
ខ. គុណវិបត្តិ ..... ១៤
៣. មតកសាសន៍ដោយលិខិតសម្ងាត់ ..... ១៥
ក. អត្ថប្រយោជន៍ ..... ១៥
ខ. គុណវិបត្តិ ..... ១៦
**កថាភាគទី ២. ទម្រង់នៃមតកសាសន៍ក្នុងស្ថានភាពពិសេស** ..... ១៦
១. មតកសាសន៍បុគ្គលដែលស្ថិតក្រោមអាណាព្យាបាលទូទៅ ..... ១៦
២. មតកសាសន៍បុគ្គលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ..... ១៧
៣. មតកសាសន៍បុគ្គលដែលត្រូវជាប់ឃុំឃាំង ..... ១៨
៤. មតកសាសន៍បុគ្គលដែលមិនអាចនិយាយបាន ឬ ស្តាប់បាន ..... ១៩
**ផ្នែកទី ៤. ភាពចាំបាច់នៃការតាក់តែងលិខិតមតកសាសន៍** ..... ២០
**កថាភាគទី ១. កាលបរិច្ឆេទ និងហត្ថលេខានៅក្នុងលិខិតមតកសាសន៍** ..... ២០
**កថាភាគទី ២. ការចូលរួមរបស់សាក្សីក្នុងពេលធ្វើមតកសាសន៍** ..... ២១
**កថាភាគទី ៣. មុខងារ និងសារៈសំខាន់របស់សារការីក្នុងការធ្វើលិខិតមតកសាសន៍** ..... ២២
១. មុខងាររបស់សារការីក្នុងការតាក់តែងលិខិតមតកសាសន៍ ..... ២២
២. សារៈសំខាន់របស់សារការីក្នុងការតាក់តែងលិខិតមតកសាសន៍ ..... ២៣
**ផ្នែកទី ៥. ចំណុចនៃមតកសាសន៍** ..... ២៤
**កថាភាគទី ១. ការកំណត់ចំណែកមត៌ក** ..... ២៤
**កថាភាគទី ២. ការកំណត់វិធីបែងចែកដោយមតកសាសន៍** ..... ២៥
**កថាភាគទី ៣. អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន** ..... ២៥
**កថាភាគទី ៤. ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍** ..... ២៦
**ផ្នែកទី ៦. ការលុបចោលនូវមតកសាសន៍** ..... ២៦

**កថាភាគទី ១. ការមិនគោរពតាមម្រង់មតកសាសន៍** ........ ២៦
**កថាភាគទី ២. ការលុបចោលមតកសាសន៍ដោយចាត់ចែងនាពេលនៅរស់** ........ ២៧
**កថាភាគទី ៣. ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍** ........ ២៧
**ផ្នែកទី ៧. អានុភាពនៃលិខិតមតកសាសន៍ និងការកំណត់ចំណែកមត៌ក** ........ ២៧
**កថាភាគទី ១. ពេលដែលមតកសាសន៍បង្កើតអានុភាព** ........ ២៧
១. មរណភាពរបស់ម្ចាស់បណ្ដាំ ........ ២៧
២. មតកសាសន៍ដែលភ្ជាប់លក្ខខណ្ឌបង្អង់ ........ ២៨
៣. ការប្រកាសពីការបាត់ខ្លួន ........ ២៨
**កថាភាគទី ២. អានុភាពនៃការកំណត់ចំណែកមត៌ក** ........ ២៩

## ជំពូកទី៣

## ការប្រតិបត្តិមតកសាសន៍ ភាគបម្រុង និងអច្ច័យទាន

**ផ្នែកទី ១. ការប្រតិបត្តិមតកសាសន៍** ........ ៣១
**កថាភាគទី ១. ការពិនិត្យ និងការបើកមតកសាសន៍** ........ ៣១
**កថាភាគទី ២. ការកំណត់អ្នកប្រតិបត្តិមតកសាសន៍** ........ ៣១
១. ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ដោយមតកជន ........ ៣២
២. ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ដោយតុលាការ ........ ៣២
៣. ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ ........ ៣២
**កថាភាគទី ៣. មុខងារ និងសិទ្ធិអំណាចអ្នកប្រតិបត្តិមតកសាសន៍** ........ ៣៣
១. តួនាទី និងសិទ្ធិអំណាចអ្នកប្រតិបត្តិមតកសាសន៍ (ជ្រើសតាំងបន្ត) ........ ៣៣
២. សហអ្នកប្រតិបត្តិមតកសាសន៍ ........ ៣៤
៣. សោហ៊ុយ និងកម្រៃនៃអ្នកប្រតិបត្តិមតកសាសន៍ ........ ៣៤
៤. ការលាឈប់ និងបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ ........ ៣៤
**ផ្នែកទី ២. ភាគបម្រុង** ........ ៣៥
**កថាភាគទី ១. និយមន័យ** ........ ៣៥
**កថាភាគទី ២. អ្នកមានសិទ្ធិលើភាគបម្រុង** ........ ៣៦
**កថាភាគទី ៣. លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង** ........ ៣៦

**កថាភាគទី ៤. ចំណែកនៃភាគបម្រុងរបស់សន្តតិជនម្នាក់ៗ** ... ៣៧
**កថាភាគទី ៥. ការកាត់បន្ថយភាគបម្រុង** ... ៣៨
១. ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ... ៣៨
២. លំដាប់នៃការកាត់បន្ថយនៃភាគបម្រុង ... ៣៩
**កថាភាគទី ៦. ការសងផលមកវិញចំពោះបុគ្គលមានសិទ្ធិលើភាគបម្រុង** ... ៤០
**កថាភាគទី ៧. ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង** ... ៤១
១. អាជ្ញាយុកាល ... ៤១
២. ការបោះបង់ភាគបម្រុង ... ៤២
**ផ្នែកទី៣. អច្ច័យទាន** ... ៤២
**កថាភាគទី ១. និយមន័យអច្ច័យទាន** ... ៤២
**កថាភាគទី ២. ប្រភេទនៃអច្ច័យទាន** ... ៤៣
១. អច្ច័យទានសកល ... ៤៣
២. អច្ច័យទានមានកំណត់ ... ៤៣
**កថាភាគទី ៣. សិទ្ធិ និងភាពព្វកិច្ចរបស់អច្ច័យលាភី** ... ៤៣
**កថាភាគទី ៤. ការយល់ព្រម និងការបោះបង់អច្ច័យទាន** ... ៤៤
១. ការបោះបង់អច្ច័យទាន ... ៤៤
២. ការទទួលស្គាល់ ឬ បោះបង់ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន ... ៤៥
៣. ការបោះបង់ ឬ ការទទួលស្គាល់ដោយសន្តតិជនរបស់អច្ច័យលាភី ... ៤៦
៤. ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ... ៤៦
៥. ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់ ... ៤៦
**សេចក្តីសន្និដ្ឋាន** ... ៤៦
**អនុសាសន៍** ... ៤៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ទ្រព្យសម្បត្តិ គឺជាផ្នែកមួយយ៉ាងសំខាន់បំផុតរបស់បុគ្គលម្នាក់ៗក្នុងការរស់នៅជីវភាពប្រចាំថ្ងៃ។ ជាទូទៅមជ្ឈដ្ឋានភាគច្រើន អាចស្គាល់កេរអាករពីដូនតាដែលបានបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយ ប៉ុន្តែពួកគាត់មិនស្គាល់កេរអាករនោះថាជាអ្វីពិតប្រាកដនោះទេ។ ជាក់ស្តែងពាក្យថាកេរអាករនៅក្នុងការសិក្សាច្បាប់ គេប្រើពាក្យមត៌ក ហើយមត៌កនោះសំដៅទៅលើទ្រព្យសម្បត្តិរបស់ជនដែលទទួលមរណភាព។ ទំនាក់ទំនងសិទ្ធិ និងទ្រព្យសម្បត្តិរបស់បុគ្គលកំពុងនៅមានជីវិតគេហៅថា (កម្មសិទ្ធិ) ចំណែកឯ ទ្រព្យរបស់បុគ្គលដែលបានបាត់បង់អាយុជីវិតទៅហើយ ត្រូវបានប្រែក្លាយពីកម្មសិទ្ធិនោះមកជាមត៌កវិញ។ ការផ្លាស់ប្តូរ ឬការផ្ទេរកម្មសិទ្ធិ រវាងមនុស្សនៅរស់ អាចធ្វើក្រោមរូបភាពដូចជា ការលក់ ការដូរ ប្រទានកម្ម ឬ អំណោយ។ ផ្ទុយទៅវិញ ការផ្ទេរមត៌ករបស់អ្នកស្លាប់ មកឱ្យមនុស្សនៅរស់ ត្រូវធ្វើតាមរយៈអច្ច័យទាន ឬសន្តតិកម្ម។ ម្យ៉ាងវិញទៀត នៅលើពិភពលោករបបសន្តតិកម្ម មានគោលការណ៍ពីរប្រភេទចម្បងៗ គឺគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ និងគោលការណ៍ជម្រះបញ្ជី។ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ មានន័យថា សន្តតិជនត្រូវទទួលស្នងមត៌កតែម្តង មុននឹងធ្វើការបែងចែក ឬសងបំណុល ដោយសន្តតិជនមានសិទ្ធិទទួលយកទាំងស្រុង ឬទទួលយកដោយមានកម្រិត ឬលះបង់សន្តតិកម្ម។ ដោយឡែកគោលការណ៍ជម្រះបញ្ជី គឺជាការជម្រះសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ហើយសន្តតិជនអាចស្នងមត៌កបាន តែក្នុងករណី នៅសល់ទ្រព្យសកម្ម ប៉ុណ្ណោះ និងប្រសិនបើកាតព្វកិច្ចធ្ងន់ធ្ងរ ត្រូវប្រកាសក្ស័យធន។

ពាក្យសន្តតិកម្មក្នុងន័យគតិយុត្តដែលមកពីពាក្យ ថាការផ្ទេរ មានន័យថាជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជន (អ្នកស្លាប់) ទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។ ម្យ៉ាងវិញទៀត ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិទាក់ទងនឹងសន្តតិកម្មមាន ២(ពីរ) ប្រភេទគឺ សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមបណ្តាំ (មតកសាសន៍) ហើយច្បាប់បានកំណត់នីតិវិធី ក៏ដូចជាដំណើរការយ៉ាងត្រឹមត្រូវ និងច្បាស់លាស់នៅក្នុងការធ្វើសន្តតិកម្មទាំងពីរប្រភេទនេះ។ តាមច្បាប់កម្ពុជាសព្វថ្ងៃ ចំពោះរបបសន្តតិកម្មតាមរយៈមតកសាសន៍ ឬបណ្តាំ ក្រមរដ្ឋប្បវេណីបានកំណត់ថាជាសកម្មភាពឯកតោភាគី ដែលត្រូវធ្វើឡើងតាមរយៈទម្រង់កំណត់ដោយច្បាប់គឺ ទម្រង់មតកសាសន៍ជាលិខិតឯកជន ទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់ និងទម្រង់មតកសាសន៍ជាលិខិតយថាភូត។ ការធ្វើសន្តតិកម្មនេះ មិនថាសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមតកសាសន៍ គឺត្រូវធ្វើឡើងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីទើបនាំឱ្យការធ្វើសន្តតិកម្មនោះមានសុពលភាព និងអានុភាព។ ដោយប្រធានបទយើងខ្ញុំបានជ្រើសរើស សន្តតិកម្មតាមមតកសាសន៍មកធ្វើការសិក្សា និងបកស្រាយដោយមានការនិយាយអំពីសញ្ញាណទូទៅពាក់ព័ន្ធ និងសន្តតិកម្មតាមច្បាប់បន្តិចបន្តួច តែប្រធានបទរបស់យើង

ផ្តោតទៅលើ សន្តតិកម្មតាមមតកសាសន៍ប៉ុណ្ណោះ។ ហេតុនេះហើយ តាមរយៈការចង្អុលបង្ហាញ ក៏ដូចជាការជ្រោមជ្រែង និងការលើកទឹកចិត្តពីសំណាក់សាស្ត្រាចារ្យណែនាំទើបខ្ញុំក្នុងនាមជានិស្សិតនីតិសាស្ត្រ និងប្រជាពលរដ្ឋកម្ពុជាមួយរូប បានសម្រេចលើកយកប្រធានបទស្តីពី "សន្តតិកម្មតាមមតកសាសន៍" នេះមកធ្វើការបកស្រាយ ដើម្បីឱ្យនិស្សិតកំពុងសិក្សា និងនិស្សិតជំនាន់ក្រោយៗទៀតក៏ដូចជាប្រជាពលរដ្ឋទូទៅបានយល់ពីបញ្ហាសន្តតិកម្មតាមមតកសាសន៍នៅព្រះរាជាណាចក្រកម្ពុជាកាន់តែច្បាស់ និងយល់អំពីការតាក់តែងលិខិតមតកសាសន៍ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ក៏ដូចជាអានុភាពក្រោយពេលម្ចាស់បណ្តាំទទួលមរណភាពចៀសវាង នៅពេលមតកជនបានទទួលមរណភាពហើយ បែរជាបណ្តាំនោះគ្មានអានុភាពទៅវិញ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ផ្អែកទៅតាមការរៀបរាប់អំពីខ្លឹមសារខ្លះៗខាងលើនេះ យើងបានដឹងហើយថាអ្វីទៅជាសន្តតិកម្មដែលត្រូវបានទទួលស្គាល់ដោយច្បាប់ ហើយសន្តតិកម្មនេះទៀតសោតមានពីរប្រភេទ។ ប៉ុន្តែអ្វីដែលយើងគួរដឹង និងស្វែងយល់បន្ថែមទៀតនោះគឺ តើសន្តតិកម្មបែងចែកជាប៉ុន្មាន? តើសន្តតិកម្មតាមមតកសាសន៍នេះមានលក្ខណៈពិសេសដូចម្តេចខ្លះ? លើសពីនេះ តើមានលក្ខខណ្ឌថែងកំណត់ក្នុងច្បាប់អ្វីខ្លះដែលរាល់ការធ្វើសន្តតិកម្មតាមមតកសាសន៍តាមទម្រង់នេះប្រព្រឹត្តទៅបាន និងមានអានុភាព ដោយគោរពទៅតាមបញ្ញត្តិនៃច្បាប់ជាធរមាន? ក្រោយពីមតកជនទទួលមរណភាព តើការបែងចែកទ្រព្យសម្បត្តិទម្រង់ខាងលើនេះ សន្តតិជនម្នាក់ៗមានសិទ្ធិលើអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ និងការរៀបចំតាក់តែងនេះធ្វើឡើងក្នុងគោលបំណងចែករំលែកនូវចំណេះដឹងជាមូលដ្ឋាន ក៏ដូចជាពុទ្ធិក្នុងការត្រិះរិះពិចារណាទៅលើបញ្ហាពាក់ព័ន្ធនៃការបែងចែកមរតក និងការស្វែងយល់បន្ថែមក្រោយពេលបុគ្គលណាម្នាក់បានទទួលមរណភាព ឬមុនពេលទទួលមរណភាពក្នុងការបង្ហាញឆន្ទៈចុងក្រោយរបស់មតកជន។ ជាពិសេសប្រធានបទមួយនេះពិតជាមានសារៈសំខាន់ដែលបុគ្គលម្នាក់ៗ ឬ ប្រជាពលរដ្ឋ ក៏ដូចជានិស្សិត ក្នុងការស្វែងយល់បន្ថែមក្នុងការបង្កើនចំណេះដឹង។ ម្យ៉ាងវិញទៀត យើងខ្ញុំចង់ធ្វើយ៉ាងណាក្រោយពេលដែលម្ចាស់បណ្តាំបានធ្វើការផ្ទេរមត៌កទៅតាមលិខិតបណ្តាំដោយឆន្ទៈពិតប្រាកដរបស់គាត់មានអានុភាព ចៀសវាងនៅពេលធ្វើលិខិតមតកសាសន៍នោះ ដោយខុសទម្រង់ ឬបែបបទ នីតិវិធី និងច្បាប់ដែលបានកំណត់ដែលឈានទៅរកមតកសាសន៍ដែលធ្វើឡើងនោះត្រូវបានលុបចោល និងមិនមានអានុភាព។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះប្រធានបទដែលយើងខ្ញុំបានលើកយកមកសិក្សាស្រាវជ្រាវនេះគឺ យើងបានចងក្រង ក៏ដូចជាស្រាវជ្រាវផ្តោតសំខាន់ទៅលើក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ រហូតដល់បច្ចុប្បន្នតែប៉ុណ្ណោះ។ ហើយចំណុចសំខាន់មួយដែលយើងខ្ញុំយកមករៀបចំចងក្រងឡើងនោះមានដូចជា៖

- ស្វែងយល់អំពីសញ្ញាណនៃរបបសន្តតិកម្ម
- សញ្ញាណទូទៅនៃសន្តតិកម្មតាមបណ្តាំ (មតកសាសន៍)
- ស្វែងយល់អំពីអានុភាព ក៏ដូចជាសុពលភាពនៃការធ្វើសន្តតិកម្មតាមមតកសាសន៍
- ស្វែងអំពីគោលការណ៍ទូទៅនៃរបបភាគបម្រុង និងការទាមទារភាគបម្រុង

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ ក៏ដូចជាការចងក្រងប្រធានបទអ្វីមួយ យើងខ្ញុំទាំងពីរបានចំណាយពេលជាច្រើនទាំងកម្លាំងកាយ និងកម្លាំងចិត្ត ជាពិសេសការខិតខំព្យាយាម ជម្នះគ្រប់ឧបសគ្គទើបការសិក្សាស្រាវជ្រាវមួយនេះទទួលបានជោគជ័យ។ ដោយប្រធានបទដែលខ្ញុំបានលើកឡើងនេះ គឺពិតជាមានសារៈសំខាន់សម្រាប់យើងខ្ញុំ ក៏ដូចជានិស្សិតទាំងអស់ដូចជា៖

- ទទួលបានចំណេះដឹងពាក់ព័ន្ធនឹងវិធីសាស្ត្រស្រាវជ្រាវ
- ទទួលបានឯកសារជាច្រើនដែលទាក់ទងទៅនឹងប្រធានបទ
- ស្វែងយល់ ក៏ដូចជាយល់ដឹងកាន់តែលម្អិតទៅលើប្រធានបទដែលបានលើកយកមកស្រាវជ្រាវ
- ជាពិសេសបានបន្សល់ទុកស្នាដៃមួយនេះសម្រាប់សិស្ស និស្សិត ក៏ដូចជាបណ្តាអ្នកសិក្សាស្រាវជ្រាវទាំងឡាយបានធ្វើជាមូលដ្ឋានក្នុងការស្វែងយល់ និងទទួលបានចំណេះដឹងបន្ថែម។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ចំណែកឯវិធីសាស្ត្រក្នុងការស្រាវជ្រាវវិញ យើងខ្ញុំទាំងពីរនាក់បានខិតខំប្រើប្រាស់នូវចំណេះជំនាញ ក៏ដូចជាវិធីសាស្ត្រ ទេពកោសល្យមកធ្វើការចងក្រង និងរៀបចំសារណានេះឡើង ដោយបានដកស្រង់ចេញពីក្រមរដ្ឋប្បវេណី អត្ថបទ ខ្លឹមសារសំខាន់ៗចេញលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងសៀវភៅរបាយការណ៍នៅតាមបណ្ណាល័យ ធ្វើការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណែត ព្រមទាំងឯកសារសិស្សច្បងមួយចំនួនផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទនៃសារណាដែលយើងធ្វើនេះ គឺបានបកស្រាយដោយផ្អែកទៅលើក្រមរដ្ឋប្បវេណី សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ឯកសារបទដ្ឋានគតិយុត្តជាច្រើន សៀវភៅរបស់សាស្ត្រាចារ្យ អ្នកនិពន្ធ និងការអនុវត្តជាក់ស្តែង ព្រមទាំងគោលការណ៍ដែលបានបញ្ញត្តិក្នុងច្បាប់ ស្តីពី ការធ្វើសន្តតិកម្មតាមមតកសាសន៍ ក្នុងនោះយើងខ្ញុំបានបែងចែកជា ៣ជំពូកធំៗដូចជា ៖

## ជំពូកទី ១. សញ្ញាណទូទៅនៃសន្តតិកម្ម

## ជំពូកទី ២. សន្តតិកម្មតាមមតកសាសន៍

## ជំពូកទី ៣. ការប្រតិបត្តិមតកសាសន៍ ភាគបម្រុង និងអច្ច័យទាន

# ជំពូកទី ១
# សញ្ញាណទូទៅនៃសន្តតិកម្ម

# ជំពូកទី ១

# សញ្ញាណទូទៅនៃសន្តតិកម្ម

## ផ្នែកទី ១. សន្តតិកម្ម

បច្ចុប្បន្នកម្ពុជាមានរបបសន្តតិកម្ម ដែលបញ្ញត្តិជាក់លាក់ទាំងលក្ខណៈសាធាតុ លក្ខណៈទម្រង់ និងនីតិវិធីអនុវត្តជាក់ស្តែង ក៏ដូចជាភាពច្បាស់លាស់តាមរយៈក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ ដែលដាក់ឱ្យប្រើប្រាស់ជំនួសក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩៦៧ ដែលចាត់ទុកថាជាការធ្វើបច្ចុប្បន្នភាពនៃសន្តតិកម្មស្របទៅតាមការវិវត្តន៍របស់សង្គម និងសាកលភាវូបនីយកម្ម។ តាមរយៈក្រមរដ្ឋប្បវេណីកម្ពុជាបច្ចុប្បន្នបានបែងចែកប្រភេទនៃសន្តតិកម្មមិនខុសពីក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ១៩៦៧ នោះទេ គឺសន្តតិកម្មមានពីរប្រភេទ រួមមាន សន្តតិកម្មតាមបណ្តាំ និងសន្តតិកម្មតាមច្បាប់ក្នុងករណីគ្មានបណ្តាំ ឬ បណ្តាំត្រូវចាត់ទុកជាមោឃៈជាអាទិ៍។

### កថាភាគទី ១. និយមន័យនៃសន្តតិកម្ម

តាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនមានមាត្រាណាមួយដែលបានចែងពីនិយមន័យនៃសន្តតិកម្មទេ ប៉ុន្តែបើក្រឡេកមកមើលសទ្ទានុក្រមរដ្ឋប្បវេណីបានផ្តល់ខ្លឹមសារនៃសន្តតិកម្មថា គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់[1]។

ចំណែកឯសទ្ទានុក្រមរដ្ឋប្បវេណី ឆ្នាំ១៩៦៧ ពាក្យសន្តតិកម្មមានន័យថា គឺជាការបញ្ជូនតាមផ្លូវច្បាប់នូវទ្រព្យរបស់អ្នកស្លាប់ទៅឱ្យអ្នករស់។ មត៌ក ឬទ្រព្យរបស់ខ្មោចដែលត្រូវបានទាយាទ[2]។

មួយវិញទៀត បើយើងក្រឡេកទៅមើលក្រមរដ្ឋប្បវេណី ឆ្នាំ១៩៦៧ មាត្រា៤៨៦ បានចែងថាសន្តតិកម្មគឺជាការផ្ទេរនូវបេតិកភណ្ឌ នៃបុគ្គលណាម្នាក់ដែលស្លាប់ឱ្យទៅជនម្នាក់ ឬច្រើននាក់ដែលហៅថា ទាយាទ ឬសន្តតិជន។

### កថាភាគទី ២. គោលបំណងនៃសន្តតិកម្ម

សន្តតិកម្ម គឺមានគោលបំណងធ្វើយ៉ាងណាមុនពេលដែលជនណាម្នាក់បានស្លាប់ (មតកជន) បានបង្ហាញឆន្ទៈចុងក្រោយក្នុងការបែងចែកទ្រព្យសម្បត្តិ និងការផ្ទេរសិទ្ធិទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់ទៅតាមរង្វង់ញាតិរបស់មតកជនផ្ទាល់។ ម្យ៉ាងវិញទៀត សន្តតិកម្មនេះក៏មានគោលបំណងដើម្បីជាភាពងាយស្រួលក្រោយពេលមតកជនបានស្លាប់ទៅ ដោយបានកំណត់ ឬធ្វើការបែងចែកមត៌កទៅតាមឆន្ទៈផ្ទាល់ និងចាត់ចែង

[1] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ បោះពុម្ពលើកទី១ ឆ្នាំ២០០៧

[2] សទ្ទានុក្រមរដ្ឋប្បវេណី ឆ្នាំ១៩៦៧

ទៅតាមស្ថានភាពទ្រព្យជាក់ស្តែងរបស់មតកជនទៅតាមច្បាប់កំណត់ដែលត្រូវទទួលបានចំណែកស្មើៗគ្នាទៅតាមភាគរបស់សន្តតិជនម្នាក់ៗដែលជារង្វង់ញាតិរបស់មតកជនផ្ទាល់។

### កថាភាគទី ៣. លក្ខណៈពិសេសនៃសន្តតិកម្ម

តាមការពិតទៅសន្តតិកម្ម គឺធ្វើយ៉ាងណាពេលម្ចាស់ទ្រព្យបានទទួលមរណភាព ដោយបន្សល់ទុកនូវទ្រព្យសម្បត្តិ ក្នុងការបែងចែកមត៌កទៅឱ្យសន្តតិជនម្នាក់ៗ បើករណីគ្មានបណ្តាំ ដោយច្បាប់បានបញ្ញត្តិចែងថាត្រូវធ្វើការបែងចែកមត៌កស្មើៗគ្នា។ ចំណែកសន្តតិកម្មតាមបណ្តាំវិញ គឺបានផ្តល់សិទ្ធិ និងសេរីភាពនៃឆន្ទៈរបស់ម្ចាស់បណ្តាំផ្ទាល់ក្នុងការបែងចែក ក៏ដូចជាបំណងចាត់ចែង ឬបែងចែកទ្រព្យសម្បត្តិនៅពេលគាត់មានជីវិត ទៅឱ្យបុគ្គលដែលជាសន្តតិជន។ មិនតែប៉ុណ្ណោះការធ្វើសន្តតិកម្មតាមមតកសាសន៍ជនក្រៅពីញាតិរបស់មតកជនក៏អាចទទួលបានមត៌កផងដែរ ដោយអាស្រ័យលើឆន្ទៈមតកជនសំដែងទៅក្នុងលិខិតបណ្តាំនោះ។

## ផ្នែកទី ២. ប្រភេទ និងសារៈសំខាន់នៃសន្តតិកម្ម

### កថាភាគទី ១. ប្រភេទនៃសន្តតិកម្ម

ដោយយោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាសន្តតិកម្មត្រូវបានបែងចែកជាពីរប្រភេទ គឺសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ (បណ្តាំ)។

**សន្តតិកម្មតាមច្បាប់** ៖ ជាការផ្ទេរសិទ្ធិ និងកាតព្វកិច្ចនៃទ្រព្យទាំងស្រុងរបស់មតកជន មកឱ្យជនដែលត្រូវបានចាត់ទុកថាជាសន្តតិជន តាមច្បាប់កំណត់ ដោយសារគ្មានលិខិតបណ្តាំរបស់មតកជនអំពីវិធីបែងចែកចំណែកមត៌កទៅឱ្យជនដែលត្រូវបានចាត់ទុកជាសន្តតិជន តាមលក្ខណៈសមភាពជាក់ស្តែងនៃចំណែកមត៌កទៅឱ្យសន្តតិជន។

**សន្តតិកម្មតាមមតកសាសន៍** ៖ ជាមធ្យោបាយបែងចែកមត៌កតាមឆន្ទៈរបស់មតកជន ក្រៅពីការកំណត់របស់ច្បាប់ ប៉ុន្តែមតកជន មិនអាចកំណត់អំពីវិធីបែងចែកដែលមានលក្ខណៈប៉ះពាល់ដល់ភាគបម្រុងដែលជាសិទ្ធិរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះឡើយ។

### កថាភាគទី ២. សារៈសំខាន់សន្តតិកម្ម

#### ១. សារៈសំខាន់នៃសន្តតិកម្មតាមមតកសាសន៍

សន្តតិកម្មតាមមតកសាសន៍ ឬការរៀបចំលិខិតបណ្តាំមត៌កមានសារៈសំខាន់ចំពោះម្ចាស់បណ្តាំដែលមានបំណងចង់ធ្វើបណ្តាំ ដោយការសម្តែងឆន្ទៈចុងក្រោយដោយផ្ទាល់របស់ម្ចាស់បណ្តាំក្នុងការបែងចែកមត៌ក និងមានភាពប្រសើរចំពោះម្ចាស់ទ្រព្យចូលដល់ស្ថានភាពចាស់ជរា ឬគ្មានសហព័ទ្ធជាដៃគូអាចបន្តគ្រប់គ្រងបានពីព្រោះវាផ្តល់ឱ្យមតកជន (ម្ចាស់ទ្រព្យ) មានលទ្ធភាពក្នុងការពិនិត្យពីគុណសម្បត្តិរបស់សន្តតិជនដែលត្រូវទទួលពីរបៀបចាត់ចែងទ្រព្យរបស់ខ្លួន និងការស្វែងរកអ្នកប្រតិបត្តិមតកសាសន៍សំរាប់ជួយខ្លួនផងដែរ។ ជាពិសេស

ច្បាប់បានផ្តល់សិទ្ធិ និងគោរពទៅលើឆន្ទៈចុងក្រោយរបស់ម្ចាស់បណ្តាំក្នុងការបែងចែកមត៌ករបស់គាត់ដោយសេរី លើកលែងតែមានការបំពានទៅលើភាគបម្រុងប៉ុណ្ណោះ។ លើសពីនេះ ការរៀបចំលិខិតបណ្តាំ ឬការធ្វើសន្តតិកម្មតាមមតកសាសន៍នេះទៀតសោត នឹងធ្វើឱ្យមតកជននៅតែជាម្ចាស់កម្មសិទ្ធិរបស់ខ្លួន ដែលអាចចៀសវាងបាននូវហានិភ័យទាំងឡាយកើតឡើងពេលកំពុងមានជីវិតរស់នៅ ហើយវាក៏អាចជួយការពារវិវាទ ឬជម្លោះពីក្នុងចំណោមសន្តតិជនដោយប្រការណាមួយពីបញ្ហាទទួលបានទ្រព្យសម្បត្តិតិច ឬច្រើននោះផងដែរ។ លើសពីនេះទៀត ការបែងចែកទ្រព្យសម្បត្តិ ក៏ដូចជាការចាត់ចែងទ្រព្យសម្បត្តិទៀតសោតក៏បានផ្តល់ សារៈសំខាន់ និងអត្ថប្រយោជន៍មួយចំនួនទៀតដែរមានដូចជា៖

- ជួយសម្រួល និងជួយបញ្ចៀសរាល់វិវាទក្នុងគ្រួសារ ឬ វិវាទទាយាទក្នុងការបែងចែកចំណែកមត៌ក ពីព្រោះតែមតកសាសន៍នេះត្រូវបានធ្វើឡើងដោយឆន្ទៈរបស់មតកជនពេលនៅមានជីវិត ដែលបានកំណត់យ៉ាងច្បាស់នូវរាល់ចំណែកដែលទាយាទទទួលបាន។
- អាចកំណត់អំពីការផ្តាច់មត៌កពីសន្តតិជនបាន ពោលគឺបុគ្គលនោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងការបែងចែកចំណែកមត៌ក ហើយករណីនេះអាចកើតមានឡើងដោយសារតែ បុគ្គលដែលត្រូវបានកាត់ផ្តាច់នោះទទួលបាននូវផលប្រយោជន៍ពិសេស ឬ ទទួលបានចំណែកទ្រព្យសម្បត្តិនៅពេលមតកជននៅរស់ មួយវិញទៀតក៏មានករណីមួយចំនួនដែលអាចមកពីធ្វើបាបចំពោះមតកជន ការប្រមាថយ៉ាងធ្ងន់ធ្ងរ មិនយកចិត្តទុកដាក់ទៅលើមតកជននៅពេលដែលមតកជនមានជម្ងឺ ត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត និងបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់ជាអាទិ៍។
- ចុងក្រោយនោះ គឺមតកជនក៏អាចប្រើប្រាស់សិទ្ធិក្នុងការទទួលស្គាល់កូន ដោយកំណត់នៅក្នុងមតកសាសន៍បាន។ ការទទួលស្គាល់បែបនេះគឺក្នុងគោលបំណងកំណត់នូវបិតុភាពចំពោះកូន ឬ ទារកក្នុងគភ៌ ថែមទាំងដើម្បីផ្តល់សិទ្ធិអោយក្លាយជាទាយាទក្នុងការទទួលបានចំណែកមត៌កផងដែរ[3]។

### ២. សារៈសំខាន់នៃសន្តតិកម្មតាមច្បាប់

ការបង្កើតឱ្យមានសន្តតិកម្មតាមច្បាប់ពិតជាមានសារៈសំខាន់ណាស់ សម្រាប់ជួយសម្រួលដល់ការបែងចែកមត៌ករបស់មតកជន ជាពិសេស ក្នុងពេលដែលមតកជនមិនបានបន្សល់ទុកនូវបណ្តាំតាមឆន្ទៈសម្រាប់ធ្វើការបែងចែកទ្រព្យសម្បត្តិមុនពេលដែលខ្លួនទទួលមរណៈភាព។ លើសពីនេះ ការកំណត់ឱ្យមានសន្តតិកម្មតាមច្បាប់អាចជួយសម្រួល ឬទប់ស្កាត់វិវាទរវាងសមាជិកគ្រួសារ ឬបងប្អូនសាច់ញាតិរបស់មតកជន ដោយហេតុថាច្បាប់នឹងធ្វើការកំណត់អំពីជនណាដែលមានសិទ្ធិតាមផ្លូវច្បាប់ទៅលើចំណែកមត៌ករបស់មតកជនមុនគេ។

[3] មាត្រា៩៩៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ប្រសិនបើច្បាប់មិនបានកំណត់អំពីសន្តតិកម្មតាមច្បាប់ ហើយលំដាប់នៃសន្តតិជនមិនត្រូវបានកំណត់ អាចនាំឱ្យមានភាពមិនច្បាស់លាស់ក្នុងការបែងចែកមត៌ករបស់ជនដែលបានស្លាប់ទៅ និងអាចនាំឱ្យសាច់ញាតិរបស់មតកជន ឬបុគ្គលដែលអាចទទួលបានប្រយោជន៍ពីមត៌កមានជម្លោះក្នុងការបែងចែកមត៌ក ឬទ្រព្យសម្បត្តិរបស់មតកជនជាដើម។ ដូច្នេះហើយបានជាបទប្បញ្ញត្តិនៃសន្តតិកម្មតាមច្បាប់ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានចូលមកបំពេញនូវតម្រូវការនៃការបែងចែកមត៌ករបស់មតកជន ដើម្បីចៀសវាងការបង្កឱ្យមានជម្លោះ ភាពស្មុគស្មាញ និងចំណាយពេលជាច្រើនក្នុងការបែងចែកមត៌ករបស់មតកជន។

# ជំពូកទី ២
# សន្តិកម្មតាមមតកសាសន៍

# ជំពូកទី ២

# សន្តតិកម្មតាមមតកសាសន៍

## ផ្នែកទី ១. សញ្ញាណទូទៅនៃសន្តតិកម្មតាមមតកសាសន៍

ឆន្ទៈរបស់បុគ្គល គឺជាការកត្តាយ៉ាងសំខាន់ដោយត្រូវបានការគោរព មិនថាបុគ្គលនោះនៅមានជីវិត ឬក៏ទទួលមរណភាពទៅហើយក្តី  ប្រសិនបើឆន្ទៈនោះមិនប៉ះពាល់ទៅដល់ការអនុវត្តសិទ្ធិដែលច្បាប់ទទួលស្គាល់ ឬមិនប៉ះពាល់ទៅដល់សិទ្ធិសេរីភាពរបស់បុគ្គលដទៃណាមួយនោះ។ នេះគឺជាការទទួលស្គាល់ក៏ដូចជាសារៈសំខាន់នៃមតកសាសន៍  ដោយហេតុថាវាជាការសម្តែងឆន្ទៈចុងក្រោយបង្អស់របស់បុគ្គលដែលបានទទួលមរណភាពទៅ  ក្នុងការផ្ទេរសិទ្ធិ  និងករណីយកិច្ចរបស់ខ្លួនទៅឱ្យសន្តតិជនម្នាក់  ឬ  ច្រើននាក់ដើម្បីចាត់ចែងនូវទ្រព្យសម្បត្តិជាក់លាក់ណាមួយ ឬ ច្រើន ឬ ទ្រព្យផ្សេងទៀតរបស់ខ្លួនរាប់បញ្ចូលទាំងទ្រព្យអកម្មផងដែរ (បំណុល)។ ទោះបីជាសេរីភាពនៃការសម្តែងឆន្ទៈរបស់មតកជនត្រូវបានគោរពក៏ពិតមែន តែមតកសាសន៍មិនអាចធ្វើក្រោមទម្រង់ណាមួយ  ដែលមិនស្របតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីឡើយ  បើពុំនោះទេមតកសាសន៍នោះនឹងត្រូវរងនូវមោឃភាព និងបាត់បង់អានុភាពជាមិនខាន។

❖ **ការវិវត្តន៍របបមតកសាសន៍កម្ពុជាបច្ចុប្បន្ន**

ចំពោះរបបសន្តតិកម្មតាមរយៈបណ្តាំ  ឬ  មតកសាសន៍  ក្រមរដ្ឋប្បវេណីបានកំណត់ថាជាសកម្មភាពឯកតោភាគី  ដែលត្រូវធ្វើតាមរយៈទម្រង់កំណត់ដោយច្បាប់គឺ  ទម្រង់មតកសាសន៍ជាលិខិតយឯកជន  ទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់  និង  ទម្រង់មតកសាសន៍ជាលិខិតយថាភូត។ ប៉ុន្តែដើម្បីឱ្យមតកសាសន៍នៃទម្រង់នានាដែលត្រូវបានបង្កើតអាចមានអានុភាពយកទៅអនុវត្តបាន លុះត្រាតែធ្វើឡើងដោយស្របតាមលក្ខខណ្ឌទម្រង់កំណត់ដោយច្បាប់  ជាពិសេសគឺ សមត្ថភាពក្នុងការបង្ហាញឆន្ទៈ សមត្ថភាពក្នុងការធ្វើសកម្មភាព ព្រមទាំងលក្ខខណ្ឌនានាក្នុងករណីពិសេសផងដែរ។ តាមរយៈភាពសំបូរបែបនៃទម្រង់មតកសាសន៍នេះ វាបង្ហាញពីជម្រើសរបស់មតកជន ក្នុងការជ្រើសរើសយកការធ្វើបណ្តាំរបស់ខ្លួន ដែលស្របទៅតាមស្ថានភាព ជីវភាព នឹងហេតុការណ៍ណាមួយ។ នេះវាក៏បានបង្ហាញយ៉ាងច្បាស់ពីភាពជាក់លាក់ប្រកបដោយការបត់បែននៃរបបសន្តតិកម្មតាមរយៈបណ្តាំបែបទំនើបរបស់កម្ពុជាផងដែរ។

### កថាភាគទី ១. និយមន័យ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់សិទ្ធិឱ្យប្រជាពលរដ្ឋខ្មែរមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិ និងសិទ្ធិក្នុងការចាត់ចែងទៅលើទ្រព្យសម្បត្តិរបស់ខ្លួន រួមទាំងត្រូវបានការពារដោយច្បាប់ទៀតផង[4]។ មួយវិញទៀត

[4] មាត្រា៤៤ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

នៅក្នុងក្រមរដ្ឋប្បវេណីក៏បានចែងអំពីគោលការណ៍ស្វ័យភាពបុគ្គលឯកជន ដែលមានអត្ថន័យ និងគោលបំណង ក្នុងការគោរពសេរីភាពនៃការបង្ហាញឆន្ទៈរបស់បុគ្គលទៅលើការប្រើប្រាស់សិទ្ធិរបស់ខ្លួន ក៏រួមផ្សំទាំងសិទ្ធិក្នុងការធ្វើមតកសាសន៍ផងដែរ[5]។

មតកសាសន៍ ត្រូវបានប្រជាជនខ្មែរទូទៅស្គាល់ថាជាបណ្តាំមត៌ក ដែលម្ចាស់បណ្តាំបានធ្វើការផ្តែផ្តាំចាត់ចែងដល់សាច់សារលោហិតមុនពេលដែលខ្លួនទទួលមរណភាព។

នៅក្នុងសន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំងផ្នែករដ្ឋប្បវេណីបានឱ្យនិយមន័យពាក្យថា មតកសាសន៍ គឺជាលិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសម្តែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព[6]។ តាមន័យនេះ មតកសាសន៍យើងអាចហៅថាជាលិខិតបណ្តាំដែលបុគ្គលម្នាក់បានធ្វើឡើង នៅពេលដែលខ្លួននៅមានជីវិត ដោយសម្រេច និងបង្ហាញឆន្ទៈចុងក្រោយរបស់ខ្លួនក្នុងការចាត់ចែងនូវទ្រព្យសម្បត្តិទាំងឡាយដែលខ្លួនមាន។ ច្បាប់ពុំបានកម្រិតការចាត់ចែងនូវទ្រព្យសម្បត្តិ ចំពោះតែសន្តតិជនរបស់ខ្លួននោះទេ ប៉ុន្តែអាចជាតតិយជនផ្សេងទៀតតាមឆន្ទៈរបស់ម្ចាស់បណ្តាំ។

ច្បាប់បានបញ្ញត្តិបុគ្គលគ្រប់រូបមានសិទ្ធិចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនដោយសេរី តាមរយៈមតកសាសន៍ (សេរីភាពនៃការធ្វើបណ្តាំ)។

**កថាភាគទី ២. គោលបំណងនៃការធ្វើសន្តតិកម្មតាមមតកសាសន៍**

សន្តតិកម្មមានបណ្តាំ ជាសន្តតិកម្មដែលធ្វើឡើងដោយផ្អែកតាមឆន្ទៈរបស់មតកជនដោយ បែងចែកទៅតាមការចែងក្នុងមតកសាសន៍។ ក្នុងនោះផងដែរ សន្តតិកម្មតាមមតកសាសន៍មានគោលបំណងក្នុងការផ្តល់ជាជំនួយ ឬមធ្យោបាយក្នុងការបែងចែកមត៌កតាមឆន្ទៈរបស់មតកជន ក្រៅពីការកំណត់របស់ច្បាប់ ប៉ុន្តែមតកជនមិនអាចកំណត់អំពីវិធីបែងចែកដែលមានលក្ខណៈប៉ះពាល់ដល់ភាគបម្រុងដែលជាសិទ្ធិរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជន នោះឡើយ។ លើសពីនេះទៅទៀត ការកំណត់ចំណែកមត៌កនេះ ត្រូវតែមានលក្ខណៈសមស្របចំពោះបទប្បញ្ញត្តិនៃច្បាប់ផងដែរ ដូចជា ការផ្តាច់មត៌កពីសន្តតិជន តាមមតកសាសន៍ ត្រូវបញ្ជាក់ពីមូលហេតុ និងមតកសាសន៍ ត្រូវធ្វើឡើងតាមបញ្ញត្តិច្បាប់ជាធរមាន[7]។

---

[5] មាត្រា៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[6] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ឆ្នាំ២០០៧

[7] គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នីតិរដ្ឋប្បវេណី (មេរៀនសង្ខេប) បង្រៀនដោយ មេធាវី អ៊ីវ ប៉ូលី ថ្ងៃ ២១ ខែ ធ្នូ ឆ្នាំ២០១១ ទំព័រ ៣៥១

មតកសាសន៍ដែលមិនបានធ្វើឡើងតាមទម្រង់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ត្រូវចាត់ទុកជាមោឃៈ[8]។ ពេលដែលម្ចាស់បណ្តាំបានទទួលមរណភាពមតកសាសន៍ នឹងមានអានុភាព។ ដូចនេះ មិនមានឱកាសសម្រាប់សួរពីឆន្ទៈពិត ឬប្រឆាំងចំពោះម្ចាស់បណ្តាំបាននោះទេ។ ជាក់ស្តែងក៏មានករណីខ្លះ តតិយជនអាចបង្កើតមតកសាសន៍ក្លែងក្លាយបានផងដែរ ឬ ខ្លឹមសារពិតរបស់មតកសាសន៍ត្រូវបានតតិយជននោះកែប្រែ។

ដូច្នេះហើយ ដើម្បីធ្វើឱ្យឆន្ទៈរបស់ម្ចាស់បណ្តាំមានភាពច្បាស់លាស់ និងដើម្បីការពារមិនឱ្យមានអ្នកក្លែងបន្លំ ឬ កែប្រែមតកសាសន៍ ក្រមរដ្ឋប្បវេណីបានចែងយ៉ាងលំអិតអំពីទម្រង់មតកសាសន៍ ហើយប្រសិនបើមិនអនុវត្តតាមទម្រង់នោះទេ មតកសាសន៍នោះនឹងត្រូវចាត់ទុកជាមោឃៈ។

## ផ្នែកទី ២. លក្ខខណ្ឌគ្រឹះនៃការធ្វើសន្តតិកម្មតាមមតកសាសន៍

មតកសាសន៍ ត្រូវបានធ្វើឡើងដោយសកម្មភាពឯកតោភាគី ដោយគ្រាន់តែមានការបង្ហាញឆន្ទៈរបស់ម្ចាស់បណ្តាំតែប៉ុណ្ណោះ មិនចាំបាច់មានការឯកភាពពីអ្នកទទួលមត៌កទេ។ ប៉ុន្តែទោះបីជាបានកំណត់បែបនេះក៏ដោយ ម្ចាស់បណ្តាំត្រូវមានលក្ខណៈគ្រប់គ្រាន់ និងមានសមត្ថភាពពេញលេញក្នុងការធ្វើមតកសាសន៍ត្រឹមត្រូវស្របតាមច្បាប់ ព្រមទាំងបង្ហាញឆន្ទៈត្រឹមត្រូវដោយការសម្រេចចិត្តរបស់ខ្លួន និងគ្មានវិការៈណាមួយកើតឡើងដើម្បីឱ្យមតកសាសន៍មានសុពលភាពតាមផ្លូវច្បាប់។

### កថាភាគទី ១. សមត្ថភាពក្នុងការធ្វើមតកសាសន៍

ម្ចាស់បណ្តាំធ្វើបណ្តាំ ក្នុងគោលបំណងសម្តែងនូវការសម្រេចចិត្តចុងក្រោយរបស់ខ្លួនដើម្បីផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនឱ្យទៅសន្តតិជន និងដើម្បីកុំឱ្យកើតមានជម្លោះរវាងសហសន្តតិជន នៅមុនពេលខ្លួនទទួលមរណភាព។ ដូច្នេះ ការកំណត់សមត្ថភាពខាងឆន្ទៈនៅពេលធ្វើមតកសាសន៍ជារឿងសំខាន់ ប្រសិនបើពុំដូច្នេះទេ មតកសាសន៍នឹងមិនមានសុពលភាពឡើយ ជាហេតុនាំឱ្យពុំអាចសម្រេចតាមឆន្ទៈរបស់ម្ចាស់បណ្តាំបានទេ។

មុនធ្វើបណ្តាំមត៌ក ម្ចាស់បណ្តាំត្រូវតែមានសមត្ថភាពនៅពេលធ្វើមតកសាសន៍[9]។ នៅក្នុងឃ្លានេះផងដែរ សំដៅទៅលើសមត្ថភាពខាងឆន្ទៈ ដែលមុនពេលដែលធ្វើមតកសាសន៍ (បណ្តាំ) បុគ្គលត្រូវតែមានសមត្ថភាពអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន បើមិនដូច្នោះទេ សកម្មភាពនោះនឹងត្រូវបានលុបចោល ឬមិនមានអានុភាព។ នៅក្នុងករណីដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍ក្នុងស្ថានភាពបាត់បង់ស្មារតីដោយសារគ្រឿងស្រវឹង ចាស់វង្វេងស្មារតីជាអាទិ៍ នោះមតកសាសន៍នឹងត្រូវចាត់ទុកជាមោឃៈ។ ម្យ៉ាងវិញទៀត ចំពោះបុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់អំពីហេតុនោះផង[10]។

[8] មាត្រា ១១៧០.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[9] មាត្រា ១១៦៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[10] មាត្រា១១៦៩.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន ត្រូវបានលុបចោល។ ទោះបីមិនមែនជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក៏ដោយ ក៏អាចលុបចោលសកម្មភាពដែលបានធ្វើឡើងក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពដែលខ្លួនបានធ្វើផងដែរ។ ដូច្នេះគួរចៀសវាងបញ្ហាទាំងនេះបានកើតឡើង ក្នុងករណីការតាក់តែងលិខិតមតកសាសន៍ ព្រមទាំងកិច្ចគតិយុត្តណាមួយផងដែរ។

**ឧទាហរណ៍៖** លោក (ក) ជានីតិជន ក្នុងពេលធ្វើមតកសាសន៍ លោក (ក) ស្ថិតក្នុងស្ថានភាពស្រវឹងជោគជាំ។ ករណីនេះដែលជាហេតុនាំឱ្យមតកសាសន៍ដែលបានធ្វើដោយ លោក (ក) មិនមានអានុភាពនោះទេ។ លោក (ក) ខ្លួនឯងអាចស្នើសុំមោឃភាពមតកសាសន៍ដែលខ្លួនបានធ្វើ ដោយលើកឡើងអំពីកង្វះសមត្ថភាពខាងឆន្ទៈដែលអាចបណ្តាលឱ្យគាត់អាចនឹងបាត់បង់នូវផលប្រយោជន៍ចំពោះសកម្មភាពដែលគាត់បានធ្វើ។

## កថាភាគទី ២. បុគ្គលដែលអាចធ្វើមតកសាសន៍បាន

បុគ្គលដែលអាចធ្វើមតកសាសន៍បានសំដៅទៅលើបុគ្គលទាំងឡាយដែលច្បាប់បានកំណត់យ៉ាងច្បាស់ថាមានលក្ខណៈសម្បត្តិដែលអាចធ្វើមតកសាសន៍បាន ដែលខុសពីបុគ្គលមួយចំនួនដែលមានលក្ខណៈសម្បត្តិអាចធ្វើមតកសាសន៍បាន។ លើសពីនេះ អនីតិជនដែលទទួលបានអត្ថាធីនភាពរួចផុតពីអាណាព្យាបាល ឬអំណាចមេបា ក៏អាចធ្វើមតកសាសន៍បានដែរ[11]។

### ១. នីតិជន

នីតិជន គឺជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើង[12]។ ជនដែលពេញវ័យ ឬអាចនិយាយបានថានីតិភាព ច្បាប់បានបញ្ញត្តិផ្តល់សិទ្ធិពេញលេញដល់បុគ្គលនោះក្នុងការធ្វើមតកសាសន៍។ សម្រាប់មតកសាសន៍មានលក្ខណៈខុសប្លែកពីសកម្មភាពផ្សេង ទោះបីនីតិជនជាជនស្ថិតនៅក្រោមហិតូបត្ថម្ភ ឬ ជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏អាចធ្វើមតកសាសន៍បានដែរ។ ប៉ុន្តែចំពោះការធ្វើមតកសាសន៍ដោយជននៅក្រោមអាណាព្យាបាលទូទៅ ចាំបាច់ត្រូវមានសមត្ថភាពខាងឆន្ទៈ ដោយខ្លួនបានជាសះស្បើយមួយរយៈពេលឡើងវិញនូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន និងមានការបញ្ជាក់ត្រឹមត្រូវពីវេជ្ជបណ្ឌិត[13]។ លើសពីនេះទៅទៀត សកម្មភាពក្នុងការធ្វើមតកសាសន៍ ដែលបានធ្វើឡើងដោយជន

[11] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨-ទី៩ រៀបចំដោយគណៈកម្មាធិការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ភ្នំពេញ ២០១០

[12] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧។

[13] មាត្រា១១៧៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

នៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ នោះអ្នកអាណាព្យាបាលទូទៅ និងហិតូបត្ថម្ភកៈ មិនអាចលុបចោលមតកសាសន៍នោះបានទេ[14]។

### ២. អនីតិជនដែលទទួលបានអត្តាធីនភាព

អនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវចាត់ទុកថា បានដល់នីតិភាព[15]។ ករណីដែលអនីតិជនដែលមានអាយុ១៦ឆ្នាំ ដោយអាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពតាមការស្នើសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ។ មួយវិញទៀត អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ក៏ត្រូវទទួលបានអត្តាធីនភាពផងដែរ (ទោះបីភាគីណាម្នាក់បានលែងលះក៏អានុភាពនៃអត្តាធីនភាពនូវតែមាន)។

ក្នុងករណីដែលអនីតិជនដែលទទួលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបា តាមរយៈការប្រកាសរបស់តុលាការក្តី តាមការរៀបអាពាហ៍ពិពាហ៍ ត្រូវបានចាត់ទុកថា បុគ្គលនោះពេញវ័យនីតិភាព។ ហេតុនេះ អនីតិជនដែលត្រូវបានទទួលអត្តាធីនភាព អាចធ្វើសកម្មភាពផ្សេងៗរួមទាំងមតកសាសន៍ បានពេញលេញដូចនីតិជនផងដែរ។

## ផ្នែកទី ៣. ប្រភេទនៃទម្រង់សន្តតិកម្មតាមមតកសាសន៍

### កថាភាគទី ១. ទម្រង់នៃមតកសាសន៍ក្នុងស្ថានភាពទូទៅ

ទម្រង់មតកសាសន៍ធម្មតាត្រូវបានបែងចែកជា ៣(បី)ទម្រង់ ដូចខាងក្រោម៖ (១) មតកសាសន៍ដែលជាលិខិតឯកជន (២) មតកសាសន៍ដែលជាលិខិតយថាភូត និង (៣) លិខិតមតកសាសន៍ដែលជាលិខិតសម្ងាត់។

មតកសាសន៍ ត្រូវធ្វើឡើងតាមទម្រង់ដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ប្រសិនបើមិនគោរពទម្រង់ទេ ត្រូវចាត់ទុកជាមោឃៈ។ ដោយឡែក មតកសាសន៍ដែលមិនបានចុះកាលបរិច្ឆេទ ត្រូវចាត់ទុកថាមានសុពលភាព បើមិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលធ្វើឡើងដោយម្ចាស់បណ្តាំដូចគ្នា។ បើមតកសាសន៍ដែលគ្មានចុះកាលបរិច្ឆេទនោះមានចំនួនច្រើនច្បាប់ និងមតកសាសន៍នោះផ្ទុយគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក។ លើសពីនេះទៅទៀត រាល់ទម្រង់មតកសាសន៍ទាំងអស់ គឺត្រូវមានសាក្សី២រូបយ៉ាងតិច លើកលែងតែទម្រង់លិខិតឯកជនដែលមិនទាមទារសាក្សី។

### ១. មតកសាសន៍ដោយលិខិតឯកជន

មតកសាសន៍ដោយលិខិតឯកជន ជាលិខិតមតកសាសន៍ដែលម្ចាស់បណ្តាំជាអ្នកសរសេរផ្ទាល់នូវខ្លឹមសារ ពាក្យពេចន៍ទាំងអស់នៃការបែងចែងមត៌ក ព្រមទាំងចុះថ្ងៃខែឆ្នាំ និងហត្ថលេខាដោយសាមីខ្លួនផ្ទាល់។

---

[14] មាត្រា១១៦៨.២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[15] មើលមាត្រា ២២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

លើសពីនេះលិខិតមតកសាសន៍ ដែលធ្វើឡើងដោយឱ្យតតិយជនជាអ្នកសរសេរជំនួស ឬដោយការវាយដោយម៉ាស៊ីន (កុំព្យូទ័រ) ជំនួសឱ្យការសរសេរដោយដៃ ត្រូវចាត់ទុកថាមោឃៈនៃលិខិតមតកសាសន៍នោះ។ ម្យ៉ាងវិញទៀត ក្នុងករណីម្ចាស់បណ្តាំចង់សរសេរបន្ថែមនូវខ្លឹមសារ ការផ្លាស់ប្តូរចំណុចណាមួយ ឬការកោសលុប ម្ចាស់បណ្តាំត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នូវការផ្លាស់ប្តូរនោះ ហើយចាំបាច់ត្រូវចុះហត្ថលេខា ដើម្បីជាការផ្ទៀងផ្ទាត់លិខិតបណ្តាំ និងលិខិតផ្សេងទៀតដែលមានហត្ថលេខារបស់សាមីខ្លួនដើម្បីបញ្ជាក់ ក្នុងករណីដែលជនណាម្នាក់ ឬតតិយជនធ្វើការក្លែងបន្លំខ្លឹមសារនៃលិខិតបណ្តាំនោះ។

### ក. អត្ថប្រយោជន៍

- ម្ចាស់បណ្តាំ អាចធ្វើតែឯងបាន ដោយមិនចាំបាច់មានអន្តរាគមន៍ពីសារការី ឬវត្តមានរបស់សាក្សី
- មិនអស់សោហ៊ុយ
- អាចរក្សាការសម្ងាត់នៃខ្លឹមសារនៃមតកសាសន៍[16]។

### ខ. គុណវិបត្តិ

• មតកសាសន៍នឹងត្រូវមោឃៈដោយសារកំហុសនៃទម្រង់ ដោយសារតែ មានការទាមទារឱ្យគោរពទម្រង់តឹងរឹង ហើយសារការីមិនបានចូលរួមជួយ

• ប្រសិនបើ ម្ចាស់បណ្តាំមិនចេះសរសេរអក្សរទេ គាត់មិនអាចធ្វើមតកសាសន៍បានទេ ព្រោះខ្លឹមសារនៃមតកសាសន៍មិនអាចសរសេរដោយអ្នកផ្សេងនោះទេ ហើយម្ចាស់បណ្តាំក៏មិនត្រូវបានអនុញ្ញាតឱ្យប្រើកុំព្យូទ័រសម្រាប់ធ្វើមតកសាសន៍ផងដែរ[17]

• អាចបាត់ ឬមានការធ្វើក្លែងក្លាយ ឬក្លែងបន្លំ ព្រោះម្ចាស់បណ្តាំជាអ្នករក្សាមតកសាសន៍

• ចាំបាច់ត្រូវមានអ្នកពិនិត្យបញ្ជាក់ដើម្បីអនុវត្តមតកសាសន៍[18]។

## ២. មតកសាសន៍ដោយលិខិតយថាភូត

លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) នៃក្រមរដ្ឋប្បវេណីសំដៅលើលិខិតដែលត្រូវបានធ្វើឡើងដោយសារការី[19]។ បើធៀបជាមួយលិខិតឯកជន គឺមានលក្ខណៈប្រសើរជាងដោយសារតែសារការី ជួយផ្តល់ប្រឹក្សាពីចំណុចសំខាន់ៗនៅក្នុងមតកសាសន៍ជាពិសេសអាចជួយស្វែង

---

[16] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣ រៀបរៀងដោយ ក្រុមការងារគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម បោះពុម្ពលើកទី១ រាជធានីភ្នំពេញ ខែ មីនា ឆ្នាំ ២០១៧ ទំព័រ៥២

[17] មាត្រា ១១៧៥.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[18] មាត្រា១២១៣.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[19] មាត្រា៩ ចំណុច គ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១

រកមធ្យោបាយស្របច្បាប់ ឱ្យមតកជនក្នុងការបែងចែកមត៌ក ឬអច្ច័យទានដោយធ្វើយ៉ាងណាកុំឱ្យប៉ះពាល់ដល់ភាគបម្រុង។ ជាពិសេស គឺទម្រង់មួយនេះ ពុំចាំបាច់ត្រូវឆ្លងកាត់តុលាការក្នុងការបើកបណ្ដាំមតកសាសន៍ឡើយ[20]។

ដើម្បីធ្វើមតកសាសន៍តាមទម្រង់លិខិតយថាភូតមានអានុភាព ត្រូវធ្វើឡើងដោយម្ចាស់បណ្ដាំនៅចំពោះមុខសារការី វត្តមានរបស់សាក្សី យ៉ាងតិច ០២ (ពីរ) នាក់ ហើយម្ចាស់បណ្ដាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារមតកសាសន៍ ចំពោះមុខសារការី។ បន្ទាប់មកសារការីត្រូវសរសេរអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្ដាំជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្ដាំ និងសាក្សីស្ដាប់។ លើសពីនេះ ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវចំពោះខ្លឹមសារនៃមតកសាសន៍ ម្ចាស់បណ្ដាំ និងសាក្សីត្រូវចុះហត្ថលេខា ហើយត្រូវបញ្ជាក់ពីឈ្មោះ អាយុ និងលំនៅឋាន ប៉ុន្តែបើម្ចាស់បណ្ដាំមិនចេះសរសេរអក្សរ ឬមិនអាចចុះហត្ថលេខាបាន សារការីអាចធ្វើជំនួស ដោយបញ្ជាក់អំពីហេតុនោះ។ ចុងក្រោយសារការីត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាមុនធ្វើការរក្សាទុក។

### ក. អត្ថប្រយោជន៍

- ខ្លឹមសារនៃមតកសាសន៍មានភាពច្បាស់លាស់ និងមានភាពជឿជាក់ខ្ពស់ដោយបានធ្វើឡើងដោយសារការី មានភាគរយតិចតួចណាស់ ឬស្ទើរតែមិនអាចក្លាយទៅជាកម្មវត្ថុនៃមោឃភាពដោយសារតែភាពមិនច្បាស់លាស់តាមផ្លូវច្បាប់នោះទេ
- មតកសាសន៍មានលក្ខណៈគតិយុត្ត ដោយសារសារការី (មន្ត្រីសាធារណៈ) ជាអ្នកជួយបង្កើតមតកសាសន៍
- ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ មានភាពជឿជាក់ និងទុកចិត្តលើមតកសាសន៍ ពីព្រោះសារការីចូលរួមក្នុងនីតិវិធីនៃការធ្វើមតកសាសន៍ ហើយជាអ្នករក្សាទុកមតកសាសន៍នោះ
- អ្នកមិនចេះអក្សរក៏អាចធ្វើមតកសាសន៍បានដែរ ពីព្រោះសារការី គឺជាអ្នកសរសេរខ្លឹមសាររបស់មតកសាសន៍
- មតកសាសន៍មិនត្រូវបានក្លែងបន្លំ ឬ ផ្លាស់ប្ដូរ ឬ បាត់បង់ ពីព្រោះសារការីជាអ្នករក្សាទុកមតកសាសន៍
- ជាពិសេសនៅពេលត្រូវអនុវត្តមតកសាសន៍ ដើរតួនាទីជាបន្ទាល់ដ៏រឹងមាំដែលអាចជឿទុកចិត្តបានចំពោះគ្រប់ភាគីទាំងអស់ រួមទាំងតុលាការផងដែរ ក្នុងករណីដែលមានវិវាទកើតឡើង
- អាចត្រូវបានបើកនៅក្រៅតុលាការបាន ដែលមតកសាសន៍មានទម្រង់ផ្សេងពុំអាចបើកនៅក្រៅតុលាការបាននោះទេ[21]។

### ខ. គុណវិបត្តិ

- ម្ចាស់បណ្ដាំត្រូវស្នើសុំឱ្យសារការីជួយ និងចំណាយលើការបង់ថ្លៃធ្វើមតកសាសន៍ចំពោះសារការី
- តម្រូវមានសាក្សី២នាក់

[20] សៀវភៅជំនួយស្មារតី នីតិបេតិកភណ្ឌ និងគ្រួសារ បណ្ឌិត ព្រំ វិទ្ធី បោះពុម្ពលើកទី១ ទំព័រ១២៨
[21] មាត្រា១២១៣.២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

• សារការី និងសាក្សីបានដឹងខ្លឹមសារក្នុងមតកសាសន៍។

### ៣. មតកសាសន៍ដោយលិខិតសម្ងាត់

ក្នុងការរក្សាខ្លឹមសារមតកសាសន៍ជាសម្ងាត់ ក្រៅពីការធ្វើមតកសាសន៍ជាលិខិតឯកជន ម្ចាស់បណ្តាំក៏អាចធ្វើមតកសាសន៍ជាលិខិតសម្ងាត់ផងដែរ។ ការតាក់តែងមតកសាសន៍ដោយលិខិតសម្ងាត់ មិនខុសពីមតកសាសន៍ប្រភេទផ្សេងទៀតនោះទេ ពោលគឺត្រូវធ្វើឡើងដោយគោរពតាមទម្រង់ដែលកំណត់ដោយច្បាប់ បើមិនដូច្នេះទេ មតកសាសន៍នោះ នឹងត្រូវចាត់ទុកជាមោឃៈ។ មតកសាសន៍ជាលិខិតសម្ងាត់ គឺជាលិខិតមួយប្រភេទដែលសារការីជាអ្នកបញ្ជាក់ថាមានលិខិតបណ្តាំរបស់មតកជនយ៉ាងពិតប្រាកដ ហើយខ្លឹមសារនៅក្នុងលិខិតបណ្តាំត្រូវបានរក្សាទុកជាការសម្ងាត់។ ម្យ៉ាងវិញទៀត មតកសាសន៍ជាលិខិតសម្ងាត់នេះទៀតសោត ម្ចាស់បណ្តាំអាចសរសេរដោយខ្លួនឯង ឬស្នើសុំឱ្យនរណាម្នាក់ជាអ្នកសរសេរខ្លឹមសារក្នុងលិខិតមតកសាសន៍បាន។ មតកសាសន៍ជាលិខិតសម្ងាត់ត្រូវធ្វើឡើងដោយយោងតាមទម្រង់ដែលបានកំណត់ដូចខាងក្រោមនេះ[22]៖

• ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាដោយផ្ទាល់លើលិខិតនោះ

• ម្ចាស់បណ្តាំត្រូវដាក់លិខិតមតកសាសន៍នោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬសរសេរសញ្ញាសម្គាល់ ឬប្រើប្រាស់មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬមិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ។

• ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និងសាក្សី ២ (ពីរ) នាក់ និងធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ។

• សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ជាមួយនឹងសាក្សី និងម្ចាស់បណ្តាំ។

#### ក. អត្ថប្រយោជន៍

• ទោះបីមិនចេះសរសេរអក្សរ ក៏អាចធ្វើបានដែរ ព្រោះគាត់អាចស្នើឱ្យនរណាម្នាក់សរសេរខ្លឹមសារ ឬប្រើប្រាស់កុំព្យូទ័រ

• អាចការពារការធ្វើក្លែងក្លាយ ឬ ក្លែងបន្លំ ឬ ផ្លាស់ប្តូរ ព្រោះមតកសាសន៍ត្រូវបានរក្សាក្នុងស្រោមសំបុត្របិទជិត

[22] មាត្រា១១៧៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

• អាចរក្សាការសម្ងាត់អំពីខ្លឹមសារនៃមតកសាសន៍បាន ព្រោះមតកសាសន៍ត្រូវបានរក្សាក្នុងស្រោមសំបុត្របិទជិត។

### ខ. គុណវិបត្តិ

• ចាំបាច់មានអន្តរាគមន៍ពីសារការី

• តម្រូវឱ្យមានសាក្សី២រូប

• វាអាចជួបប្រទះ នឹងហានិភ័យនៃការពុំត្រូវបានគេរកឃើញ

• ចាំបាច់ធ្វើការពិនិត្យបញ្ជាក់ ពេលអនុវត្តមតកសាសន៍[23]។

## កថាភាគទី ២. ទម្រង់នៃមតកសាសន៍ក្នុងស្ថានភាពពិសេស

ក្នុងការរស់នៅជីវភាពប្រចាំថ្ងៃក្នុងសង្គម យើងអាចនឹងមានការជួបឧប្បត្តិហេតុកើតមានដោយចៃដន្យគ្រប់ពេលវាលា និងទីកន្លែងដោយពុំមានការត្រៀមទុកជាមុនដែលអាចឈានទៅរកក្នុងស្ថានភាពបាត់បង់ជីវិត។ ដោយសង្កេតឃើញអំពីហេតុការណ៍ទាំងអស់នេះហើយបានជាច្បាប់ផ្តល់នូវវិធីក្នុងការតាក់តែងមតកសាសន៍តាមវិធីពិសេសនេះ ក្នុងគោលបំណងដើម្បីឱ្យមាននូវនីតិវិធីងាយស្រួល និងភាពបត់បែនស្របទៅតាមស្ថានភាពដែលមិនអាចដឹងមុនជាយថាហេតុ ក៏ដូចជាហេតុការណ៍បានកើតឡើងភ្លាមៗដល់ម្ចាស់បណ្តាំដែលទទួលរងគ្រោះថ្នាក់ ឬអាចនឹងទទួលគ្រោះថ្នាក់ ហើយបណ្តាលអោយបុគ្គលនោះបាត់បង់អាយុជីវិត ឬធ្វើអោយប៉ះពាល់ដល់សមត្ថភាព ឬពេលវេលាគ្រប់គ្រាន់ ក្នុងការធ្វើមតកសាសន៍តាមវិធីធម្មតា។

### ១. មតកសាសន៍បុគ្គលដែលស្ថិតក្រោមអាណាព្យាបាលទូទៅ

ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ជាជនដែលស្ថិតក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកស្មារតី[24]។ ម្យ៉ាងវិញទៀត ជននេះក៏ត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផងដែរ[25]។ ក្នុងន័យនេះសំដៅដល់ ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅនេះ មិនអាចធ្វើសកម្មភាពបានទេ ទោះបីជាសកម្មភាពឯកតោភាគី ឬកិច្ចសន្យា។ រាល់ការធ្វើសកម្មភាព ត្រូវធ្វើឡើងដោយមានការយល់ព្រមពី អ្នកអាណាព្យាបាលទូទៅ បើមិនដូច្នេះទេ សកម្មភាពដែលបានធ្វើអាចលុបចោលបាន។

[23] មាត្រា១២១៣.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[24] មាត្រា២៤.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[25] មាត្រា១៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ចំពោះការធ្វើមតកសាសន៍វិញច្បាប់បានបញ្ញត្តិ សម្រាប់ម្ចាស់បណ្តាំជាជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ អាចធ្វើធ្វើមតកសាសន៍បានមិនចាំបាច់មានការអនុញ្ញាតពីអ្នកអាណាព្យាបាលទូទៅនោះឡើយ ក្នុងករណី (១) ម្ចាស់បណ្តាំបានជាសះស្បើយពីជម្ងឺក្នុងកម្រិតណាមួយ និង (២) វត្តមានវេជ្ជបណ្ឌិត។

ក្នុងន័យម្ចាស់បណ្តាំបានជាសះស្បើយពីជម្ងឺក្នុងកម្រិតណាមួយសំដៅដល់ស្ថានភាពដែលម្ចាស់បណ្តាំមានស្មារតី ដឹងខុសត្រូវ ដឹងច្បាស់ពីសកម្មភាព និងដោយត្រូវមានការវិនិច្ឆ័យរបស់វេជ្ជបណ្ឌិតដែលមានជំនាញ។

មួយវិញទៀត វត្តមានរបស់វេជ្ជបណ្ឌិត នៅពេលម្ចាស់បណ្តាំធ្វើមតកសាសន៍។ វេជ្ជបណ្ឌិតត្រូវវាយតម្លៃ និងពិនិត្យឱ្យបានច្បាស់លាស់លើស្ថានភាពរបស់ម្ចាស់បណ្តាំ ព្រោះថាមតកសាសន៍នៃជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ វេជ្ជបណ្ឌិតត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍ថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍ ម្ចាស់បណ្តាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ម្ចាស់បណ្តាំ ដោយសារមានវិបត្តិស្មារតីទេ។

## ២. មតកសាសន៍បុគ្គលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

ក្នុងករណីមានជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀតមានចំណងចង់ធ្វើមតកសាសន៍ គឺអាចធ្វើទៅតាមដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ។ ជនដែលត្រូវបានប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្តាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះត្រូវចុះហត្ថលេខាលើលិខិតនោះ[26]។

- ការតាក់តែងមតកសាសន៍របស់ជនដែលជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតត្រូវធ្វើឡើងតាមដំណាក់កាលដូចខាងក្រោមនេះ ៖
    - ✓ ជាដំបូងត្រូវស្វែងរកសាក្សី៣នាក់
    - ✓ បន្ទាប់មកមតកជនប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់
    - ✓ សាក្សីម្នាក់ក្នុងចំណោម ៣នាក់ ជាអ្នកកត់ត្រានូវខ្លឹមសារនៃមតកសាសន៍
    - ✓ ចុងក្រោយសាក្សីនីមួយៗធ្វើការពិនិត្យបញ្ជាក់ និងចុះហត្ថលេខា

[26] មាត្រា១១៧៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សាក្សីដែលបានចូលរួមនៅពេលធ្វើមតកសាសន៍ចំពោះករណីជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ត្រូវតែជាជនដែលមានលក្ខណៈសម្បត្តិក្លាយជាសាក្សី តាមបញ្ញត្តិមាត្រា ១១៧២ នៃក្រមរដ្ឋប្បវេណីដែលចែងអំពីលក្ខខណ្ឌ និង សមាសភាពដែលអាចក្លាយជាសាក្សីផងដែរ។

លើសពីនេះទៅទៀត មតកសាសន៍របស់ជនដែលជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត នឹងលែងមានអានុភាពកាលបើសាក្សីណាម្នាក់ ឬ អ្នកពាក់ព័ន្ធនូវផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការនៅក្នុងកំឡុងពេល ១ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍ ហើយពុំទទួលបានការបញ្ជាក់ពីតុលាការទេ។ តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។

### ៣. មតកសាសន៍បុគ្គលដែលត្រូវជាប់ឃុំឃាំង

ជនដែលត្រូវជាប់ឃុំឃាំង អាចធ្វើមតកសាសន៍បានដោយមានការអន្តរាគមន៍ពីមន្ត្រីពាក់ព័ន្ធ។ ជនដែលត្រូវជាប់ឃុំនេះ ត្រូវបានច្បាប់កំណត់ដោយញែកជាពីរករណីដូចជា បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក និង បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ។

ចំពោះបុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយការចេញសេចក្តីសម្រេច សាលក្រម ឬសាលដីកា អាចធ្វើមតកសាសន៍បាន ដោយត្រូវអោយមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច២នាក់។ ចំណែកឯបុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវអោយមានវត្តមានរបស់មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និង សាក្សីយ៉ាងតិច២នាក់ [27] ។ ការតាក់តែងមតកសាសន៍ទម្រង់នេះ ត្រូវអនុវត្តប្រហាក់ប្រហែលនឹងដំណើរការតាក់តែងមតកសាសន៍ដោយលិខិតយថាភូតដែរ ដោយគ្រាន់តែលិខិតយថាភូតមានការអន្តរាគមន៍ពីសារការី ចំណែកមតកសាសន៍របស់ជនដែលជាប់ឃុំមានអន្តរាគមន៍ពីមន្ត្រីពាក់ព័ន្ធ ប៉ុន្តែមតកសាសន៍របស់ជនដែលត្រូវជាប់ឃុំឃាំងនេះ មិនមានសុពលភាពដូចលិខិតយថាភូតនោះទេ។

➢ ការតាក់តែងមតកសាសន៍របស់ជនដែលត្រូវជាប់ឃុំត្រូវធ្វើឡើងតាមដំណាក់កាលដូចខាងក្រោម ៖

✓ ត្រូវមានវត្តមានសាក្សីយ៉ាងតិច ២ (ពីរ) នាក់

✓ ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះនគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ ករណីជាជនជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក និង ចំពោះមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា យន្តហោះ ករណីជនជាប់នាវា ឬ យន្តហោះ។

[27] មាត្រា១១៧៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

✓ មន្ត្រីពាក់ព័ន្ធត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីនោះស្តាប់។

✓ បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សីបានបានទទួលស្គាល់ថាកំណត់ជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើអោយមានភាពច្បាស់លាស់នៅលើឯកសារអំពី ឈ្មោះ អាយុ និងលំនៅដ្ឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន។ ប៉ុន្តែបើម្ចាស់បណ្តាំមិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ មន្ត្រីពាក់ព័ន្ធអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅដ្ឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវមូលហេតុនោះផងដែរ។

✓ មន្ត្រីពាក់ព័ន្ធត្រូវសរសេរថ្ងៃខែឆ្នាំ ហើយចុះហត្ថលេខា។

ម្ចាស់បណ្តាំដែលកំពុងជាប់ឃុំឃាំងអាចធ្វើមតកសាសន៍បាន ដោយត្រូវមានវត្តមានចូលរួមរបស់នគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និងសាក្សីយ៉ាងតិច ២ (ពីរ) នាក់។ ជនដែលត្រូវជាប់ឃុំឃាំង ដោយការចេញសេចក្តីសម្រេច សាលក្រម ឬសាលដីកា ក្រៅពីការធ្វើលិខិតមតកសាសន៍ដោយលិខិតឯកជន ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ក្នុងទម្រង់ពិសេសមួយផ្សេងទៀត ដែលច្បាប់បានកំណត់ទម្រង់ចំពោះជនដែលបានជាប់ឃុំឃាំង។

មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំឃាំងនឹងអស់សុពលភាព កាលបើម្ចាស់បណ្តាំបន្តនៅរស់ក្រោយអំឡុងពេល ៦ (ប្រាំមួយ) ខែ ដោយរាប់ចាប់ពីថ្ងៃដែលបានធ្វើលិខិតមតកសាសន៍នោះ។ ច្បាប់បានកំណត់រយៈពេលអានុភាពនៃមតកសាសន៍ប្រភេទនេះ ក៏ព្រោះតែមតកសាសន៍តាមវិធីពិសេស មានគោលបំណងអនុវត្តតែក្នុងពេលស្ថានភាពបន្ទាន់ប៉ុណ្ណោះ។

### ៤. មតកសាសន៍បុគ្គលដែលមិនអាចនិយាយបាន ឬស្តាប់បាន

ក្នុងករណីម្ចាស់បណ្តាំ បានស្ថិតនៅក្នុងស្ថានភាពដែលមិនអាចនិយាយបាន ឬ មិនអាចស្តាប់បាន ដោយមូលហេតុនៃជម្ងឺ ឬ មូលហេតុផ្សេងទៀត ប៉ុន្តែម្ចាស់បណ្តាំមានបំណងធ្វើមតកសាសន៍ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ បានដោយត្រូវបំពេញលក្ខខណ្ឌទម្រង់ដែលច្បាប់បានបញ្ញត្តិពិសេសចំពោះហេតុនីមួយៗ ចំពោះម្ចាស់បណ្តាំជាជនដែលមិនអាចនិយាយបាន និង ចំពោះម្ចាស់បណ្តាំ និងសាក្សី ជាជនដែលមិនអាចស្តាប់បាន។

#### ❖ ចំពោះម្ចាស់បណ្តាំជាជនដែលមិនអាចនិយាយបាន

ចំពោះបុគ្គលដែលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់លិខិតយថាភូត និងលិខិតសម្ងាត់ ម្ចាស់បណ្តាំ អាចជំនួសការប្រាប់បាន ដោយត្រូវធ្វើសេចក្តីថ្លែងអំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងថាលិខិតដែលបានធ្វើនេះ និងដាក់ក្នុងស្រោមសំបុត្របិទជិតជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបក

ប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី[28]។ ករណីខាងលើនេះជាករណីពិសេស ដែលម្ចាស់បណ្ដាំ ជាបុគ្គលដែលមិនអាចនិយាយបាន ហើយម្ចាស់បណ្ដាំត្រូវបង្ហាញឆន្ទៈក្នុងការធ្វើមតកសាសន៍បាន ដោយត្រូវបានជំនួសឱ្យការថ្លែងដោយផ្ទាល់មាត់ មកជាការបកប្រែរបស់អ្នកបកប្រែវិញ។

មួយវិញទៀត ប្រសិនបើមានហេតុដូចនេះបានកើតឡើង សារការីជាអ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍ដោយលិខិតយថាភូត និងជាអ្នកទទួលបន្ទុកក្នុងការរក្សាមតកសាសន៍ដោយលិខិតសម្ងាត់ ជនទាំងនេះត្រូវសរសេរនូវហេតុដែលម្ចាស់បណ្ដាំ មិនអាចនិយាយបាន ព្រមទាំងការប្រើវិធីផ្សេងដើម្បីជំនួសការថ្លែងការណ៍ផ្ទាល់មាត់ក្នុងការតាក់តែងលិខិតក្នុងស្ថានភាពបែបនេះ។

❖ **ចំពោះម្ចាស់បណ្ដាំជាជនដែលមិនអាចស្ដាប់បាន**

បើក្នុងករណី ម្ចាស់បណ្ដាំ និងសាក្សីជាមនុស្សថ្លង់មិនអាចស្ដាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតអាចជំនួសការអានឱ្យស្ដាប់ ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរ តាមការបកប្រែ ទៅម្ចាស់បណ្ដាំ ឬ សាក្សី[29]។ ទោះបីម្ចាស់បណ្ដាំមានបំណងធ្វើមតកសាសន៍ តាមទម្រង់ណាមួយដែលច្បាប់បានកំណត់ ដែលតម្រូវឱ្យមានការអាន ឬ សូត្រឡើងវិញនូវខ្លឹមសារនៃមតកសាសន៍ដែលសារការី ឬ បុគ្គលផ្សេងទៀត ដែលបានសរសេរតាមសម្ដីរបស់ម្ចាស់បណ្ដាំ ហើយម្ចាស់បណ្ដាំ និងសាក្សី បែរជាមនុស្សថ្លង់មិនស្ដាប់បាន នោះត្រូវមានវត្តមានរបស់អ្នកបកប្រែម្នាក់ទៀត ដើម្បីចូលរួមបកប្រែនូវសម្ដីរបស់សារការី ឬ បុគ្គលផ្សេងទៀតដែលច្បាប់បានកំណត់ ជាភាសាកាយវិការឱ្យ ម្ចាស់បណ្ដាំ និងសាក្សី។ ក្នុងករណី សារការី ឬបុគ្គលផ្សេងទៀតដែលជាអ្នកទទួលបន្ទុកសរសេរមតកសាសន៍ ត្រូវសរសេរអំពីហេតុដែលម្ចាស់បណ្ដាំមិនអាចស្ដាប់បាន នៅក្នុងលិខិតមតកសាសន៍នោះ[30]។

# ផ្នែកទី ៤. ភាពចាំបាច់នៃការតាក់តែងលិខិតមតកសាសន៍

## កថាភាគទី ១. កាលបរិច្ឆេទ និងហត្ថលេខានៅក្នុងលិខិតមតកសាសន៍

រាល់លិខិតបទដ្ឋានគតិយុត្តទាំងអស់ត្រូវតែមាន កាលបរិច្ឆេទមួយច្បាស់លាស់ រួមទាំងលិខិតមតកសាសន៍ផងដែរ។ ការចុះកាលបរិច្ឆេទទៅលើលិខិតមតកសាសន៍ជាការចាំបាច់ដើម្បីបញ្ជាក់ពីសុពលភាពនៃមតកសាសន៍ ប៉ុន្តែករណីដែលលិខិតមតកសាសន៍ណាមួយ មិនបានចុះកាលបរិច្ឆេទ ដើម្បីធ្វើឱ្យលិខិតមតកសាសន៍នោះអាចមានសុពលភាពបាន លុះត្រាតែលិខិតមតកសាសន៍នោះមិនផ្ទុយ នឹងខ្លឹមសារនៃលិខិតមតកសាសន៍ផ្សេងទៀតដែលមានការចុះកាលបរិច្ឆេទ។ លើសពីនេះបើលិខិតមតកសាសន៍ណាមួយដែលមិនបានចុះ

[28] មាត្រា១១៧៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[29] មាត្រា១១៧៩.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[30] មាត្រា១១៧៩.៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

កាលបរិច្ឆេទច្បាស់លាស់ ហើយមានខ្លឹមសារផ្ទុយពីលិខិតមតកសាសន៍ដែលមានការចុះកាលបរិច្ឆេទ នោះលិខិតដែលមិនចុះកាលបរិច្ឆេទ នឹងត្រូវចាត់ទុកជាមោឃៈ។ មួយវិញទៀត ក្នុងករណីដែលមានលិខិតមតកសាសន៍ច្រើនមិនមានកាលបរិច្ឆេទ ហើយមានខ្លឹមសារផ្ទុយគ្នា នោះលិខិតមតកសាសន៍នឹងត្រូវធ្វើការកាត់បន្ថយគ្នាទៅវិញទៅមក[31]។

ចំពោះហត្ថលេខាវិញ មតកជនមិនត្រូវបានអនុញ្ញាតឱ្យផ្តិតមេដៃជំនួសឱ្យការចុះហត្ថលេខាទេ។ ដោយសារតែមានភាពចាំបាច់ត្រូវធ្វើការផ្ទៀងផ្ទាត់ មើលហត្ថលេខារបស់មតកជនទៅលើលិខិតផ្សេងៗដែលមតកជនធ្លាប់បានចុះហត្ថលេខា។ ការផ្តិតស្នាមម្រាមដៃ ធ្វើឱ្យពិបាកក្នុងការផ្ទៀងផ្ទាត់មើលពីភាពត្រឹមត្រូវនៃស្នាមម្រាមដៃរបស់មតកជន។ ប៉ុន្តែមតកសាសន៍នៅអាចប្រើប្រាស់ ការសរសេរនាមត្រកូល នាមខ្លួន និងការផ្តិតស្នាមម្រាមដៃមកប្រើប្រាស់ជំនួសការចុះហត្ថលេខាបាន ក្នុងករណីដែលមានវត្តមានសារការី និងសាក្សីបានចុះហត្ថលេខាបញ្ជាក់ពីការផ្តិតម្រាមដៃរបស់មតកជនដោយយោងតាមទំនៀមទំលាប (បវេណី) របស់ព្រះរាជាណាចក្រកម្ពុជា។

**កថាភាគទី ២. ការចូលរួមរបស់សាក្សីក្នុងពេលធ្វើមតកសាសន៍**

សាក្សី គឺជាបុគ្គលដែលជួយសម្រួលដល់ការបញ្ជាក់ពីភាពត្រឹមត្រូវរបស់លិខិតមតកសាសន៍តាមឆន្ទៈរបស់មតកជន និងមានសុពលភាពពេញលេញនៅក្នុងនីតិវិធីដែលច្បាប់បានកំណត់។ លើកលែងតែមតកសាសន៍ដែលធ្វើឡើងដោយទម្រង់លិខិតឯកជនមួយប៉ុណ្ណោះមិនទាមទារឱ្យមានការចូលរួមពីសាក្សី។ ចំពោះមតកសាសន៍ដោយលិខិតយថាភូត និងមតកសាសន៍ដោយលិខិតសម្ងាត់គឺតម្រូវឱ្យមានការចូលរួមផ្ទាល់ពីសាក្សីជាចាំបាច់។ ដូច្នេះសាក្សី គឺជាបុគ្គលដែលអាចធ្វើការបញ្ជាក់បានថាមតកសាសន៍ពិតជាបានធ្វើឡើងដោយឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំពិតប្រាកដមែន។ ក៏ប៉ុន្តែមិនមែនមានន័យថា គ្រប់បុគ្គលទាំងអស់សុទ្ធតែមានលក្ខណៈសម្បត្តិធ្វើជាសាក្សីនោះទេ ច្បាប់ក៏បានកំណត់រូបវន្តបុគ្គលមួយចំនួនដែលគ្មានលក្ខណៈសម្បត្តិធ្វើជាសាក្សីនៅក្នុងការតាក់តែងលិខិតមតកសាសន៍ បុគ្គលទាំងនោះរួមមាន៖

- អនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ៖ ចំពោះជនដែលមិនទានពេញវ័យនីតិភាព គឺអាយុចាប់ពី ១៨ឆ្នាំឡើង ឬជនដែលស្ថិតក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកស្មារតី ឬជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ឬមិនអាចចូលរួមធ្វើសាក្សី ក្នុងការធ្វើមតកសាសន៍បានទេ។ ករណីដែលជនទាំងនេះបានធ្វើសាក្សីចូលរួមក្នុងការតាក់តែងលិខិតមតកសាសន៍ នឹងធ្វើឱ្យបណ្តាំនោះមិនមានសមភាព កង្វះសមត្ថភាព និងបាត់បង់អានុភាព ដែលជាហេតុច្បាប់បានបញ្ញត្តិមិនឱ្យជនទាំងនោះធ្វើជាសាក្សី។

[31] មាត្រា១១៧០.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

• សន្តតិជន បុគ្គលដែលបានសន្មតថាជាសន្តតិជន ឬបុគ្គលដែលមានផលប្រយោជន៍ ក៏មិនអាចធ្វើជាសាក្សីក្នុងការតាក់តែងលិខិតមតកសាសន៍បានឡើយ។ ក្នុងនោះរួមមាន អច្ច័យលាភី សហព័ទ្ធរបស់ម្ចាស់បណ្តាំ ញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្តាំ និងជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងលិខិតមតកសាសន៍ផងដែរ គឺច្បាប់បានហាមឃាត់ក្នុងការចូលរួមធ្វើសាក្សីនៅពេលធ្វើបណ្តាំមត៌ក។

• សារការី ច្បាប់បានកំណត់នៅពេលដែលសារការីពាក់ព័ន្ធទៅលើការធ្វើមតកសាសន៍ គឺនាំឱ្យខ្វះលក្ខណៈសម្បត្តិជាសាក្សី នៅក្នុងទម្រង់លិខិតមតកសាសន៍ដោយលិខិតយថាភូត គឺម្ចាស់បណ្តាំប្រាប់ផ្ទាល់មាត់នូវខ្លឹមសារចំពោះចំពោះមុខសារការី ដែលជាអ្នកកត់ត្រាខ្លឹមសារទាំងមូលជាលាយលក្ខណ៍អក្សរ ជាហេតុសារការីមិនអាចចូលរួមធ្វើសាក្សីក្នុងការធ្វើមតកសាសន៍ដោយលិខិតយថាភូតបានទេ។ បើសារការីមានការចូលរួម គឺអាចនិយាយបានថាសារការីដើរតួនាទីពីរ (វិសមិតភាព) ជាអ្នកតាក់តែងនូវខ្លឹមសារផង និងជាសាក្សីផង ដូច្នេះករណីនេះមិនអាចឱ្យមានជាដាច់ខាត ព្រោះវានាំឱ្យមិនមានភាពត្រឹមត្រូវទៅតាមច្បាប់នោះទេ ឬបំពានច្បាប់ដែលជាហេតុនាំឱ្យមតកសាសន៍ដែលបានធ្វើឡើងនេះមិនមានអានុភាពគតិយុត្តនោះទេ។

មុននឹងបុគ្គលម្នាក់ អាចក្លាយជាសាក្សីក្នុងការចូលរួមធ្វើលិខិតមតកសាសន៍ បុគ្គលនោះត្រូវតែធ្វើការអះអាងនៅចំពោះមុខសារការីថាខ្លួនមិនបានជាប់ពាក់ព័ន្ធជាញាតិលោហិតខ្សែផ្ទាល់នឹងម្ចាស់បណ្តាំ ហើយយល់ព្រមផ្តល់ចម្លើយជូនសមត្ថកិច្ចមន្ត្រីពាក់ព័ន្ធនៅពេលដែលមានការអនុវត្តខ្លឹមសារនៃលិខិតមតកសាសន៍ ក៏ព្រោះតែសាក្សីមានតួនាទីក្នុងការអះអាងដឹងឮពីភាពត្រឹមត្រូវ ពេញលេញទៅលើសកម្មភាព និងសមត្ថភាពរបស់ម្ចាស់បណ្តាំនៅក្នុងពេលតាក់តែងលិខិតមតកសាសន៍។

## កថាភាគទី ៣. មុខងារ និងសារៈសំខាន់របស់សារការីក្នុងការធ្វើលិខិតមតកសាសន៍

ដោយបានបកស្រាយ ក៏ដូចជារៀបរាប់ខាងលើមកហើយ តាមច្បាប់កម្ពុជាសព្វថ្ងៃ មតកសាសន៍អាចធ្វើឡើងក្រោមបីទម្រង់គឺ មតកសាសន៍ដោយលិខិតឯកជន មតកសាសន៍ដោយលិខិតយថាភូត និងមតកសាសន៍ដោយលិខិតសម្ងាត់។ ដោយសារនៅពេលអនុវត្តលិខិតបណ្តាំនេះ ម្ចាស់បណ្តាំបានទទួលមរណភាពទៅហើយ ដែលនឹងមិនអាចមកអះអាងបញ្ជាក់អំពីខ្លឹមសារបណ្តាំរបស់ខ្លួនបានឡើយ ដូច្នេះមតកសាសន៍ដោយលិខិតយថាភូតដើរតួនាទីជាបន្ទាល់ដ៏រឹងមាំដែលអាចទុកចិត្ត និងជឿជាក់បាន ចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់រួមទាំងតុលាការផង នាពេលកើតមានវិវាទ។

### ១. មុខងាររបស់សារការីក្នុងការតាក់តែងលិខិតមតកសាសន៍

សារការីជាមន្ត្រីសាធារណៈដែលត្រូវបានតែងតាំងដោយអង្គការនីតិប្រតិបត្តិ ហើយទទួលបាន នូវសិទ្ធិអំណាចក្នុងការតាក់តែងលិខិតយថាភូត ធានាកាលបរិច្ឆេទ តម្កល់ និងចេញសេចក្តីចម្លងយថាភូតនៃលិខិត។ ទម្រង់មតកសាសន៍ដោយលិខិតយថាភូតដែលធ្វើឡើងដោយសារការីមានតម្លៃជាភស្តុតាងរឹងមាំ ដែលគេត្រូវជឿ

ទុកចិត្តថាត្រឹមត្រូវ លើកលែងតែមានភស្តុតាងបញ្ជាក់ពីការក្លែងបន្លំដោយសារការី។ មិនតែប៉ុណ្ណោះ លិខិតមតកសាសន៍ធ្វើឡើងដោយសារការី ជាលិខិតអនុវត្តដែលមានតម្លៃស្មើនឹងសាលក្រម ឬ សាលដីកាស្ថាពរ ក្នុងករណីពេលដែលបើកលិខិតមតកសាសន៍ដោយមិនតម្រូវឱ្យបើកនៅចំពោះមុខតុលាការនោះទេ។

នៅក្នុងដំណើរការតាក់តែងលិខិតយថាភូត សារការីមានកាតព្វកិច្ចក្នុងការប្រឹក្សា និងផ្តល់យោបល់ដល់មតកជនអំពីសិទ្ធិដែលខ្លួនមានដូចជា សិទ្ធិក្នុងការកំណត់ចំណែកមត៌ក សិទ្ធិក្នុងការផ្តាច់ចំណែកមត៌ក សិទ្ធិជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ និងសិទ្ធិក្នុងការផ្តល់អំណាចអាណាព្យាបាលរួមទាំងលទ្ធផលក្រោយការអនុវត្តលិខិតមតកសាសន៍។

សារការី មានកាតព្វកិច្ចរក្សាទុកនូវលិខិតមតកសាសន៍យ៉ាងហោចណាស់៤០ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃឯកសារ ឬថ្ងៃបញ្ចប់សំណុំរឿង[32]។

## ២. សារៈសំខាន់របស់សារការីក្នុងការតាក់តែងលិខិតមតកសាសន៍

តើហេតុអ្វីបានជាទម្រង់យថាភូតនៃមតកសាសន៍មានសារប្រយោជន៍ខ្ពស់? តើអន្តរាគមន៍របស់សារការីនៅក្នុងការតាក់តែងមតកសាសន៍អាចជាជំនួយពិសេសអ្វីខ្លះ?

មតកសាសន៍ដោយលិខិតយថាភូតត្រូវធ្វើឡើងដោយម្ចាស់បណ្តាំប្រាប់ផ្ទាល់មាត់នូវខ្លឹមសារ នៅចំពោះមុខសារការីដែលជាអ្នកកត់ត្រាខ្លឹមសារទាំងនោះជាលាយលក្ខណ៍អក្សរ។ មតកសាសន៍ ដែលធ្វើឡើងដោយសារការីដែលជាមន្ត្រីសាធារណៈ មានគុណប្រយោជន៍ពិសេសមួយចំនួនៈ

- ឆន្ទៈរបស់ម្ចាស់បណ្តាំមិនអាចជំទាស់ប្រឆាំងបានឡើយនៅក្រោយមរណភាពរបស់ខ្លួនៈ សារការីមានតួនាទីក្នុងការពិនិត្យពិច័យសមត្ថភាពក្នុងការធ្វើបណ្តាំ និងឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំព្រមទាំងអនុលោមភាពនៃទម្រង់ និងខ្លឹមសារនៃមតកសាសន៍ទៅតាមច្បាប់ផងដែរ។ ក្រោយពីបានសរសេររួចរាល់នូវខ្លឹមសារបណ្តាំ សារការីត្រូវសូត្រសេចក្តីនោះឱ្យម្ចាស់បណ្តាំ និងសាក្សីពីររូបទៀតស្តាប់ និងទទួលស្គាល់ជាលាយលក្ខណ៍អក្សរលើខ្លឹមសារនោះ។ ដូច្នេះ ភាពច្បាស់លាស់ និងត្រឹមត្រូវនឹងអាចត្រូវបានធានានៅក្នុងលក្ខខណ្ឌនេះ។

- ការរក្សាទុកនូវមតកសាសន៍ៈ សារការីដែលទទួលតាក់តែងមតកសាសន៍ មានកាតព្វកិច្ចរក្សាមតកសាសន៍នោះទុក សម្រាប់រយៈពេលយូរអង្វែង និងប្រកបដោយសុវត្ថិភាពខ្ពស់។ ដូច្នេះ ករណីនៃការក្លែងបន្លំ ឬការបាត់បង់នូវមតកសាសន៍ នឹងមិនអាចកើតមានឡើយ។

[32] មាត្រា១៤ ច្បាប់ស្តីពីបណ្ណាសារ ឆ្នាំ២០០៥

• ការអនុវត្តមតកសាសន៍ដោយលិខិតយថាភូតអាចធ្វើឡើងនៅក្រៅតុលាការៈ តាមច្បាប់កម្ពុជាបច្ចុប្បន្ន ក្រៅពីមតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ទាំងអស់ត្រូវមានការបញ្ជាក់លិខិតនោះ ដោយតុលាការជាមុនសិន នៅពេលចាប់ផ្តើមសន្តតិកម្ម។ ដោយឡែកមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការប៉ុណ្ណោះ ហើយបុគ្គលដែលបានលិខិតមតកសាសន៍ នៅក្រៅតុលាការ នឹងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១.០០០.០០០ (មួយលាន) រៀល។

## ផ្នែកទី ៥. ចំណុចនៃមតកសាសន៍

ចំណុចនៃមតកសាសន៍ គឺសំដៅដល់ខ្លឹមសារដែលមាននៅក្នុងមតកសាសន៍មួយ។ ក្រមរដ្ឋប្បវេណីបានកំណត់នូវចំណុចមួយចំនួន ដែលអាចត្រូវបានដាក់បញ្ចូលក្នុងមតកសាសន៍ ហេតុនេះក្នុងករណីដែលមតកជន ឬ ម្ចាស់បណ្តាំបានសរសេរចំណុចផ្សេងៗទៀតក្រៅពីចំណុចដែលច្បាប់បានកំណត់នោះចំណុចទាំងនេះនឹងពុំមានអានុភាពតាមផ្លូវច្បាប់ឡើយ។

### កថាភាគទី ១. ការកំណត់ចំណែកមត៌ក

មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍បាន ទោះបីជាផ្ទុយនឹងបញ្ញត្តិស្តីពីផលប្រយោជន៍ពិសេសក៏ដោយ លើកលែងតែការកំណត់ចំណែកមត៌កនោះបំពានភាគបម្រុង។ ផ្ទុយទៅវិញ បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬច្រើននាក់ ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវធ្វើឡើងតាមគោលការណ៍នៃការសម្រួលមត៌ក ហើយបើបំពានភាគបម្រុង ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

បុគ្គលណាម្នាក់ក្នុងចំណោមសហសន្តតិជនដែលបានទទួល ផលប្រយោជន៍ពិសេសដូចជា ការទទួលបានប្រទានកម្ម ឬអច្ច័យទានពីមតកជន (ឱកាសអាពាហ៍ពិពាហ៍ ឬការផ្តល់ដើមទុនក្នុងការរកស៊ី) ដោយមានការបង្ហាញឆន្ទៈត្រឹមត្រូវពេលធ្វើសកម្មភាពនោះ ជាហេតុនាំឱ្យតម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មដោយបូកបញ្ចូលនូវតម្លៃប្រទានកម្មត្រូវបានចាត់ទុកជាមត៌ក[33]។

បើប្រទានកម្ម ឬ អច្ច័យទានស្មើគ្នានឹងតម្លៃចំណែកមត៌ក ឬ លើសពីតម្លៃនៃចំណែកមត៌កទៀត សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កបានឡើយ[34]។ លើសពីនេះ ការកំណត់ចំណែកមត៌កនេះមិនអាចធ្វើការបំពានភាគបម្រុងបាននោះទេ ដោយត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង[35]។

[33] មាត្រា១១៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[34] មាត្រា១១៦៣.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[35] មាត្រា១១៨២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**កថាភាគទី ២. ការកំណត់វិធីបែងចែកដោយមតកសាសន៍**

មតកជនអាចកំណត់វិធីបែងចែកតាមមតកសាសន៍ ឬប្រគល់អាណត្តិឱ្យតតិយជនកំណត់ ឬអាចហាមឃាត់មិនឱ្យបែងចែក នៅអំឡុងពេលមិនលើសពី ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្ម[36]។

**ឧទាហរណ៍៖** មតកជន មានកូន ០៣នាក់ (ក,ខ និង គ) ដោយនៅក្នុងមតកសាសន៍នោះ កំណត់ជាក់លាក់ពីវត្ថុដែលជាចំណែករបស់កូននីមួយៗ ដោយនៅក្នុងមតកសាសន៍បានបញ្ជាក់ថា (ក) ជាអ្នកប្រតិបត្តិមតកសាសន៍ (កូនច្បង) ហើយត្រូវគ្រប់គ្រងទ្រព្យសម្បត្តិនេះរហូតដល់ប្អូនៗមាននីតិភាព ទើបធ្វើការបែកចែកចំណែកស្មើៗគ្នា ដែលមតកសាសន៍នេះមានអានុភាពនៅថ្ងៃទី ០១.០១.២០១០ ហើយប្អូនៗរបស់ (ក) នឹងពេញវ័យនីតិភាពទាំងអស់គ្នា នៅឆ្នាំ ២០១៤។ មានន័យថា (ក) មិនអាចចាត់ចែងមត៌កនោះបានទេ ទោះបីជាសន្តតិកម្មបានចាប់ផ្ដើមហើយក៏ដោយ ក៏ត្រូវរងចាំប្អូនៗ បានទទួលនីតិភាពផងដែរ។ មួយវិញទៀត មតកជនអាចធ្វើការកំណត់មត៌ករបស់ខ្លួនជាភាគ ដោយប្រើការបែងចែកទ្រព្យសម្បត្តិជាភាគទៅឱ្យសន្តតិជនម្នាក់ៗ។

**ឧទាហរណ៍៖** សុខជាមតកជន ដោយសន្តតិជនរបស់គាត់មានប្រពន្ធ និងកូនបីនាក់។ ដូចនេះកូនទាំងបីរបស់គាត់ទទួលបានចំណែក១/៤ ប៉ុន្តែគាត់បានកំណត់ឱ្យប្រពន្ធរបស់គាត់ទទួលបានចំណែក១/២។

**កថាភាគទី ៣. អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន**

មតកជនអាចធ្វើអនុប្បទាននូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែក ឬធ្វើប្រទានកម្ម ឬអច្ច័យទានតាមមតកសាសន៍ ឱ្យទៅជនដែលត្រូវបានសន្មតថាជាសន្តតិជន ឬតតិយជនបានផងដែរ។ មួយវិញទៀត បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទាននូវទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬច្រើនឱ្យសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតកសាសន៍នោះ ត្រូវបានសន្មតថាជាការកំណត់នូវវិធីនៃការបែងចែកមត៌ក លើកលែងតែមតកសាសន៍នោះ មានអត្ថន័យជាអច្ច័យទានច្បាស់លាស់ ដូចជាអច្ច័យទានភ្ជាប់បន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យនោះ មានចំនួនតិចជាងចំណែកមត៌កដែលសន្តតិជននោះត្រូវទទួលខុសត្រូវ លុះត្រាតែពុំមានការកំណត់ផ្សេងៗ នៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថា កំណត់វិធីបែងចែកមត៌ក ដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ[37]។

[36] មាត្រា១១៨៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[37] គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី សន្តតិកម្ម(មេរៀនសង្ខេប) បង្រៀនដោយ៖ មេធាវី អ៊ីវ ប៉ូលី ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ១៨

#### កថាភាគទី ៤. ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន [38] ។ ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍នេះ មិនមែនមានលក្ខណៈចាប់បង្ខំនោះទេ អ្នកដែលត្រូវបានជ្រើសរើសអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិក្នុងការបដិសេធ ដោយធ្វើការជូនដំណឹងដល់សន្តតិជនដោយគ្មានការយឺតយ៉ាវ ប៉ុន្តែកាលបើជននោះ បានបង្ហាញឆន្ទៈយល់ព្រមក្លាយជាអ្នកប្រតិបត្តិមតកសាសន៍នោះ ដើម្បីលាឈប់ត្រូវមានការអនុញ្ញាតពីតុលាការ[39]។

### ផ្នែកទី ៦. ការលុបចោលនូវមតកសាសន៍

ការបង្កើតមតកសាសន៍ គឺជាឆន្ទៈរបស់មតកជន ដើម្បីជាគោលបំណងចុងក្រោយក្នុងការបង្ហាញឆន្ទៈក្នុងការចាត់ចែងទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួន ចំពោះការបង្កើតមតកសាសន៍នេះទៀតសោត គឺជាសិទ្ធិផ្តាច់មុខរបស់ម្ចាស់បណ្តាំ។ យ៉ាងណាមិញ ម្ចាស់បណ្តាំមិនមែនមានតែសិទ្ធិក្នុងការបង្កើតមតកសាសន៍នោះទេ ម្ចាស់បណ្តាំក៏មានសិទ្ធិលុបចោលមតកសាសន៍វិញផងដែរ។ ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬទាំងមូល នៅពេលណាក៏បាន ដោយយោងតាមប្បញ្ញត្តិនៃ ការលុបចោលមតកសាសន៍នេះ[40]។

#### កថាភាគទី ១. ការមិនគោរពទម្រង់មតកសាសន៍

ក្នុងករណីដែលម្ចាស់បណ្តាំបានធ្វើសកម្មភាពផ្ទុយទៅនឹងមតកសាសន៍មុន ករណីនោះត្រូវបានចាត់ទុកថាបានលុបចោលដោយស្វ័យប្រវត្តិនូវមតកសាសន៍មុន។ មួយវិញទៀត ប្រសិនមតកសាសន៍ធ្វើក្រោយនេះមានភាពចំណុចខ្លះផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះបានលុបចោលមមតកសាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ[41]។ យ៉ាងណាមិញ ដើម្បីឱ្យមានភាពច្បាស់លាស់ចំពោះមតកសាសន៍ដែលបានធ្វើនៅពេលមុន ឬ ពេលក្រោយគឺ ត្រូវកំណត់ទៅលើកាលបរិច្ឆេទដែលបានចុះទៅលើកាលបរិច្ឆេទដែលបានចុះនៅក្នុងមតកសាសន៍នោះ។

**ឧទាហរណ៍៖** មតកសាសន៍មុន ម្ចាស់បណ្តាំបានឱ្យ A ទទួលដោយសន្តតិកម្ម នូវទ្រព្យសម្បត្តិទាំងអស់ (រថយន្ត ដី ផ្ទះ និងប្រាក់បញ្ញើនៅធនាគារ និងទ្រព្យផ្សេងទៀត)។

មតកសាសន៍ក្រោយ ម្ចាស់បណ្តាំបានឱ្យ A ទទួលដោយសន្តតិកម្មនូវដី និងរថយន្ត និងឱ្យ B ទទួលសន្តតិកម្មនូវ ផ្ទះ និងប្រាក់បញ្ញើនៅធនាគារ ឱ្យ C ទទួលសន្តតិកម្មនូវទ្រព្យក្រៅពីនេះ។

---

[38] មាត្រា១១៨៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[39] មាត្រា១២១៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[40] មាត្រា១១៨៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[41] មាត្រា១១៨៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្នុងករណីនេះ ត្រូវចាត់ទុកថាឱ្យ A ទទួលសន្តតិកម្មនូវ ផ្ទះ ប្រាក់បញ្ញើ និងទ្រព្យផ្សេងទៀត ក្នុងមតកសាសន៍ ត្រូវបានលុបចោល។

### កថាភាគទី ២. ការលុបចោលមតកសាសន៍ដោយចាត់ចែងនាពេលនៅរស់

បើម្ចាស់បណ្ដាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្ដាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ[42]។ មានន័យថា តាមមតកសាសន៍ មានចលនវត្ថុ មួយបានប្រគល់ទៅឱ្យបុគ្គលដែលជាសន្តតិជន A ក៏ប៉ុន្តែអំឡុងពេលដែលមតកជននៅរស់បានធ្វើប្រទានកម្ម ចលនវត្ថុនោះទៅឱ្យបុគ្គល B ដូចនេះ មតកសាសន៍បានលុបចោលអច្ច័យទាន ដែលជាផ្នែកមួយនៃមតកសាសន៍។

### កថាភាគទី ៣. ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍

លិខិតមតកសាសន៍ គឺជាភស្តុតាងតែមួយគត់ដែលអាចបញ្ជាក់ថា មានមតកសាសន៍។ បើម្ចាស់បណ្ដាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថាបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបំផ្លាញនោះ។ លើសពីនេះ ចំពោះករណីដែលម្ចាស់បណ្ដាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ដោយចេតនា ក៏ត្រូវបានយកអនុវត្តផងដែរ។ និយាយជារួមមានន័យថាមតកសាសន៍ធ្វើឡើងជាតឹកតាងសម្រាប់បញ្ជាក់ពីឆន្ទៈរបស់មតកជន ប្រសិនបើមតកជនបំផ្លាញមតកសាសន៍នោះ ជាហេតុនាំឱ្យមតកសាសន៍ត្រូវចាត់ទុកជាមោឃៈ។ ផ្ទុយទៅវិញក្នុងករណីដែលលិខិតមតកសាសន៍ ត្រូវបានបំផ្លាញដោយទង្វើរបស់តតិយជន ឬដោយប្រធានសក្តិ អានុភាពនៃការលុបចោលមិនអាចកើតឡើងបានឡើយ ប៉ុន្តែប្រសិនបើមានផ្នែកណាមួយមើលមិនយល់ ត្រូវចាត់ទុកថាផ្នែកនៃមតកសាសន៍នោះគ្មានអានុភាព។ បើសិនក្នុងករណីដែលមតកសាសន៍ត្រូវបានលុបចោលទាំងស្រុង នោះត្រូវចាត់ទុកថា មតកសាសន៍មិនត្រូវបានបង្កើតឡើងតាំងពីដំបូង។

## ផ្នែកទី ៧. អានុភាពនៃលិខិតមតកសាសន៍ និងការកំណត់ចំណែកមត៌ក

### កថាភាគទី ១. ពេលដែលមតកសាសន៍បង្កើតអានុភាព

#### ១. មរណភាពរបស់ម្ចាស់បណ្ដាំ

មតកសាសន៍មានអានុភាពនៅពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព [43] ។ ដោយបានរៀបរាប់មកច្រើនហើយថា លិខិតមតកសាសន៍ ត្រូវកើតចេញពីឆន្ទៈរបស់ម្ចាស់បណ្ដាំ ស្របតាមទម្រង់ណាមួយ ហើយធ្វើឡើងដោយគ្មានការចាប់បង្ខំពីតតិយជនណាម្នាក់ ឬម្ចាស់បណ្ដាំមិនស្ថិតក្រោមការហាមឃាត់ និងត្រូវបំពេញ

[42] មាត្រា១១៩០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[43] មាត្រា ១១៩៥.១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បែបបទយ៉ាងត្រឹមត្រូវតាមការកំណត់ទុកទើបមានសុពលភាព។ នៅក្នុងក្រមរដ្ឋប្បវេណី បានបង្ហាញពីសិទ្ធិចាត់ចែងរបស់មតកជន ទៅលើទ្រព្យសម្បត្តិដែលខ្លួនមាននៅពេលខ្លួនជារូបវន្តបុគ្គល។

**ឧទាហរណ៍៖** មតកជនធ្វើលិខិតបណ្តាំដោយក្នុងលិខិតបណ្តាំនោះមានខ្លឹមសារថា ផ្ទះ១ខ្នងតម្លៃ ២០០,០០០$ (ម្ភៃម៉ឺនដុល្លារ) ប្រគល់ឱ្យ A ដែលជាសហព័ទ្ធ ដី ១កន្លែង ប្រគល់ឱ្យ B ជាកូនស្រីច្បង និងលុយ ១៥០,០០០ (ដប់ប្រាំម៉ឺនដុល្លារ) នៅក្នុងធានាគារប្រគល់ឱ្យកូនប្រុសរបស់គាត់។ ក្រោយមកម្ចាស់បណ្តាំបានទទួលមរណភាព ហើយលិខិតបណ្តាំនឹងមានអានុភាពតាមការកំណត់នៅក្នុងខ្លឹមសារនោះ។ ការរៀបរាប់ខ្លឹមសារខាងលើនេះសម្រាប់លិខិតមតកសាសន៍ដែលម្ចាស់បណ្តាំមិនបានចែងកំណត់ពីលក្ខខណ្ឌបង្អង់នៃលិខិតមតកសាសន៍ ជាហេតុនាំឱ្យមានអានុភាពភ្លាមៗ បន្ទាប់ពីម្ចាស់បណ្តាំបានទទួលមរណភាព។

## ២. មតកសាសន៍ដែលភ្ជាប់លក្ខខណ្ឌបង្អង់

លិខិតមតកសាសន៍ដែលមានភ្ជាប់លក្ខខណ្ឌបង្អង់ គឺជាឆន្ទៈរបស់មតកជនដែលចង់ឱ្យសន្តតិជន ឬជនពាក់ព័ន្ធនឹងផលប្រយោជន៍ បំពេញនូវលក្ខខណ្ឌណាមួយស្របតាមបំណងចុងក្រោយរបស់ខ្លួននាពេលអនាគតបន្ទាប់ពីខ្លួនបាត់បង់ជីវិត។

ក្នុងករណីដែលមតកសាសន៍ភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ បើលក្ខខណ្ឌនោះ ត្រូវបានបំពេញចប់សព្វគ្រប់ នៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាពចាប់ពីពេលដែលលក្ខខណ្ឌនោះត្រូវបានបំពេញ[44]។

**ឧទាហរណ៍៖** ការធ្វើអច្ច័យទាននូវដីធ្លីដែលមានផ្ទះ ដោយតម្រូវឱ្យមានអាពាហ៍ពិពាហ៍នៃអច្ច័យលាភីជាលក្ខខណ្ឌបង្អង់។ ចំពោះករណីនេះ អានុភាពនៃមតកសាសន៍នេះកើតឡើងនៅពេលមានអាពាហ៍ពិពាហ៍ក្រោយពេលម្ចាស់បណ្តាំទទួលមរណភាព។ ក្នុងករណីនេះអាចសន្និដ្ឋានបានថា អច្ច័យលាភីបានទទួលលទ្ធកម្មនូវសិទ្ធិដែលមានភ្ជាប់លក្ខខណ្ឌ នៅពេលមរណភាពរបស់ម្ចាស់បណ្តាំ។ ផ្ទុយទៅវិញ ប្រសិនបើអច្ច័យលាភីបានរៀបអាពាហ៍ពិពាហ៍មុនពេលម្ចាស់បណ្តាំទទួលមរណភាព លក្ខខណ្ឌបង្អង់នោះបានសម្រេចមុនពេលម្ចាស់បណ្តាំទទួលមរណភាព ហេតុនេះហើយ អាចនិយាយបានថាមតកសាសន៍នេះគ្មានភ្ជាប់នូវលក្ខខណ្ឌនោះទេ។

## ៣. ការប្រកាសពីការបាត់ខ្លួន

ការប្រកាសអំពីការបាត់ខ្លួន គឺជាប្រព័ន្ធដែលចាត់ទុកថាបុគ្គលនោះបានទទួលមរណភាព ទៅលើទំនាក់ទំនងគតិយុត្តជុំវិញលំនៅដ្ឋាន តាមរយៈនីតិវិធីដែលបានកំណត់ ក្នុងករណីពុំបានដឹងច្បាស់លាស់ថាបុគ្គលនោះនៅរស់ ឬ ស្លាប់ក្នុងអំឡុងពេលកំណត់។ ក្នុងករណីបុគ្គលដែលជាម្ចាស់បណ្តាំ ពុំមានដំណឹងច្បាស់លាស់ថានៅ

[44] មាត្រា ១១៩៤.២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

មានជីវិត ឬទទួលមរណភាពក្នុងអំឡុងពេលណាមួយដូចបានកំណត់ក្នុងនីតិវិធី ត្រូវចាត់ទុកថាម្ចាស់បណ្តាំបានទទួលមរណភាពចំពោះទំនាក់ទំងគតិយុត្តទាំងអស់។ ហើយការបាត់ខ្លួនមាន ពីរប្រភេទគឺ ការបាត់ខ្លួនធម្មតា និង ការបាត់ខ្លួនពិសេស។

**ការបាត់ខ្លួនធម្មតា** ៖ ករណីការបាត់ខ្លួនធម្មតា នៅពេលមិនមានដំណឹងច្បាស់លាស់រយៈពេល ៥ឆ្នាំ ថាបុគ្គលដែលអវត្តមាននោះនៅរស់ ឬ ស្លាប់ តុលាការអាចប្រកាសអំពីការបាត់ខ្លួន តាមពាក្យស្នើសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ឬ អ្នកមានផលប្រយោជន៍ពាក់ព័ន្ធក្នុងការប្រកាសអំពីការបាត់ខ្លួននោះ។

**ការបាត់ខ្លួនពិសេស** ៖ ចំពោះករណី ការបាត់ខ្លួនពិសេសវិញ គឺអនុវត្តទៅលើករណីដែលមិនច្បាស់ថាបុគ្គលដែលជួបប្រទះនឹងករណីគ្រោះថ្នាក់ជាដើម នៅរស់ ឬ ស្លាប់។ បុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬបុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងថាបុគ្គលនោះនៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេល ១ឆ្នាំក្រោយពីចប់សង្គ្រាម ឬក្រោយពីនាវាបានលិច ឬក្រោយពីគ្រោះថ្នាក់បានកន្លងផុតទៅ តុលាការអាចប្រកាសអំពីការបាត់ខ្លួនបាន តាមពាក្យសុំរបស់សន្តតិជន អច្ច័យលាភី ឬជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដើម្បីប្រកាសអំពីការបាត់ខ្លួន ដែលធ្វើឱ្យនៅពេលចាប់ផ្តើមសសន្តតិកម្ម ឬការបើកលិខិតមតកសាសន៍នោះ មានអានុភាពទៅតាមផ្លូវច្បាប់។

បន្ទាប់ពីតុលាការបានចេញដីកា អំពីការប្រកាសបាត់ខ្លួន និងបានចូលជាធរមានស្ថាពរ នោះនាំឱ្យបង្កើតអានុភាពពិសេសគឺ ជនដែលតុលាការបានប្រកាសបាត់ខ្លួនត្រូវចាត់ទុកថាជននោះបានទទួលមរណភាព។ អានុភាពនៃការប្រកាសបាត់ខ្លួនរបស់ដីកាសម្រេចរបស់តុលាការនេះហើយដែលត្រូវចាត់ទុកថាបុគ្គលបាត់ខ្លួនបានទទួលមរណភាព ជាហេតុនាំឱ្យ មតកសាសន៍របស់ជនដែលបានបាត់ខ្លួននោះ ក៏ចាប់ផ្តើមបង្កើតអានុភាព ពីពេលដែលសេចក្តីសម្រេចពីការបាត់ខ្លួនចូលជាស្ថាពរ[45]។

## កថាភាគទី ២. អានុភាពនៃការកំណត់ចំណែកមត៌ក

មតកជនបានកំណត់ចំណែកមត៌ក ឬ វិធីបែងចែកមត៌កដោយអនុប្បទាននូវទ្រព្យសម្បត្តិជាក់លាក់ណាមួយ ឬច្រើនទៅឱ្យសន្តតិជនម្នាក់ ឬច្រើន តាមរយៈមតកសាសន៍ ទ្រព្យនោះនឹងធ្លាក់ទៅសន្តតិជន ដែលនឹងត្រូវទទួលទ្រព្យនោះដោយស្វ័យប្រវត្តិ នៅពេលមតកសាសន៍បង្កើតអានុភាព។ នៅក្នុងករណីនេះ មានការកំណត់នូវវិធីបែងចែកមត៌កតាមមតកសាសន៍ ហេតុនេះ មត៌កត្រូវបែងចែកតាមវិធីដែលបានកំណត់នោះ ដោយមិនចាំបាច់

[45] មាត្រា៤៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឆ្លងកាត់ការពិភាក្សាដោយសហសន្តតិជនឡើយ។ មួយវិញទៀត បើមតកសាសន៍ភ្ជាប់ជាមួយលក្ខខណ្ឌបង្អង់លុះត្រាតែលក្ខខណ្ឌនោះ ត្រូវបានបំពេញនៅក្រោយមរណភាពរបស់ម្ចាស់បណ្តាំ ទើបទ្រព្យនោះ ត្រូវចាត់ទុកថាធ្លាក់ទៅលើសន្តតិជន ដោយប្រតិសកម្ម គិតចាប់ពីថ្ងៃ ដែលមតកជននោះបានទទួលមរណភាព។

ដោយឡែកចំពោះអច្ច័យទាន ពុំមានអានុភាពឡើយ ប្រសិនបើអច្ច័យលាភីទទួលមរណភាពមុនម្ចាស់បណ្តាំ ឬដំណាលគ្នានឹងម្ចាស់បណ្តាំ។ កម្មវត្ថុដែលជាអច្ច័យទានទាំងអស់ត្រូវធ្លាក់ទៅលើសន្តតិជនវិញ។ ប៉ុន្តែបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈ ពិសេសផ្សេងពីនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវអនុវត្តតាមខ្លឹមសារនៃបណ្តាំនោះ។ ទោះបីអច្ច័យទាន កើតចេញពីឆន្ទៈនិងសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្តាំក្នុងការបែងចែកទ្រព្យសម្បត្តិទៅឱ្យអច្ច័យលាភីយ៉ាងណាក៏ដោយ ក៏មិនត្រូវចាប់បង្ខំអច្ច័យលាភីទទួលយក ឬអនុវត្តតាមការសម្រេចចិត្តរបស់ម្ចាស់បណ្តាំដែរ។ អច្ច័យលាភី មានសិទ្ធិក្នុងការបដិសេធ និងបោះបង់ចំពោះអច្ច័យទាន ហើយអច្ច័យទានក៏គ្មានអានុភាពចំពោះអច្ច័យលាភីបន្ទាប់ពីការបោះបង់សិទ្ធិនោះ[46]។

[46] ក្រមរដ្ឋប្បវេណី និង ក្រមនីតិរដ្ឋប្បវេណី ភាគ១ សមិទ្ធផល គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ បោះពុម្ពលើកទី១ ខែ ធ្នូ ឆ្នាំ ២០១៥ ទំព័រ៧៥

# ជំពូកទី ៣
# ការប្រតិបត្តិមតកសាសន៍ ភាគបម្រុង និងអច្ច័យទាន

# ជំពូកទី ៣
# ការប្រតិបត្តិមតកសាសន៍ ភាគបម្រុង និងអច្ច័យទាន

## ផ្នែកទី ១. ការប្រតិបត្តិមតកសាសន៍

### កថាភាគទី ១. ការពិនិត្យ និងការបើកមតកសាសន៍

រាល់ប្រភេទនៃមតកសាសន៍ដែលធ្វើឡើងទាំងអស់ ក្រៅពីទម្រង់នៃលិខិតយថាភូត ត្រូវតែមានការពិនិត្យ និងបញ្ជាក់។ ការពិនិត្យ និងបញ្ជាក់នេះ គឺត្រូវធ្វើឡើងសម្រាប់ជនដែលមានផលប្រយោជន៍បានដឹងលឺ និងដើម្បីកំណត់ខ្លឹមសារនៃមតកសាសន៍នោះ។ ហេតុនេះ អ្នកថែរក្សា គ្រប់គ្រងមតកសាសន៍ត្រូវដាក់ពាក្យសុំឱ្យមានការពិនិត្យទៅតុលាការនៅពេលដែលចាប់ផ្ដើមអនុវត្តសន្តតិកម្ម។ ក្នុងករណីដែលរកឃើញមតកសាសន៍ក្រោយមរណភាពរបស់មតកជន គឺត្រូវតែធ្វើការដាក់ពាក្យសុំទៅតុលាការដោយគ្មានការយឺតយ៉ាវជាដាច់ខាត។

ចំពោះមតកសាសន៍ដែលប្រថាប់ត្រា ត្រូវដាក់ពាក្យសុំទៅតុលាការក្នុងការបើក ដើម្បីចៀសវាងការកែប្រែនៃមតកសាសន៍នោះ ដោយក្នុងពេលបើកមតកសាសន៍នេះ គឺត្រូវមានវត្តមានអ្នកសង្កេតការណ៍ជាសន្តតិជន ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ជននោះ។ ប្រសិនបើមានការបើកលិខិត មតកសាសន៍នោះនៅក្រៅតុលាការ តែអានុភាពរបស់មតកសាសន៍នៅតែមានដដែល ដោយគ្រាន់តែត្រូវពិន័យចំពោះបុគ្គលដែលបានបើកនោះជាប្រាក់មិនលើសពី ១លានរៀល។ ការពិនិត្យបញ្ជាក់លិខិត មតកសាសន៍ គឺមានគោលបំណងក្នុងការបញ្ជាក់ពីអត្ថិភាព ឬ នត្ថិភាពនៃមតកសាសន៍ ដើម្បីមានភាពច្បាស់លាស់ចំពោះឆន្ទៈពិតប្រាកដរបស់មតកជន និងទម្រង់នៃមតកសាសន៍នោះ[47]។

អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម។

### កថាភាគទី ២. ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍បង្កើតឡើង ដើម្បីជួយសម្រួលដល់ការអនុវត្តមតកសាសន៍ប្រកបដោយភាពត្រឹមត្រូវ ការជឿទុកចិត្ត កាត់បន្ថយការរាំងស្ទះនានា ក្នុងកិច្ចដំណើរការអនុវត្តមតកសាសន៍ ធ្វើយ៉ាងណាឱ្យសម្រេចបាននូវខ្លឹមសារនៃមតកសាសន៍។ ហើយហេតុដែលច្បាប់បានបង្កើតរបបនៃអ្នកប្រតិបត្តិមតកសាសន៍នេះឡើង គឺដើម្បីឱ្យបុគ្គល ឬក្រុមបុគ្គល ជាអ្នកដែលនឹងក្លាយជាអ្នកប្រតិបត្តិ អនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងឆន្ទៈរបស់មតកជន ដើម្បីសម្រេចឱ្យបានទាំងស្រុងនូវខ្លឹមសារមតកសាសន៍ ធានាតម្លាភាព ជម្លោះនឹង ជៀសវាងបញ្ហារាំងស្ទះនានាដែលបង្កឡើងដោយបុគ្គលមានផលប្រយោជន៍ផ្នែកណាមួយ ឬភាគីពាក់ព័ន្ធ។

[47] JICA, មេធាវី អ៊ីវ ប៉ូលី៖ ការបែងចែកមត៌ក ១៥ មករា ២០១៨, ទំព័រ១៧

**១. ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ដោយមតកជន**

ម្ចាស់បណ្តាំ គឺជាអ្នកកំណត់នូវបុគ្គលដែលជាអ្នកប្រតិបត្តិមតកសាសន៍ផ្ទាល់។ ម្ចាស់បណ្តាំអាចប្រគល់អាណត្តិឱ្យតតិយជន កំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍។ មតកជនអាចជ្រើសរើសមនុស្សដែលខ្លួនពេញចិត្ត និងទុកចិត្តដើម្បីអនុវត្តមុខងារដែលខ្លួនបានប្រគល់ឱ្យ។ ការកំណត់អ្នកប្រតិបត្តិមតកសាសន៍នេះ មតកជនអាចសរសេរខ្លឹមសារនៅក្នុងមតកសាសន៍ថាបុគ្គល (ក) ឬ (ខ) គឺជាអ្នកប្រតិបត្តិមតកសាសន៍ នៅពេលដែលខ្លួនទទួលមរណភាព ឬនៅពេលដែលមតកសាសន៍នោះបង្កើតអានុភាព។

**២. ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ដោយតុលាការ**

ប្រសិនបើគ្មានអ្នកប្រតិបត្តិមតកសាសន៍ ដោយមូលហេតុមតកជនមិនបានកំណត់ពីនៅក្នុងលិខិតមតកសាសន៍ ឬក្នុងករណីដែលត្រូវកំណត់ជាអ្នកប្រតិបត្តិមតកសាសន៍នោះមិនព្រមកាន់មុខងារ ឬ អ្នកប្រតិបត្តិមតកសាសន៍បានទទួលមរណភាព នោះតុលាការអាចធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ តាមការទាមទាររបស់សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍[48]។ ជាគោលការណ៍ អ្នកប្រតិបត្តិមតកសាសន៍ជាអ្នកធ្វើសកម្មភាពគតិយុត្ត ក្រោយមតកសាសន៍មានអានុភាព ហេតុនេះបុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ ត្រូវបានច្បាប់កំណត់ដូចជា ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និងជនធនក្ស័យ។

**៣. ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ**

សន្តតិជន ឬជនដែលមានប្រយោជន៍ពាក់ព័ន្ធ អាចកំណត់អំឡុងពេលសមរម្យ និងធ្វើការដាស់តឿនចំពោះជនដែលត្រូវបានកំណត់ថាជាអ្នកប្រតិបត្តិមតកសាសន៍ ឱ្យធ្វើការឆ្លើយតបនៅក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬមិនយល់ព្រម ហើយបើអ្នកប្រតិបត្តិមតកសាសន៍នោះ មិនឆ្លើយតបនៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា លាឈប់ពីការងារ។ មួយវិញទៀតចំពោះជនដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍នៅក្នុងអំឡុងពេលដាស់តឿននេះទេ ត្រូវចាត់ទុកថាលាឈប់ពីអាណត្តិនោះ[49]។

[48] មាត្រា១២១៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[49] នីតិរដ្ឋប្បវេណី (មេរៀនសង្ខេប) បង្រៀនដោយ មេធាវី អ៊ុំ ប៉ុលី ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

## កថាភាគទី ៣. មុខងារ និងសិទ្ធិអំណាចអ្នកប្រតិបត្តិមតកសាសន៍

### ១. តួនាទី និងសិទ្ធិអំណាចអ្នកប្រតិបត្តិមតកសាសន៍ (ជ្រើសតាំងបន្ត)

អ្នកប្រតិបត្តិមតកសាសន៍ អាចបំពេញតួនាទី និងមុខងាររបស់ខ្លួនដោយឯករាជ្យ ដោយមិនចំណុះទៅនឹងភាគីណាមួយ ឬអ្នកពាក់ព័ន្ធផលប្រយោជន៍ណាមួយឡើយ។

ជាគោលការណ៍ អ្នកប្រតិបត្តិមតកសាសន៍មិនអាចឱ្យតតិយជនអនុវត្តកិច្ចការរបស់ខ្លួនបានឡើយ។ ប៉ុន្តែ ក្នុងករណីដែលមានមូលហេតុដែលពុំអាចជៀសវាងបានបានទេ ព្រមទាំងក្នុងករណីដែលមានការចែងអនុញ្ញាតជាមុនក្នុងលិខិតមតកសាសន៍ អាចឱ្យតតិយជនអនុវត្តកិច្ចការនោះបាន[50]។ ការមិនអនុញ្ញាតឱ្យតតិយជនអនុវត្តកិច្ចការនេះ ជាគោលការណ៍ គឺដោយសារតែមតកជនជឿទុកចិត្តទៅលើចំណេះដឹង និងសមត្ថភាពរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ហើយបានជ្រើសតាំងអ្នកនោះធ្វើជាអ្នកប្រតិបត្តិមតកសាសន៍នោះធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ ដោយប្រគល់សិទ្ធិដែលមាលក្ខណៈផ្តាច់មុខ។

អ្នកប្រតិបត្តិមតកសាសន៍ នៅពេលដែលបានឱ្យតតិយជនអនុវត្តកិច្ចការរបស់ខ្លួន ជាដំបូងអ្នកប្រតិបត្តិមតកសាសន៍ ត្រូវទទួលខុសត្រូវចំពោះអច្ច័យលាភី និងសន្តតិជន ក្នុងការជ្រើសតាំង និងត្រួតពិនិត្យតតិយជននោះ។ បន្ទាប់មក ក្នុងករណីដែលបានជ្រើសតាំងឱ្យតតិយជនអនុវត្តកិច្ចការ ដោយខុសនឹងគោលការណ៍នោះនឹងត្រូវសងសំណងនៃការខូចខាត ដែលកើតឡើងដោយសារហេតុនោះ ចំពោះអច្ច័យលាភី និង សន្តតិជន[51]។

អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និងធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីអនុវត្តលិខិតមតកសាសន៍[52]។ តួនាទីរបស់អ្នកប្រតិបត្តិមតកសាស៍បន្ទាប់ពីចូលកាន់មុខងាររបស់ខ្លួននោះ គឺត្រូវរៀបចំបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរបស់មតកជន។ បន្ទាប់ពីរៀបចំបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរបស់មតកជនរួច អ្នកប្រតិបត្តិមតកសាសន៍មានករណីយកិច្ចប្រគល់របាយការណ៍ និងត្រូវសងសំណង ករណីខ្លួនបានប្រើប្រាស់ប្រាក់ដែលជាមត៌ក ឬប្រើប្រាស់ប្រាក់សម្រាប់ត្រៀមក្នុងដំណើរការអនុវត្តសន្តតិកម្ម និងត្រូវប្រគល់ឱ្យសន្តតិជន ឬជនពាក់ព័ន្ធនឹងផលប្រយោជន៍ដោយគ្មានការយឺតយ៉ាវ[53]។ បញ្ជីសារពើភ័ណ្ឌចាំបាច់ត្រូវតែមាន ដើម្បីងាយស្រួលកំណត់ឱ្យបានច្បាស់លាស់អំពីកម្មវត្ថុនៃសិទ្ធិគ្រប់គ្រងចាត់ចែងមត៌ក។

---

[50] មាត្រា១២២៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[51] មាត្រា១២២៤.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[52] មាត្រា១២២០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[53] មាត្រា១២១៩ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការទទួលបន្ទុកការការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១៤

### ២. សហអ្នកប្រតិបត្តិមតកសាសន៍

ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានចំនួនច្រើននាក់ ការអនុវត្តភារកិច្ចនោះត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាល លើកលែងតែម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍ ត្រូវតែសម្រេចតាមឆន្ទៈនោះ[54]។

**ឧទាហរណ៍៖** A មានសិទ្ធិសម្រេចអ្វីៗពាក់ព័ន្ធអំពីអចលនទ្រព្យ ហើយ B មានសិទ្ធិសម្រេចអ្វីៗពាក់ព័ន្ធអំពីសិទ្ធិលើបំណុល។

### ៣. សោហ៊ុយ និងកម្រៃនៃអ្នកប្រតិបត្តិមតកសាសន៍

សោហ៊ុយដែលពាក់ព័ន្ធនឹងការប្រតិបត្តិមតកសាសន៍ជាបន្ទុកនៃមត៌ក ប៉ុន្តែមិនអាចកាត់បន្ថយភាគបម្រុង ដោយសារបន្ទុកនេះឡើយ[55]។ សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍មានដូចជា សោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីពិនិត្យបញ្ជាក់លិខិតមតកសាសន៍ សោហ៊ុយធ្វើបញ្ជីសារពើភ័ណ្ឌមត៌ក សោយហ៊ុយគ្រប់គ្រងមត៌ក និងកម្រៃនៃអ្នកប្រតិបត្តិមតកសាសន៍ជាអាទិ៍។ មួយវិញទៀត ការកាត់សោហ៊ុយប្រតិបត្តិមតកសាសន៍នេះ មិនអាចកាត់បន្ថយភាគបម្រុងឡើយ ពីព្រោះភាគនៃសោហ៊ុយជាបន្ទុករបស់អច្ច័យលាភី។

អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលមានកំណត់នៅក្នុងមតកសាសន៍បាន[56]។ បើនៅក្នុងមតកសាសន៍ ពុំបានកំណត់កម្រៃនោះទេ តុលាការត្រូវកំណត់ចំនួនកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ ដោយពិចារណា ភាពសមរម្យនៅក្នុងការបង់កម្រៃ ស្ថានភាពនៃមត៌ក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និងអ្នកប្រតិបត្តិមតកសាសន៍រាប់បញ្ចូលទាំងស្ថានភាពផ្សេងៗផងដែរ[57]។

### ៤. ការលាឈប់ និងបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍អាចលាឈប់ពីតួនាទីរបស់ខ្លួនបានក្នុងករណីខ្លួនមានមូលហេតុសមហេតុផលក៏ដូចជាមូលហេតុត្រឹមត្រូវ ដែលមិនអាច ឬ ពិបាកក្នុងការបំពេញកិច្ចការអាណត្តិក្នុងនាមជាអ្នកប្រតិបត្តិមតកសាស៍បាន ដោយត្រូវដាក់ពាក្យស្នើសុំលាឈប់ទៅតុលាការសាលាដំបូងនៃទីកន្លែងចាប់ផ្តើមសន្តតិកម្ម។ នៅក្នុងពាក្យសុំលាឈប់នេះ អ្នកប្រតិបត្តិត្រូវតែបញ្ជាក់ភាពចាំបាច់របស់ខ្លួនដែលមិនអាចបំពេញកិច្ចការប្រតិបត្តិបានយ៉ាងជាក់ច្បាស់ ដូចជា បញ្ហាសុខភាព ការជាប់ទៅបំពេញបេសកម្មក្នុងរយៈពេលវែងនៅក្រៅប្រទេស ឬមូលហេតុចូលកាន់ដំណែង ឬ កិច្ចការផ្សេងដែលធ្វើឱ្យមានភាពមមាញឹកជាអាទិ៍។ ម្យ៉ាងវិញទៀតក្នុងករណីដែល

[54] មាត្រា១២២៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[55] មាត្រា១២២៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[56] មាត្រា១២២៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[57] មាត្រា១២២៦.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អ្នកប្រតិបត្តិធ្វេសប្រហែស ខ្ជីខ្ជា ក្នុងការបំពេញភារកិច្ច ឬ មានភាពខ្ជិលច្រអូសក្នុងការបំពេញកិច្ចការរបស់ខ្លួន នោះសន្តតិកម្ម ឬ អច្ច័យលាភី ឬ អ្នកពាក់ព័ន្ធផលប្រយោជន៍នៃមតកសាសន៍អាចដាក់ពាក្យទៅតុលាការដើម្បីបញ្ឈប់តួនាទីអ្នកប្រតិបត្តិនោះ[58]។

## ផ្នែកទី ២. ភាគបម្រុង

ដោយបានរៀបរាប់ខាងលើមកហើយថា មតកជនអាចសម្រេចចិត្តដោយខ្លួនឯងអំពីនីតិវិធីនៃការបែងចែកទ្រព្យសម្បត្តិក្រោយពីទទួលមរណភាព តាមរយៈការធ្វើមតកសាសន៍បាន។ ប៉ុន្តែ ដោយសារតែមតកជនបានបែងចែកមត៌ករបស់គាត់ទៅតាមឆន្ទៈផ្ទាល់ ទើបក្រមរដ្ឋប្បវេណីបញ្ញត្តិអំពីប្រព័ន្ធមួយដែលហៅថា ភាគបម្រុង។ នៅក្នុងចំណោមចំណែកមត៌ករបស់សន្តតិជន ភាគបម្រុង គឺជាផ្នែកមួយដែលមិនអាចធ្វើការបំពានដោយមតកសាសន៍ជាអាទិ៍បានឡើយ។

ជាទូទៅ តាមរយៈសន្តតិកម្មតាមមតកសាសន៍ (បណ្តាំ) មតកជនអាចបង្ហាញនូវឆន្ទៈរបស់ខ្លួនក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន បន្ទាប់ពីខ្លួនទទួលមរណភាព។ ប៉ុន្តែ ជម្រើសនៃការបែងចែកមត៌កតាមវិធីនេះអាចនឹងមានការបំពានដល់ចំណែករបស់សន្តតិជនណាមួយ ក្នុងករណីមតកជនបានកំណត់ក្នុងបណ្តាំថា នឹងបែងចែកចំនួនលើសលុបឱ្យទៅសន្តតិជនណាម្នាក់ ជាហេតុធ្វើឱ្យសន្តតិជនម្នាក់ទៀតទទួលបានមត៌កតិចជាងសន្តតិជនផ្សេងទៀត។ ដើម្បី សម្រួលស្ថានភាពបែបនេះ ទើបក្រមរដ្ឋប្បវេណីបានកំណត់នូវបញ្ញត្តិមួយឡើង ដើម្បីធានាថាគ្មានការបំពានលើចំណែកមត៌ក ដែលត្រូវទទួលបានដោយសន្តតិជន ដែលរបបមួយនេះហៅថា ភាគបម្រុង។

បទបញ្ញត្តិ ស្តីពីភាគបម្រុងនេះទៀតសោតត្រូវបានបង្កើតឡើង ក្នុងគោលបំណងការការពារចាត់ចែងទ្រព្យសម្បត្តិដោយមានភាពសុក្រិត សមភាព នឹងមិនលំអៀង ឬការមិនរំលោភទៅលើចំណែកមត៌ករបស់សន្តតិជនណាម្នាក់ ដែលធ្វើឡើងដោយមតកជន ដូចជាធានាបាននូវចំណែកមត៌កជាក់លាក់ នឹងត្រឹមត្រូវមួយសម្រាប់ជនដែលនឹងត្រូវមានសិទ្ធិទទួលបានមត៌ក។ មតកជន មានសិទ្ធិធ្វើការបែងចែកមត៌ករបស់គាត់បានគ្រប់រូបភាព ក៏ប៉ុន្តែត្រូវគោរពលក្ខខណ្ឌតាមគោលការណ៍ភាគបម្រុង[59]។

### កថាភាគទី ១. និយមន័យ

ក្រមរដ្ឋប្បវេណីកម្ពុជាបច្ចុប្បន្ន មិនមានមាត្រាណាមួយកំណត់និយមន័យជាក់លាក់អំពី អ្វីទៅជាភាគបម្រុង នោះទេ។ ប៉ុន្តែបើយើងក្រឡេកទៅមើលក្រមរដ្ឋប្បវេណី ឆ្នាំ១៩៦៧ ឃើញថាបានឱ្យនិយមន័យថា ៖

[58] មាត្រា១២២៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និង មាត្រា១២២៧ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

[59] www.ciclg.com,ហ្វេសបុកផេក៖ ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ / Cambodia International Cooperation Law Group.

ភាគបម្រុង គឺជារបបមួយនៃបេតិកភណ្ឌ ដែលម្ចាស់បណ្តាំខ្លួនឯងផ្ទាល់ ក៏មិនអាចនឹងចាត់ចែងយ៉ាងណាៗដោយសេរីបានឡើយ[60]។

ទោះបីជាក្រមរដ្ឋប្បវេណីមិនបានអោយនិយមន័យនៃរបបភាគបម្រុងនេះក៏ដោយតែយើងអាចកំណត់អំពីអត្ថន័យនៃរបបនេះតាមរយៈការសិក្សាលើមាត្រា ១២៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ថាភាគបម្រុង គឺជាសិទ្ធិដែលទទួលបានមត៌កជាអប្បរមាដែលត្រូវធានាដោយច្បាប់ចំពោះអ្នកមានសិទ្ធិលើភាគបម្រុង។

**កថាភាគទី ២. អ្នកមានសិទ្ធិលើភាគបម្រុង**

នៅក្នុងក្រមរដ្ឋប្បវេណី បានកំណត់យកអ្នកដែលមានសិទ្ធិលើភាគបម្រុងមានដូចជា៖ បច្ឆាញាតិផ្ទាល់ ឪពុកម្តាយ ឬ ជីដូនជីតា និងសហព័ទ្ធរបស់មតកជន។ មានន័យថាអ្នកដែលត្រូវបានកំណត់ទុកថានឹងក្លាយជាសន្តតិជនផ្អែកតាមបញ្ញត្តិនៃចំណែកមត៌កដែលច្បាប់បានកំណត់ នឹងក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង។ លើសពីនេះទៅទៀតជាគោលការណ៍នៃភាគបម្រុង គឺ ១/២ នៃមត៌ករបស់មតកជនលើកលែងតែឪពុកម្តាយ ឬជីដូនជីតាជាសន្តតិជនដែលភាគបម្រុងគឺ ១/៣ នៃមត៌ករបស់មតកជន។ ចំណែកឯ បងប្អូនបង្កើត (សន្តតិជនលំដាប់ទី៣) មិនអាចក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបានទេ ទោះបីត្រូវបានកំណត់ទុកថានឹងក្លាយជាសន្តតិជនក៏ដោយ។

**កថាភាគទី ៣. លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង**

ដោយយើងបានដឹងហើយថាសន្តតិជនមានច្រើនប្រភេទ ដូចជាបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់។ ប៉ុន្តែមានតែសន្តតិជនមួយចំនួនប៉ុណ្ណោះ ទើបត្រូវចាត់ទុកជាអ្នកមានសិទ្ធិលើភាគបម្រុងដែលមានដូចជា៖

- បច្ឆាញាតិរបស់មតជន
- ឪពុកម្តាយរបស់មតកជន
- ជីដូនជីតារបស់មតកជន
- សហព័ទ្ធរបស់មតកជន។

លក្ខណៈក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង ពុំមានចែងនៅក្នុងក្រមរដ្ឋប្បវេណីទេ ប៉ុន្តែយើងអាចធ្វើការកត់សម្គាល់ អំពីលក្ខណៈសម្បត្តិ ដើម្បីក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបាន លុះត្រាតែបំពេញនូវលក្ខខណ្ឌពីរយ៉ាងគឺ ទី១ អ្នកមានសិទ្ធិលើភាគបម្រុងត្រូវតែជាសន្តតិជនដែលកំណត់ដោយច្បាប់ ហើយលក្ខណៈក្លាយជាសន្តតិជននេះ ក៏មានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីផងដែរ។ បន្ថែមពីនេះទៅទៀត ភាពដែលជាសន្តតិជនតែមួយមុខមិនអាចគ្រប់គ្រាន់នៅឡើយទេ គឺ ទី២ វាទាមទារឱ្យមាននូវការបំពានចំណែកមត៌កមួយទៀត ដែលជាធាតុសំខាន់ដែលមិនអាចខ្វះបាន។

[60] មាត្រា៥២៨ ក្រមរដ្ឋប្បវេណី ឆ្នាំ១៩៦៧

❖ **បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន**

សន្តតិជនដែលអាចទទួលមត៌កបានលុះត្រាតែបុគ្គលនោះ ជាសន្តតិជនដែលមានជីវិតនៅរស់នៅពេលចាប់ផ្ដើមសន្តតិកម្មតែប៉ុណ្ណោះ។ ប្រសិនបើជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ បានទទួលមរណភាពមុនពេល ឬ តំណាលគ្នានឹងមតកជននោះ សន្តតិជនមិនអាចបំពេញលក្ខខណ្ឌនៅមានជីវិតរស់នៅពេលចាប់ផ្ដើមសន្តតិកម្មនោះទេ ដូច្នេះ មិនអាចទទួលបានសន្តតិកម្មឡើយ។ លើសពីនេះសន្តតិជនត្រូវតែមិនមែនជាអភ័ព្វបុគ្គលហើយត្រូវផ្ដាច់ចេញពីមត៌ក[61]។

❖ **មានការបំពានលើចំណែកមត៌ក**

ការបំពានលើចំណែកមត៌ករបស់សន្តតិជន គឺជាធាតុមួយដ៏សំខាន់ ដែលមិនអាចខ្វះបានទេ ប្រសិនបើមិនមានការបំពានលើចំណែកមត៌កទេនោះ សន្តតិជនមិនអាចក្លាយជាអ្នកមានសិទ្ធិលើភាគភាគបម្រុងបានទេ។

**ឧទាហរណ៍៖** មតកជនមាន កូន២ (ពីរ) នាក់ និងសហព័ទ្ធដោយមតកជនបានបន្សល់ទុកនូវទ្រព្យមួយចំនួន ១០,០០០០ដុល្លារ។ នៅក្នុងមតកសាសន៍បានកំណត់បែងចែកទ្រព្យសម្បត្តិ ៣០,០០០ដុល្លារ ឱ្យទៅសហព័ទ្ធ ហើយកូនម្នាក់ៗបាន ៣០,០០០ដុល្លារ ចំណែក ១០,០០០ដុល្លារដែលនៅសល់ត្រូវឱ្យទៅបងរបស់មតកជន។

## កថាភាគទី ៤. ចំណែកនៃភាគបម្រុងរបស់សន្តតិជនម្នាក់ៗ

ការកំណត់ចំណែកមត៌ករបស់អ្នកមានសិទ្ធិលើភាគបម្រុង គឺជាអ្វីដែលច្បាប់បានកំណត់ ឬអនុញ្ញាតឱ្យអ្នកមានសិទ្ធិលើភាគបម្រុង មានសិទ្ធិទាមទារនូវចំណែកមត៌ករបស់ខ្លួន តែមិនមែនទាមទារបានដោយសេរីនោះទេ ហេតុនេះហើយបានជាច្បាប់បានកំណត់យ៉ាងជាក់លាក់ អំពីគោលការណ៍នៃចំណែកមត៌ក។

នៅក្នុងការបែងចែកចំណែកនៃភាគបម្រុងនេះ វាពុំមានលក្ខណៈស្មើគ្នានោះទេ គឺវាអាស្រ័យទៅតាមលំដាប់ និងចំនួនសន្តតិជនប៉ុណ្ណោះ។ ខាងក្រោមនេះ គឺជាចំណែកដែលសន្តតិជនម្នាក់ៗ ទទួលបានដោយយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា៖

ជាគោលការណ៍ភាគបម្រុង គឺ ១ ភាគ ២ នៃមត៌ករបស់មតកជន។

• **ចំពោះករណីដែលមតកជនមានតែឪពុកម្ដាយ ឬ ជីដូនជីតាជាសន្តតិជន**

ក្នុងករណីដែលមតកជនមានតែឪពុកម្ដាយ ឬ ជីដូនជីតាជាសន្តតិជននោះភាគបម្រុងត្រូវស្មើភាគនឹង ១ ភាគ ៣ នៃទ្រព្យសម្បត្តិរបស់មតកជន[62]។

---

[61] មាត្រា១១៥០ និងមាត្រា១១៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[62] មាត្រា១២៣០.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍៖** មតកជន មានទ្រព្យសម្បត្តិចំនួន ៦០,០០០ដុល្លារ នោះភាគបម្រុងស្មើនឹង២០,០០០ដុល្លារ។ បើក្នុងករណីដែលដែលមានតែកូនម្នាក់ និងសហព័ទ្ធរបស់មតកជន ជាសន្តតិជន ភាគបម្រុងសម្រាប់អ្នកទាំងនោះ គឺ ១ ភាគ ២ នៃមត៌ករបស់មតកជន។

**• ករណីមានសន្តតិជនច្រើននាក់**

ក្នុងករណីដែលសន្តតិជនដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗអាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមត៌កបាន[63]។

**កំណត់សម្គាល់៖**

❖ សហព័ទ្ធមានសិទ្ធិលើភាគបម្រុងជានិច្ច

❖ បើមានសន្តតិជនលំដាប់ទី១ ជាអ្នកមានសិទ្ធិលើភាគបម្រុង នោះសន្តតិជនលំដាប់ទី២ មិនមានសិទ្ធិនោះឡើយ។

**ឧទាហរណ៍** ៖ មតកជន មិនមានកូន និង សហព័ទ្ធ មានតែឪពុក និងម្តាយ ដូចនេះឪពុកម្តាយជាសន្តតិជនតាមច្បាប់ ករណីខាងលើ ភាគបម្រុង គឺ ១/៣ នៃមត៌ករបស់មតកជន ដោយសន្តតិជនមានពីរនាក់ ដូចនេះចំណែកនៃសិទ្ធិលើភាគបម្រុង ១/៣ ចែកនឹង២ = ១/៦។ តាមឧទាហរណ៍ខាងលើ ប្រសិនបើ មតកជន មានទ្រព្យដែលជាមូលដ្ឋានលើភាគបម្រុង មានចំនួន ៩០.០០០ ដុល្លារ។

ដូចនេះតាមសម្មតិកម្មខាងលើយើងអាចទាញបាន ៖

នាំឱ្យភាគបម្រុង = ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង × (១/៦)

នាំឱ្យភាគបម្រុង = ៩០.០០០ × (១/៦) = ១៥.០០០ ដុល្លារ

សរុបមក ចំណែកនៃមត៌ក ដែលអាចទាមទារបានពីភាគបម្រុង គឺឪពុក និងម្តាយ ទទួលបាន ១៥.០០០ ដុល្លារ ស្មើគ្នា។

## កថាភាគទី ៥. ការកាត់បន្ថយភាគបម្រុង

### ១. ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្តនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបាន ទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ[64]។ ជនដែលត្រូវបានបំពានភាគបម្រុង អាចយកសិទ្ធិដែលជាកម្មវត្ថុនៃការកាត់បន្ថយនោះមកធ្វើជារបស់ខ្លួនបាន ដោយធ្វើការទាមទារឱ្យកាត់បន្ថយអច្ច័យទាន ជាអាទិ៍

[63] មាត្រា១២៣០.៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[64] មាត្រា១២៣៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ហើយអ្នកមានសិទ្ធិលើភាគបម្រុង ឬប្រតិសិទ្ធិរបស់ខ្លួនមានសេរីភាពក្នុងការទាមទារ ឬមិនទាមទារ និង ប្រសិនបើមិនទាមទារ នាំឱ្យមតកសាសន៍មានសុពលភាពពេញលេញ ហើយជាគោលការណ៍ ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត ហេតុនេះ បើមិនទាមទារ នាំឱ្យបាត់បង់នូវអានុភាពដោយស្វ័យប្រវត្តិ ក្នុងកម្រិតនៃការបំពានសិទ្ធិលើភាគបម្រុងទៅតាមកម្រិតនៃភាគបម្រុង។ ម្យ៉ាងវិញទៀត ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះ មិនចាំបាច់ធ្វើសកម្មភាពបណ្ដឹងឡើយ ដោយតម្រូវឱ្យបង្ហាញឆន្ទៈជាការគ្រប់គ្រាន់ ប៉ុន្តែបើភាគីម្ខាងទៀតមិនយល់ព្រម ត្រូវដាក់ពាក្យបណ្ដឹង ហើយចំពោះការបង្ហាញឆន្ទៈនេះ ត្រូវធ្វើឡើងនៅអំឡុងពេលនៃអាជ្ញាយុកាល ១ (មួយ) ឆ្នាំដោយគិតចាប់ពីថ្ងៃដែលខ្លួនបានដឹងពីការចាប់ផ្ដើមសន្តតិកម្ម ឬ ៥ (ប្រាំ) ឆ្នាំគិតចាប់ពីថ្ងៃដែលចាប់ផ្ដើមសន្តតិកម្ម។ ដែលនាំឱ្យសិទ្ធិនេះ ត្រូវស្នងដោយជនដែលមានសិទ្ធិលើភាគបម្រុង ចាប់ពីពេលដែលបានបង្ហាញឆន្ទៈនោះ ហេតុនេះទោះបីជាដាក់ពាក្យបណ្ដឹងក្រោយអំឡុងពេលនេះ ក៏មិនមានបញ្ហាអ្វីឡើយ[65]។

## ២. លំដាប់នៃការកាត់បន្ថយនៃភាគបម្រុង

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុង រួមមាន អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និងប្រទានកម្ម [66] ។ដើម្បីដឹងថាតើការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងយ៉ាងដូចម្ដេចនោះ ច្បាប់ក៏បានកំណត់ពីលំដាប់នៃការកាត់បន្ថយផងដែរ។

នៅពេលដែលមានការបំពានភាគបម្រុង អច្ច័យទាន និងចំណែកមត៌ករបស់សន្តតិជន នឹងក្លាយជាកម្មវត្ថុនៃការកាត់បន្ថយ មុនដំបូងគេ ហើយប្រសិនបើនៅតែខ្វះ ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានដែលបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន ក្នុងគោលគំនិតធ្វើឱ្យមានភាពច្បាស់លាស់នៃនីតិវិធីកាត់បន្ថយអច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ក្នុងមតកសាសន៍ និងធ្វើចំណាត់ថ្នាក់នៃអច្ច័យទានរបស់សន្តតិជន និងអច្ច័យទានរបស់តតិយជន ដោយហេតុថា សន្តតិជនត្រូវទទួលសន្តតិកម្មនូវឋានៈជាកូនបំណុលនៃអច្ច័យទាន ពីមតកជន ហេតុនេះ ជាដំបូងត្រូវសម្រួលផ្ទៃក្នុងសន្តតិជនជាមុនសិន ហើយប្រសិនបើមិនគ្រប់ទេត្រូវកាត់បន្ថយពីតតិយជន។ មួយវិញទៀត អច្ច័យទាន និងចំណែកមត៌កដែលបានកំណត់តាមវិធីធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់ត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុ ប៉ុន្តែចំពោះករណីអច្ច័យទានរបស់សន្តតិជន នឹងចំណែកមត៌កដែលបានកំណត់នោះ ជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុង ផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជន ត្រូវចាត់ទុកថាជាតម្លៃនៃកម្មវត្ថុ។ លើសពីនេះទៅទៀត ក្នុងករណីមានការកំណត់នូវ

[65] នីតិរដ្ឋប្បវេណី (មេរៀនសង្ខេប) បង្រៀនដោយៈ មេធាវី អ៊ីវ ប៉ូលី ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

[66] មាត្រា១២៣៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ចំណែកមត៌ក ភាគនៃមត៌កត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង លើកលែងតែមតកជនបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍។

មួយវិញទៀតចំពោះប្រទានកម្ម និងការទទួលផលប្រយោជន៍ពិសេស មិនអាចកាត់បន្ថយបានឡើយ ដរាបណាអច្ច័យទាន និង ការកំណត់ចំណែកមត៌ក មិនទាន់បានកាត់បន្ថយជាមុននោះទេ[67]។ ខ្លឹមសារខាងលើនេះមានន័យ ត្រូវយកអច្ច័យទាន និងចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ មកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយ មុនប្រទានកម្ម និងការទទួលផលប្រយោជន៍ពិសេស[68]។ ដោយគោលគំនិតនៃរបបភាគបម្រុង គឺដើម្បីធានាទុកនូវមត៌កមួយភាគសម្រាប់ឱ្យជនដែលមានសិទ្ធិលើភាគបម្រុង។ ប៉ុន្តែ ក្នុងករណីដែលមានការកាត់បន្ថយមត៌កនាំឱ្យទៅជាការបំពានទៅលើភាគបម្រុងទៅវិញ ដោយសារការធ្វើប្រទានកម្មពេលនៅរស់ ដូចនេះប្រទានកម្ម ក៏ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយផងដែរ។

ក្នុងករណីដែលមតកជនបានធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិជាច្រើន ទៅឱ្យជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍ នាពេលនៅរស់ ការកាត់បន្ថយប្រទានកម្ម ឬផលប្រយោជន៍ពិសេស ត្រូវចាប់ផ្តើមពីប្រទានកម្ម ឬផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ ប៉ុន្តែប្រសិនបើជនដែលត្រូវបានកាត់បន្ថយនោះជាសន្តតិជន ហើយសាមីខ្លួនត្រូវបានបំពានដោយសារការកាត់បន្ថយនោះ ការកាត់បន្ថយនោះត្រូវធ្វើឡើងដោយដកភាគបម្រុងរបស់សន្តតិជននោះជាមុនសិន។ មួយវិញទៀត នៅក្នុងករណីដែលប្រទានកម្ម ឬផលប្រយោជន៍ពិសេសនោះត្រូវបានធ្វើឡើងលើសពី ២០ (ម្ភៃ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេស បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេស អាចបដិសេធនូវការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះបាន ដែលនេះគឺជាគោលគំនិតនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ដោយបន្ថែមនូវចំនួនឆ្នាំដើម្បីឱ្យមានសមភាពរវាងសន្តតិជន និងអ្នកទទួលផលប្រយោជន៍ពិសេស។

### កថាភាគទី ៦. ការសងផលមកវិញចំពោះបុគ្គលមានសិទ្ធិលើភាគបម្រុង

នៅពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទាមទារទៅឱ្យជនដែលមានករណីយកិច្ច ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង (សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ជាអាទិ៍) ដែលត្រូវបានទាមទារឱ្យកាត់បន្ថយភាគបម្រុង ត្រូវសងផលមកវិញនូវផលដែលកើតឡើង ចាប់ពីកាលបរិច្ឆេទ ដែលបានទាមទារឱ្យធ្វើការកាត់បន្ថយ ដោយរាប់បញ្ចូលទាំងប្រាក់សំណងផងដែរ។ ផ្ទុយទៅវិញ ប្រសិនបើ សហសន្តតិជន អច្ច័យលាភី ឬបដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ មិនអាចសងទ្រព្យ ដែលបានទទួលពីមតកជនវិញបាន ឬមិនអាចសងនូវតម្លៃទ្រព្យនោះ ដោយសារអសាធនភាព ការខាតបង់នេះ ត្រូវធ្លាក់បន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង

[67] មាត្រា១២៣៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[68] មាត្រា១២៣៦.២ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ក្រសួងយុត្តិធម៌ ២០១០

ដែលជាគោលការណ៍អ្នកមានសិទ្ធិលើភាគបម្រុងជាអ្នកទទួលបន្ទុក ហើយមិនអាចទាមទារឱ្យអ្នកមានកាតព្វកិច្ចនៅក្នុងលំដាប់បន្ទាប់សងនូវចំណែកដែលខ្លួនមានសិទ្ធិនោះទេ។

**ឧទាហរណ៍៖** ម្ចាស់បណ្តាំ (ក) បានធ្វើប្រទានកម្មនូវផ្ទះវីឡាសម្រាប់ជួលឱ្យទៅ (ខ) ដោយផលដែលកើតចេញពីផ្ទះវីឡា ជួលក្នុងមួយខែ៣០០០ដុល្លារ ដោយ (ខ) ទទួលបាន៣០០០ដុល្លារ ជារៀងរាល់ខែ ហើយម្ចាស់បណ្តាំបានទទួលមរណភាពនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ ហើយនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០២៣ សន្តតិជនរបស់ (ក) ក៏បានទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងពី (ខ) ចំពោះផ្ទះវីឡាទាំងមូលហើយ (ខ) ក៏បានប្រគល់ផ្ទះនោះនៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២៣។ ដោយ (ខ) បានទទួលផលដែលកើតចេញពីកម្មវត្ថុនៃការទាមទារឱ្យកាត់បន្ថយ គឺការបានប្រាក់ឈ្នួលពីការជួលផ្ទះចំនួន ៦ខែ។ ដូនេះ ៦x៣០០០=១៨,០០០ ដុល្លារ ដូច្នេះ (ខ) ត្រូវកាត់ទឹកប្រាក់ចំនួន ៣ខែ ដែលស្មើនឹង ៩,០០០ដុល្លារ ប្រគល់ទៅឱ្យសន្តតិជនរបស់ (ក) ដោយសារការទាមទារនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ហើយទឹកប្រាក់ដែលនៅសល់ចំនួន ៩,០០០ដុល្លារ (ខ) អាចរក្សាទុកបាន ដោយមិនត្រូវបានទាមទារឱ្យកាត់បន្ថយភាគបម្រុងនោះទេ។

## កថាភាគទី ៧. ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

### ១. អាជ្ញាយុកាល

សិទ្ធិទាមទារឱ្យកាត់បន្ថយ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និងការកំណត់ចំណែកមត៌កអច្ច័យទាន ប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ។ សិទ្ធិទាមទារឱ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម។

ការរំលត់ដោយអាជ្ញាយុកាលនៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនម្នាក់ ឬការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ[69]។

ចំពោះប្រទានកម្ម ក្នុងករណីដែលបានធ្វើប្រទានកម្ម ឬទទួលផលប្រយោជន៍ពិសេស លើសពី ២០ (ម្ភៃ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះ អាចបដិសេធ នូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន[70]។

---

[69] មាត្រា១២៤៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[70] មាត្រា១២៣៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ២. ការបោះបង់ភាគបម្រុង

ភាគបម្រុងអាចបោះបង់ចោលទាំងអស់ ឬមួយផ្នែកបាន[71]។ ការបោះបង់ភាគបម្រុង គឺអាចធ្វើបានដោយការបង្ហាញឆន្ទៈតែម្ខាងចំពោះអ្នកមានកាតព្វកិច្ច។ ឧទាហរណ៍៖ ដូចជាការទទួលប្រាក់កំណត់មួយពីជនដែលមានកាតព្វកិច្ច ហើយជាថ្នូរ គឺត្រូវបោះបង់នូវភាគបម្រុងដែលនៅ ខ្វះជាដើម។

ចំណែកឯ ការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្តើមសន្តតិកម្មមានអានុភាព លុះត្រាតែបានទទួលការ អនុញ្ញាតពីតុលាការ[72]។ ការណ៍នេះ ដើម្បីកុំឱ្យមានការបោះបង់សិទ្ធិនោះជាមុន ដោយសារតែចាញ់អំណាចរបស់ឪពុកម្តាយ ជាអាទិ៍ ប៉ុន្តែប្រសិនបើមានការបោះបង់ ចាំបាច់ត្រូវតែមានការពិនិត្យតាងនាមជាអាណាព្យាបាលដោយតុលាការ។ តុលាការដែលទទួល ពាក្យសុំអនុញ្ញាតនោះ ត្រូវធ្វើការវិនិច្ឆ័យដោយពិនិត្យមើល ថាតើការបោះបង់នោះជាឆន្ទៈពិតរបស់ជនដែលមានសិទ្ធិលើភាគបម្រុងឬទេ តើការបោះបង់នោះមានភាពសមហេតុផលដែរឬទេ តើចាំបាច់បោះបង់ឬទេ តើមានតម្លៃជាថ្នូរដែរឬទេ។

ម្យ៉ាងទៀតទោះបីជាបានបោះបង់សិទ្ធិនេះ មុនពេលចាប់ផ្តើមសន្តតិកម្មដោយទទួលការអនុញ្ញាតពីតុលាការ ក៏ដោយ ក៏អ្នកមានសិទ្ធិលើភាគបម្រុងនោះអាចដាក់ពាក្យសុំឱ្យតុលាការលុបចោលការអនុញ្ញាតមុននោះបាន នៅមុន ពេលចាប់ផ្តើមសន្តតិកម្ម ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរក្រោយពេលបោះបង់សិទ្ធិនោះ។

## ផ្នែកទី៣. អច្ច័យទាន

### កថាភាគទី ១. និយមន័យអច្ច័យទាន

អច្ច័យទាន គឺជាប្រទានកម្ម ដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួន តាមរយៈមតកសាសន៍[73]។ អច្ច័យទាន គឺជាសកម្មភាពឯកតោភាគីដែលធ្វើឡើងដោយម្ចាស់បណ្តាំ សំដែងឆន្ទៈធ្វើអនុប្បទានទ្រព្យសម្បត្តិមួយផ្នែក ឬ ទាំងអស់ឱ្យអច្ច័យលាភី ដែលខុសវាខុសពីប្រទានកម្ម គឺធ្វើឡើងរវាងទាយក និងបដិគ្គាហកតាមរយៈកិច្ចសន្យា។ អ្នកទទួលអច្ច័យទាន ហៅថា អច្ច័យលាភី។ ក្នុងនោះដែលអច្ច័យទានត្រូវបានបែងចែកជាពីរប្រភេទ គឺអច្ច័យទានសកល និងអច្ច័យមានកំណត់។

[71] មាត្រា១២៤៦.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[72] មាត្រា១២៤៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[73] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ បោះពុម្ពលើកទី១ ឆ្នាំ២០០៧

## កថាភាគទី ២. ប្រភេទនៃអច្ច័យទាន

### ១. អច្ច័យទានសកល

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគតាមរយៈមតកសាសន៍ (ទាំងអស់, ពាក់កណ្តាល, ឬ ១/៣ ជាអាទិ៍)[74]។

**ឧទាហរណ៍៖** ម្ចាស់បណ្តាំ (ក) មានមត៌កសរុបរួមមាន ផ្ទះល្វែងតម្លៃ ១៥០,០០០ ដុល្លារ រថយន្តចំនួនពីរគ្រឿងតម្លៃទីផ្សារ ៥០,២០០០ ដុល្លារ និងប្រាក់សរុបចំនួន ៤០,០០០ ដុល្លារ។ ខ្លឹមសារនៅក្នុងលិខិតបណ្តាំម្ចាស់បណ្តាំបានសរសេរដោយធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិចំនួន ១/៣ នៃមត៌កសរុបឱ្យទៅអច្ច័យលាភី (ខ)។ ករណីនេះគឺជាប្រភេទ អច្ច័យទានសកល។

### ២. អច្ច័យទានមានកំណត់

អច្ច័យទានមានកំណត់ គឺជាប្រទានកម្ម ដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់ ដោយមតកសាសន៍[75]។

**ឧទាហរណ៍៖** ម្ចាស់បណ្តាំ (ក) មាននមត៌កសរុបរួមមាន ផ្ទះល្វែងតម្លៃ ១៥០,០០០ ដុល្លារ រថយន្តចំនួនពីរគ្រឿងតម្លៃទីផ្សារ ៥២,០០០ ដុល្លារ និងប្រាក់សុទ្ធចំនួន ៤០,០០០ ដុល្លារ។ ខ្លឹមសារនៅក្នុងលិខិតបណ្តាំម្ចាស់បណ្តាំបានសរសេរដោយធ្វើអច្ច័យទាននូវរថយន្តចំនួនពីរគ្រឿងឱ្យទៅអច្ច័យលាភី (ខ)។ ករណីនេះគឺជាអច្ច័យទានមានកំណត់។

## កថាភាគទី ៣. សិទ្ធិ និងភាតព្វកិច្ចរបស់អច្ច័យលាភី

អច្ច័យលាភី គឺជាបុគ្គលដែលបានទទួលដែលទទួលបានអច្ច័យទាន។ បើសិនជាអច្ច័យលាភីបានទទួលមរណភាពមុនពេលម្ចាស់បណ្តាំទទួលមរណភាព នោះអច្ច័យទានពុំមានអានុភាពនោះទេ។ ប៉ុន្តែមតកជនក៏អាចសម្តែងឆន្ទៈផ្សេងពីនេះក្នុងមតកសាសន៍ដែរ[76]។

អច្ច័យលាភី មានសិទ្ធិក្នុងការទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន។ អច្ច័យលាភី អាចបោះបង់អច្ច័យទានសកលនៅពេលណាក៏បានដែរ ក្រោយពេលដែលម្ចាស់បណ្តាំទទួលមរណភាព។ ចំពោះការបោះបង់អច្ច័យទានសកលនេះ ត្រូវអនុវត្តដូចការបោះបង់សន្តតិកម្មដែរ [77] ។ ដោយឡែកចំពោះការបោះបង់អច្ច័យទានមានកំណត់វិញ ពុំមានបញ្ញត្តិណាមួយនៃក្រមរដ្ឋប្បវេណីបានចែងនោះទេ។

[74] មាត្រា១១៩៩ សេចក្តីកំណត់ក្រមរដ្ឋប្បវេណីភាគ៦ ៖ គន្លឹះទី៨-៩

[75] មាត្រា១១៩៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[76] មាត្រា១២០០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[77] មាត្រា១២០១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដើម្បីចៀសវាងភាពយឺតយ៉ាវនៃការធ្វើសន្តតិកម្ម បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចដាស់តឿនឱ្យអច្ច័យលាភីធ្វើការទទួលស្គាល់ ឬ បោះបង់អច្ច័យទានក្នុងអំឡុងពេលសមរម្យមួយ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅអំឡុងពេលដែលបានកំណត់នោះទេ គេចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ[78]។ ករណីដែលអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានបង្ហាញឆន្ទៈក្នុងការបោះបង់ ឬ ទទួលស្គាល់អច្ច័យទាននៅឡើយ នោះសន្តតិជនរបស់អច្ច័យលាភី អាចធ្វើការទទួលស្គាល់ ឬ បោះបង់អច្ច័យទានបានត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុវត្តតាមឆន្ទៈនោះ[79]។

ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ហើយអច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទានដោយបោះបង់សន្តតិកម្មបានឡើយ[80]។

លើសពីនេះទៅទៀត អច្ច័យលាភីមានសិទ្ធិក្នុងការទាមទារផលប្រយោជន៍របស់ខ្លួន បន្ទាប់ពីអច្ច័យទានមានអានុភាព ពោលគឺបន្ទាប់ពីមតកជនទទួលមរណភាព។ ប៉ុន្តែប្រសិនបើអច្ច័យទានមានលក្ខខណ្ឌបង្អង់ អច្ច័យលាភីអាចទាមទារឱ្យអនុវត្តអច្ច័យទានលុះត្រាតែលក្ខខណ្ឌបង្អង់នោះត្រូវបានបំពេញសិន[81]។

## កថាភាគទី ៤. ការយល់ព្រម និងការបោះបង់អច្ច័យទាន

### ១. ការបោះបង់អច្ច័យទាន

ជាទូទៅអច្ច័យទានកើតចេញពីឆន្ទៈ និងសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្តាំ ក្នុងការផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនទៅអោយអច្ច័យលាភី ហើយអានុភាពរបស់វានឹងកើតឡើងដោយស្វ័យប្រវត្តិ នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព ដោយគ្មានទាក់ទងនឹងឆន្ទៈរបស់អច្ច័យលាភីឡើយ។ ទោះបីជាបែបនេះក៏ដោយវាមិនអាចបង្ខំអោយអច្ច័យលាភីទទួលយកវត្ថុ ឬ សិទ្ធិ (ទ្រព្យសម្បត្តិ ប្រាក់បញ្ញើ សិទ្ធិលើបំណុល) ដែលខ្លួនពុំមានឆន្ទៈក្នុងការទទួលផងដែរ ព្រោះជាគោលការណ៍ច្បាប់បានប្រគល់សិទ្ធិ ក៏ដូចជាការគោរពនូវសេរីភាពរបស់បុគ្គលក្នុងការបោះបង់អច្ច័យទានបាន។ ដើម្បីការពារនូវសិទ្ធិនេះ ច្បាប់ក៏បានបញ្ញត្តិថា នៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន[82]។ ប៉ុន្តែចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិច្បាប់ស្តីពីការបោះបង់សន្តតិកម្មផងដែរ ដោយត្រូវដាក់

[78] មាត្រា១២០២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[79] មាត្រា១២០៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[80] មាត្រា១២០៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[81] មាត្រា១២០៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[82] មាត្រា១២០១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ពាក្យសុំទៅតុលាការ ចំណែកអច្ច័យទានកំណត់វិញ ពុំមានបញ្ញត្តិពាក់ព័ន្ធនឹងការកំណត់ពេលវេលាសំរាប់ការបោះបង់អច្ច័យទាន ឬ ទម្រង់ឡើយ។ បន្ទាប់ពីមានការបោះបង់អច្ច័យទាន ការបោះបង់នេះត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្តាំទទួលមរណភាព ហើយកម្មវត្ថុនៃទ្រព្យអច្ច័យទានត្រូវធ្លាក់លើសន្តតិជនរបស់មតកជន ចាប់ពីពេលដែលសន្តតិកម្មបានចាប់ផ្តើម[83]។

## ២. ការទទួលស្គាល់ ឬ បោះបង់ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

ក្នុងករណីអច្ច័យលាភី ជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ។ អច្ច័យលាភីនោះ មិនអាចទទួលស្គaល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ[84]។ ដោយហេតុថា ក្នុងករណីដែលមតកជនមានកាតព្វកិច្ចណាមួយក្នុងការឱ្យសន្តតិជនទទួលយកសន្តតិកម្ម ក៏ប៉ុន្តែ សន្តតិជនបែរជាមិនទទួលយកកាតព្វកិច្ចនោះដោយបានបោះបង់សន្តតិកម្ម ហើយនៅក្នុងលិខិតមតកសាសន៍នោះមតកជនបានធ្វើអច្ច័យទានទ្រព្យសម្បត្តិជាក់លាក់មួយ ប្រសិនបើសន្តតិជនទទួលយកគឺមានន័យថាការទទួលយក គឺដើម្បីតែផលប្រយោជន៍ប៉ុណ្ណោះ[85]។ ហេតុនេះទើបច្បាប់បានបញ្ញត្តិពិសេសស្តីពីការទទួលស្គាល់ ឬ បោះបង់នូវអច្ច័យទាន ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន ដើម្បីចៀសវាងការទទួលយកតែផលប្រយោជន៍ ហើយបោះបង់កាតព្វកិច្ចណាមួយ។

ឧទាហរណ៍៖ នៅក្នុងមត៌ករបស់ម្ចាស់បណ្តាំ មានផ្ទះ ប្រាក់ ឡាន និងបំណុល។ នៅក្នុងមតកសាសន៍ម្ចាស់បណ្តាំបានធ្វើអច្ច័យទាន ជាកំណត់នៅផ្ទះឱ្យសន្តតិជនដែលសន្មតជាអច្ច័យលាភី ហើយទ្រព្យដែលនៅសល់ទាំងអស់នោះត្រូវឱ្យសន្តតិជនបីនាក់ (ម្នាក់ក្នុងចំណោមបីនាក់ គឺជាអច្ច័យលាភី)។ ក្នុងករណីនេះអច្ច័យលាភីជាសន្តតិជន មិនអាចបោះបង់សន្តតិកម្ម (ប្រាក់ ឡាន និងបំណុលតាមសមាមាត្រ ដែលខ្លួនទទួលបាន) ដោយទទួលយកតែ អច្ច័យទាន (ផ្ទះ)។ ព្រោះការធ្វើបែបនេះ វាអយុត្តិធម៌ចំពោះសន្តតិជនផ្សេងៗទៀតដែលត្រូវទទួលរ៉ាបរងបំណុល។

ប៉ុន្តែបើអច្ច័យលាភី ជាសន្តតិជនបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយក៏អច្ច័យលាភីនោះ អាចបោះបង់អច្ច័យទានមានកំណត់បានដែរ[86]។

[83] មាត្រា១១៩៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[84] មាត្រា១២០៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[85] មាត្រា១២០៥ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦៖ គន្ថីទី៨-ទី៩ រៀបរៀងដោយ គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុងការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ២០១០

[86] មាត្រា១២០៥.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣. ការបោះបង់ ឬ ការទទួលស្គាល់ដោយសន្តតិជនរបស់អច្ច័យលាភី

បើករណីអច្ច័យលាភីបានទទួលមរណភាពដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន។ ប៉ុន្តែបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ[87]។

### ៤. ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

នៅក្នុងករណីខ្លះ អច្ច័យលាភីពុំបានបង្ហាញឆន្ទៈ បោះបង់ ឬ ទទួលស្គាល់ទេ ដូចនេះវាធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ជនដទៃផ្សេងទៀត។ ក្នុងករណីនេះ ជនពាក់ព័ន្ធផលប្រយោជន៍ (ម្ចាស់បំណុល) អាចដាស់តឿនអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទាន ដោយកំណត់កំឡុងពេលសមរម្យ។ បើសិនជាអច្ច័យលាភីមិនបានបង្ហាញឆន្ទៈចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន (សន្តតិជន អច្ច័យលាភីសកល) នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថាអច្ច័យលាភីបាន ទទួលស្គាល់អច្ច័យទាននោះ។

### ៥. ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

នៅក្នុងលក្ខខណ្ឌនៃការបោះបង់ និងការទទួលស្គាល់ អច្ច័យទានក៏មានការហាមឃាត់ផងដែរ ក្នុងករណីអច្ច័យលាភីបានលុបចោលវិញនៅការទទួលស្គាល់ ឬ ការបោះបង់នោះ ព្រោះវាអាចជះឥទ្ធិពលដល់ជនដែលពាក់ព័ន្ធ។ ទោះបីជាយ៉ាងណាក៏ដោយ ករណីខ្លះ អច្ច័យលាភីនៅតែអាចលុបចោលការបោះបង់ និងការទទួលស្គាល់អច្ច័យទានដែរ ដោយមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈ ដែលកើតចេញពីការគំរាមកំហែង ឬ ឆបោកពីបុគ្គលពាក់ព័ន្ធ។

[87] មាត្រា១២០៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងប្រធានបទ សន្តតិកម្មតាមមតកសាសន៍ រួចមក យើងសង្កេតឃើញថា ប្រធានបទមួយនេះពិតជាមានសារៈសំខាន់សម្រាប់ សិស្សនិស្សិតក៏ដូចជា ប្រជាពលខ្មែរគ្រប់រូបដែលគួរគប្បីយល់ដឹងអំពីដំណើរការបញ្ហាពាក់ព័ន្ធទៅនឹងការធ្វើបណ្តាំនេះ។ ដោយនៅក្នុងសន្ទានុក្រមផ្នែករដ្ឋប្បវេណីបានឱ្យនិយន័យពាក្យថា សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬ ច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។ ក្នុងនោះដែរក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧បានបញ្ញត្តិទាក់ទងនឹងប្រភេទនៃរបបសន្តតិកម្ម គឺមានពីរប្រភេទ នោះគឺសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍។ ដោយឡែកប្រធានបទរបស់យើងនិយាយផ្តោតទៅលើអំពី សន្តតិកម្មតាមមតកសាសន៍ប៉ុណ្ណោះតែមានបកស្រាយសញ្ញាណទូទៅនៃសន្តតិកម្ម និងសន្តតិកម្មតាមច្បាប់បន្តិចបន្តួចផងដែរ ។ បើក្រឡេកមកមើលសន្តតិកម្មតាមមតកសាសន៍វិញ គឺសំដៅទៅលើ ការបង្ហាញឆន្ទៈជាឯកតោភាគីរបស់ម្ចាស់បណ្តាំ ក្នុងការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចដែលធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសម្តែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន បន្ទាប់ពីទទួលមរណភាព។ ដោយបានបកស្រាយ ក៏ដូចជាការរៀបរាប់ខាងលើមកហើយ តាមច្បាប់កម្ពុជាសព្វថ្ងៃ មតកសាសន៍អាចធ្វើឡើងក្រោមបីទម្រង់គឺ មតកសាសន៍ដោយលិខិតឯកជន មតកសាសន៍ដោយលិខិតយថាភូត និងមតកសាសន៍ដោយលិខិតសម្ងាត់។ មុនពេលធ្វើបណ្តាំម្ចាស់បណ្តាំអាចជ្រើសរើសទម្រង់មួយក្នុងការធ្វើមតកសាសន៍ ដោយត្រូវអនុវត្តតាមច្បាប់ និងអនុលោមទៅតាមបែបបទ នីតិវិធី ក៏ដូចជាដំណើរការនីមួយៗឱ្យបានខ្ជាប់ខ្ជួន។ មួយវិញទៀត រាល់ទម្រង់លិខិតមតកសាសន៍ទាំងអស់គឺតម្រូវឱ្យមានការចូលរួមពីសាក្សីយ៉ាងតិចពីរូប លើកលែងតែទម្រង់លិខិតឯកជនដែលមិនទាមទារឱ្យមានការចូលរួមពីសាក្សី។ បែបបទនៃលិខិតមតកសាសន៍ដោយលិខិតឯកជន គឺម្ចាស់បណ្តាំជាអ្នកសរសេរផ្ទាល់នូវខ្លឹមសារទាំងមូលនៃការបែងចែកមត៌ក ព្រមទាំងចុះថ្ងៃខែឆ្នាំ និងហត្ថលេខាដោយសាមីខ្លួនផ្ទាល់។ ករណីដែលម្ចាស់បណ្តាំធ្វើឡើងដោយឱ្យតតិយជនជាអ្នកសរសេរជំនួសដោយការវាយកុំព្យូទ័រ ឬដោយការសរសេរដោយដៃត្រូវចាត់ទុកថាមោឃៈ។ ចំពោះមតកសាសន៍ដោយលិខិតយថាភូតវិញ សារការីដើរតួនាទីយ៉ាងសំខាន់ក្នុងការតាក់តែងមតកសាសន៍នេះ ដោយម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារទាំងមូលចំពោះមុខសារការីដើម្បីកត់ត្រាចូលលិខិតបណ្តាំនោះ ហើយត្រូវមានសាក្សីពីររូបយ៉ាងតិចនៅពេលធ្វើមតកសាសន៍នេះ។ ចំណែកឯ មតកសាសន៍ដោយលិខិតសម្ងាត់វិញ គឺម្ចាស់បណ្តាំសរសេរដោយផ្ទាល់ ឬស្នើសុំឱ្យនរណាម្នាក់ជាអ្នកសរសេរក៏បាន។ បន្ទាប់ម្ចាស់បណ្តាំត្រូវធ្វើការចុះហត្ថលេខាដោយខ្លួនឯងផ្ទាល់ ដើម្បីបញ្ជាក់ថាលិខិតមតកសាសន៍បានកើតចេញពីម្ចាស់បណ្តាំយ៉ាងពិតប្រាកដ។ ហើយសារការីជាអ្នកបញ្ជាក់ ថាមានលិខិតបណ្តាំរបស់ម្ចាស់បណ្តាំយ៉ាងពិត

ប្រាកដមែន ហើយខ្លឹមសារនៅក្នុងលិខិតបណ្តាំត្រូវបានរក្សាទុកជាការសម្ងាត់។ ម្ចាស់បណ្តាំត្រូវដាក់លិខិតបណ្តាំនោះ នៅចំពោះមុខសារការីម្នាក់ និងសាក្សីពីររូប បន្ទាប់មកសារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំនៅលើស្រោមលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើស្រោមលិខិតនោះជាមួយសាក្សី និងម្ចាស់បណ្តាំ។

សរុបសេចក្តីមកការធ្វើសន្តតិកម្មតាមមតកសាសន៍ គឺត្រូវគោរពតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ជាចាំបាច់ ជាពិសេសការធ្វើទៅតាមនីតិវិធីដែលច្បាប់បានកំណត់ជាកំហិត ទើបមតកសាសន៍ដែលបានធ្វើឡើងនោះមានអានុភាពគតិយុត្តក្រោយពេលម្ចាស់បណ្តាំទទួលមរណភាព។ ការធ្វើបែបនេះ គឺគោលបំណងធានាបាននូវភាពមិនប្រក្រតីណាមួយ ក៏ដូចជាចន្លោះប្រហោងផ្សេកអ្វីមួយនៅពេលតាក់តែងលិខិតមតកសាសន៍ ចៀសវាងក្រោយពេលមតកជនបានទទួលមរណភាព មតកសាសន៍នោះមិនមានអានុភាព និងមិនមានលក្ខណៈគ្រប់គ្រាន់ ឬឆន្ទៈពិតប្រាកដដែលជាសមត្ថភាពរបស់ម្ចាស់បណ្តាំផ្ទាល់ ឬរងនូវមោឃភាព ដោយខុសលក្ខខណ្ឌគ្រឹះ ឬលក្ខខណ្ឌទម្រង់ណាមួយដែលច្បាប់បានកំណត់។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវសារណាក្រោមប្រធានបទ **សន្តតិកម្មតាមមតកសាសន៍** ទាំងមូលរួចមក ក្នុងនាមយើងខ្ញុំជានិស្សិតផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងប្រជាពលរដ្ឋកម្ពុជា យើងខ្ញុំសូមចូលរួមផ្តល់អនុសាសន៍ខ្លះៗ ក៏ដូចជាចំណុចខ្វះខាតមួយចំនួនដែលពួកយើងមើលឃើញនៅក្នុងប្រធានបទមួយនេះក្នុងគោលបំណងចង់ឱ្យសិស្សនិស្សិត ព្រមទាំងប្រជាពលរដ្ឋទាំងអស់គប្បីយល់ដឹងបន្ថែមអំពីច្បាប់ដែលបានចែងក្នុងក្រមរដ្ឋប្បវេណីបន្ថែមពីការតាក់តែងមតសាសន៍ និងនីតិវិធី ក៏ដូចជាបែបបទនៃការធ្វើសន្តតិកម្មតាមមតកសាសន៍នេះ។ ដោយសង្កេតឃើញថា បញ្ហាទម្រង់នៃការតាក់តែងលិខិតមតកសាសន៍មិនទាន់យល់ដឹងឱ្យកាន់តែទូលំទូលាយនៅឡើយ វាជាបញ្ហាដែលនៅពេលមតកជនបានទទួលមរណភាព បែរជាបណ្តាំនោះគ្មានអានុភាព ដោយសារខុសទម្រង់ ឬលក្ខខណ្ឌណាមួយក្នុងពេលតាក់តែងមតកសាសន៍នោះ។ ទោះបីជាយ៉ាងណាបន្ទាប់ពីបានសិក្សាទៅលើប្រធានបទខាងលើរួចមក យើងខ្ញុំសូមស្នើសុំផ្តល់ជាអនុសាសន៍មួយចំនួនដែលជាការចូលរួមចំណែក ជាយោបល់ដើម្បីឱ្យរបបស្តីពីសន្តតិកម្មតាមមតកសាសន៍នេះ ទទួលបានការចាប់អារម្មណ៍ពីអ្នកសិក្សាច្បាប់ អ្នកប្រកបវិជ្ជាជីវៈ និងប្រជាពលរដ្ឋទូទៅដើម្បីធ្វើការត្រិះរិះពិចារណាបន្ថែមឈានទៅរកការវិវឌ្ឍន៍កាន់តែប្រសើរជាងនេះទៅទៀត ដែលអនុសាសន៍ទាំងនោះរួមមាន ៖

✓ ករណីមតកសាសន៍ដោយលិខិតឯកជន ឬ លិខិតសម្ងាត់ ៖ គឺទម្រង់លិខិតទាំងនេះច្បាប់បានអនុញ្ញាតឱ្យមតកជនអាចធ្វើបានដោយខ្លួនឯងផ្ទាល់ ជាហេតុដែលការការតាក់តែងឡើងរបស់គាត់អាចមិនបានគោរពទៅតាមខ្លឹមសារច្បាប់ ឬ ទម្រង់នោះទេ ដោយមូលហេតុនៃចំណេះដឹង ជាពិសេសក៏ត្រូវមានការយល់ដឹងអំពីច្បាប់ពាក់ព័ន្ធផងដែរ។ ដូច្នេះវាអាចមានការបំពានលើភាគបម្រុងជាអាទិ៍ ដូច្នេះគួរគប្បីពិនិត្យលទ្ធភាពក្នុងការបង្កើតបទដ្ឋានគតិយុត្តដែលអាចផ្តល់ ភាពងាយស្រួលដល់មតកជន ដូចជាការកំណត់នូវតម្លៃ ក៏ដូចជាការវាយតម្លៃទ្រព្យសម្បត្តិជាក់លាក់ ដែលអាចធ្វើការបង្ហាញឆន្ទៈដោយសេរីរបស់មតកជន ដោយមិនចាំបាច់អនុវត្តរបបភាគបម្រុងនោះទេ ដោយមូលហេតុ ទ្រព្យសម្បត្តិមានតម្លៃតិចតួចនាំឱ្យមានបញ្ហាស្មុគស្មាញ តែបើករណីដែលទ្រព្យសម្បត្តិមានច្រើន និងមានតម្លៃ គឺចាំបាច់ត្រូវឱ្យមានការអនុវត្តរបបភាគបម្រុងនេះជាដាច់ខាត ពីព្រោះវាជាបញ្ហាដ៏សំខាន់ដែលអាចមានការរំលោភទៅលើរបបភាគបម្រុងធ្ងន់ធ្ងរ។

✓ នីតិវិធីក្នុងការអនុវត្តមតកសាសន៍ ៖ ចំពោះសកម្មភាពរបស់អ្នកអនុវត្តមតកសាសន៍ នៅពេលកំណត់អំពីការបែងចែកចំណែកតាមខ្លឹមសារនៃមតកសាសន៍រួចរាល់ គួរកំណត់យ៉ាងជាក់លាក់ថា ត្រូវស្នើសុំដីកាសម្រេច និងរូបមន្តអនុវត្តពីតុលាការ លើខ្លឹមសារទាំងស្រុងតែម្តង។

✓ មតកសាសន៍ដោយលិខិតយថាភូត ៖ ដោយហេតុថា មានតែសារការីប៉ុណ្ណោះដែលទទួលបានសិទ្ធិអំណាចពីរដ្ឋ និងច្បាប់ ក្នុងការតាក់តែងមតកសាសន៍ជាលិខិតយថាភូត និង មានសិទ្ធិចេញនូវរូបមន្តអនុវត្ត

ដោយមិនចាំបាច់ឆ្លងកាត់ការបញ្ជាក់ ឬ នីតិវិធីនានាតាមផ្លូវតុលាការ ព្រោះច្បាប់បានផ្តល់ឱ្យនូវសិទ្ធិអំណាច និង សន្មតថា សារការីជាមន្ត្រីវិជ្ជាជីវៈជំនាញផ្នែកច្បាប់ ដូច្នេះសារការីដើរតួនាទី និងជាអ្នកអនុវត្តបាននូវកិច្ចការក្នុងការ តាក់តែងលិខិតមតកសាសន៍ទាំងស្រុង។ ដោយហេតុថាមតកសាសន៍ដោយលិខិតយថាភូត មានភាពច្បាស់លាស់ និង ងាយស្រួលក្នុងការអនុវត្តជាងទម្រង់មតកសាសន៍នានា ដូច្នេះដើម្បីជាភាពងាយស្រួល និងទាក់ទាញការ ចាប់អារម្មណ៍អតិថិជន ក៏ដូចជាសាធារណៈជនទទួលទូទៅទទួលមកទទួលសេវាកម្មនេះ គួរតែកំណត់នូវតម្លៃ សេវាកម្មច្បាស់លាស់មានលក្ខណៈទូទៅ ដូចជាសេវាសាធារណៈ ដើម្បីធានាតម្លាភាព និងគណនីភាពជូន ចំពោះអ្នកដែលប្រើប្រាស់សេវានោះ។

✓ បច្ចុប្បន្នកម្ពុជាមានសារការីជាច្រើន បានបំពេញមុខងាររបស់ខ្លួននៅតាមមន្ទីរសារការីជាច្រើននៅទី ក្រុងភ្នំពេញ ទន្ទឹមនឹងនេះចំពោះការបំពេញមុខងាររបស់សារការីកម្ពុជាមិនទាន់មានបទដ្ឋានគតិយុត្តដែលរឹងមាំ ក្នុងការត្រួតពិនិត្យមុខងាររបស់សារការីនៅតាមមន្ទីរសារការីនីមួយៗនៅឡើយ។ ដូច្នេះ រដ្ឋ ឬស្ថាប័នដែលមាន សមត្ថកិច្ចគួរតែចូលរួមក្នុងការធ្វើសេចក្តីព្រាង ការរៀបចំ និងការអនុម័តច្បាប់ស្តីពីលក្ខន្តិកៈសារការីបន្ថែមដើម្បី ត្រួតពិនិត្យមុខងាររបស់សារការីឱ្យមានភាពរឹងមាំព្រមទាំងមានភាពឈ្លាសវៃដោយឈរលើគោលការណ៍នៃការ ទទួលខុសត្រូវចំពោះមុខច្បាប់។

ជាកិត្តិយសរបស់យើងខ្ញុំសូមធ្វើការបង្ហាញពីទឹកចិត្តក្នុងការតម្រែតម្រង់ទិស ក៏ដូចជាសំណូមពរដល់ ក្រសួងស្ថាប័ន បណ្តាភាគីពាក់ព័ន្ធទាំងអស់ ស្ថាប័នតុលាការ និងសារការី ពិសេសប្រជាពលរដ្ឋគ្រប់រូប ត្រូវតែ ចូលរួមអនុវត្ត និងលើកតម្កើងប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់ខ្លួនឱ្យមានដំណើរការប្រកបទៅដោយភាពងាយស្រួល និងមិនស្មុគស្មាញ។ ម្យ៉ាងវិញទៀត អាចធានាទៅលើរាល់ការធ្វើបណ្តាំតាមរយៈលិខិតមតកសាសន៍ឱ្យមាន ភាពត្រឹមត្រូវដោយគោរពទៅតាមទម្រង់ដែលច្បាប់បានចែងកំណត់។ ទោះបីជាច្បាប់បានកំណត់ក៏ដោយ ចំពោះ ការតាក់តែងមតកសាសន៍ សារការីត្រូវតែអនុវត្តការងាររបស់ខ្លួនឱ្យមានភាពយុត្តិធម៌ ប្រកបដោយគុណប្រយោជន៍ ទៅដល់ភាគី ពិសេសចូលរួមផ្សព្វផ្សាយឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដល់បណ្តាសាធារណៈជន ចៀស វាងការទទួលស្គាល់បាននូវភាពមិនសមប្រកប ក៏ដូចជាបំណងរបស់ម្ចាស់បណ្តាំ មិនយល់ពីផ្លូវច្បាប់ ដែលនាំឱ្យ ប្រទេសយើងជះឥទ្ធិពលណាមួយប៉ះពាល់ទៅដល់សង្គមជាតិ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ យើងខ្ញុំសូមអរគុណ យ៉ាងជ្រាវជ្រៅពីសំណាក់អ្នកសិក្សាពីគ្រប់មជ្ឈដ្ឋានដែលបានយកចិត្តទុកដាក់ តាមដានចំពោះការបកស្រាយទៅ លើប្រធានបទខាងលើនេះជាទីគាប់ប្រសើរ តាំងពីពេលចាប់ផ្តើមនៃប្រធានបទរហូតឈានមកដល់ការបញ្ចប់។ យើងខ្ញុំសង្ឃឹមថាសារណាមួយនេះនឹងបានផ្តល់ជាចំណេះដឹងបន្ថែម និងបំពេញនូវចំណុចពាក់ព័ន្ធ ឬ ខ្វះខាត ស្តីពីការធ្វើសន្តតិកម្មតាមមតកសាសន៍ពីមួយដំណាក់កាលទៅមួយដំណាក់កាលរហូតដល់មតកសាសន៍នោះ មានអានុភាពឈានទៅរកការបែងចែកទៅតាមចំណែកដែលមតកជនកំណត់ទៅឱ្យសន្តតិជនម្នាក់តាមឆន្ទៈ

ផ្ទាល់របស់មតកជន។ ជាពិសេសជួយការពារផលប្រយោជន៍ ក៏ដូចជាធានាឱ្យបាននូវ យុត្តិធម៌សមភាពចំពោះមុខច្បាប់ ព្រមទាំងគោលការណ៍នៃសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗ ដោយមិនមានការរំលោភបំពានក្នុងគោលបំណងទុច្ចរិតទៅលើចំណែកអ្វីមួយរបស់ជនណាម្នាក់។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០២១ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧

## ២. ឯកសារផ្សេងទៀត

- សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨-៩ រៀបរៀងដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ភ្នំពេញ ២០១០
- នីតិរដ្ឋប្បវេណី១ គម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជា ឧបត្ថម្ភដោយអង្គការ JICA សមិទ្ធិផលរបស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ៣ រៀបរៀងដោយក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមចៅក្រម ឆ្នាំ២០១៧
- សៀវភៅមេរៀនស្តីពី ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ រៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៥
- សេចក្តីផ្តើមនីតិរដ្ឋប្បវេណី និពន្ធដោយៈ សាស្ត្រាចារ្យ ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ បោះពុម្ពលើកទី៥ ភ្នំពេញ ២០១១
- សៀវភៅមេរៀនស្តីពី ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ៣ រៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៧

- សៀវភៅមេរៀនសង្ខេប នីតិរដ្ឋប្បវេណី របស់សាស្ត្រាចារ្យ មេធាវី អ៊ុំ ប៉ូលី ឆ្នាំ២០១១
- សៀវភៅជំនួយស្មារតី នីតិបេតិកភណ្ឌ និង គ្រួសារ របស់សាស្ត្រាចារ្យ ព្រុំ រិទ្ធី
- សៀវភៅមេរៀនសង្ខេប នីតិសន្តតិកម្ម របស់សាស្ត្រាចារ្យ ជ័យ រិទ្ធី
- សន្ទានុក្រមផ្នែក រដ្ឋប្បវេណី។

# ឧបសម្ព័ន្ធ

(គំរូលិខិតមតកសាសន៍)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតមតកសាសន៍

## ម្ចាស់បណ្តាំ

- នាម-គោត្តនាម ៖...............................ភេទ៖......................ជនជាតិ៖
 ....................................
- ថ្ងៃខែឆ្នាំកំណើត៖..........................................មុខរបរ៖........................................................
- ទីកន្លែងកំណើត៖..........................................................................................................
- ឪពុកឈ្មោះ៖...........................................ម្តាយឈ្មោះ
 ......................................................
- ស្ថានភាពគ្រួសារ៖
 ..............................................................................................................
- អត្តសញ្ញាណប័ណ្ណលេខ៖
 ....................................................................................................
- សៀវភៅគ្រួសារលេខ៖
 ........................................................................................................
- ទីលំនៅនបច្ចុប្បន្ន៖ផ្ទះលេខ..........ផ្លូវ................ភូមិ..............សង្កាត់..............ខណ្ឌ
 ....................រាជធានី/ខេត្ត.................។

## អច្ច័យលាភី

- នាម-គោត្តនាម ៖...............................ភេទ៖......................ជនជាតិ៖
 ....................................
- ថ្ងៃខែឆ្នាំកំណើត៖..........................................មុខរបរ៖........................................................
- ទីកន្លែងកំណើត៖..........................................................................................................
- ឪពុកឈ្មោះ៖...........................................ម្តាយឈ្មោះ
 ......................................................
- ស្ថានភាពគ្រួសារ៖
 ..............................................................................................................

- អត្តសញ្ញាណប័ណ្ណលេខ៖ .............................................................................................................
- សៀវភៅគ្រួសារលេខ៖ ....................................................................................................................
- ទីលំនៅបច្ចុប្បន្ន៖ផ្ទះលេខ..........ផ្លូវ................ភូមិ..............សង្កាត់...............ខណ្ឌ ....................រាជធានី/ខេត្ត.................។

**សាក្សីទី១៖**

- នាម-គោត្តនាម ៖...............................ភេទ៖.....................ជនជាតិ៖ .......................................
- ថ្ងៃខែឆ្នាំកំណើត៖..........................................មុខរបរ៖......................................................
- ទីកន្លែងកំណើត៖......................................................................................................................
- ឪពុកឈ្មោះ៖.............................................ម្តាយឈ្មោះ ..........................................................
- ស្ថានភាពគ្រួសារ៖ .........................................................................................................................
- អត្តសញ្ញាណប័ណ្ណលេខ៖ .............................................................................................................
- សៀវភៅគ្រួសារលេខ៖ ....................................................................................................................
- ទីលំនៅបច្ចុប្បន្ន៖ផ្ទះលេខ..........ផ្លូវ................ភូមិ..............សង្កាត់...............ខណ្ឌ ....................រាជធានី/ខេត្ត.................។

**សាក្សីទី២៖**

- នាម-គោត្តនាម ៖...............................ភេទ៖.....................ជនជាតិ៖ .......................................
- ថ្ងៃខែឆ្នាំកំណើត៖..........................................មុខរបរ៖......................................................
- ទីកន្លែងកំណើត៖......................................................................................................................
- ឪពុកឈ្មោះ៖.............................................ម្តាយឈ្មោះ ..........................................................
- ស្ថានភាពគ្រួសារ៖ .........................................................................................................................

- អត្តសញ្ញាណប័ណ្ណលេខ៖
  ..............................................................................................................
- សៀវភៅគ្រួសារលេខ៖
  ...................................................................................................................
- ទីលំនៅនបច្ចុប្បន្នះផ្ទះលេខ..........ផ្លូវ................ភូមិ...............សង្កាត់...............ខណ្ឌ
  ....................រាជធានី/ខេត្ត..................។

សាក្សីបានអះអាងថាមិនមែនជាញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្ដាំ។

**សារការីផ្តល់លិខិតយថាភូតលើលិខិតមតកសាសន៍**

ឈ្មោះ.....................ជាសារការី និងជា....(សមាសភាព និងនាករណ៍ស្ថាប័ន).........មានអាស័យដ្ឋាននៅផ្ទះលេខ..........ផ្លូវ................ភូមិ...............សង្កាត់...............ខណ្ឌ...................រាជធានី/ខេត្ត..................។

**I-អត្ថន័យនៃបណ្ដាំ**

..................................................................................................................................................................................................................................................................................................................................................................................................................................................................

**II-សេចក្តីអះអាងរបស់សាក្សី**

..........................................................................................................................................................................................................................................................................................................................................................................................................................................................................................................................................................................................................

III-អ្នកទទួលអច្ច័យទាន (ករណីដែលមានការចូលរួមពីសំណាក់អច្ច័យលាភី)

..................................................................................................................................................................................................................................................................................................................................................................................................................................................................

IV-ការរៀបចំ និងការផ្ដិតមេដៃលើលិខិតមតកសាសន៍

........................................................................................................................................................
........................................................................................................................................................
........................................................................................................................................................
......................

ហត្ថលេខាម្ចាស់បណ្ដាំ ស្នាមមេដៃស្ដាំអច្ច័យលាភី

.................................. ..................................

ស្នាមមេដៃស្ដាំសាក្សីទី១ ស្នាមមេដៃស្ដាំសាក្សីទី២

.................................. ..................................

**លិខិតមតកសាសន៍នេះ ត្រូវបានពិនិត្យ និងធ្វើការបញ្ជាក់**
**ជាលិខិតយថាភូតដោយចុះបញ្ជី**

**លេខ**..................................................
**នៅមន្ទីសារការី**....................................
**ក្រោមការទទួលខុសត្រូវរបស់**
**សារការី**................................................

**មានខ្លឹមសារបញ្ជាក់ដូចតទៅ ៖**

**១.សារការីបានពិនិត្យឯកសារច្បាប់ដើម្បមាន៖**

........................................................................................................................................................
........................................................................................................................................................
........................................................................................................................................................
......................

**២.សារការីបានធ្វើការកត់សម្គាល់បញ្ជាក់ឆន្ទៈរបស់ភាគីពាក់ព័ន្ធថា៖**

.......................................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

......................

**៣.អត្ថបទច្បាប់**

.......................................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

......................

**៤.មន្ទីសារការី......................ទទួលលិខិតមតកសាសន៍នេះ តាមសំណើររបស់ម្ចាស់បណ្តាំតាមនីតិវិធីច្បាប់។**

លិខិតមតកសាសន៍នេះមានសុពលភាពអនុវត្ត
ចាប់ពីថ្ងៃ..........ខែ........ឆ្នាំ..........សំរិទ្ធិស័ក ព.ស.............
ត្រូវនឹងថ្ងៃទី............ខែ..........ឆ្នាំ................

(ហត្ថលេខា និងត្រា)
(ឈ្មោះសារការី)

**គម្រូវលិខិតបណ្តាំមត៌ក**

(លិខិតបណ្តាំតាមទម្រង់លិខិតឯកជន)

មត្រា១១៧៤

## ១. អត្តសញ្ញាណរបស់ម្ចាស់បណ្តាំ (មតកជន)

ឈ្មោះ............................................................................................ .............
.......................................................................................................................................
..................................................................................................................................។

(ចំណុចនេះអាចបញ្ជាក់អំពីសមត្ថភាពរបស់បុគ្គលដែលអាចធ្វើមតកសាសន៍)

មាត្រា១១៦៨

## ២. ស្ថានភាពពេលកំពុងសរសេរមតកសាសន៍

ខ្ញុំសរសេរបណ្តាំមត៌កនេះ ក្នុងស្ថានភាពដែលខ្ញុំមានស្មារតី ល្អ ដឹងច្បាស់ពីអ្វីដែលខ្ញុំ កំពុងតែចាត់ចែង ហើយអ្វីដែលខ្ញុំសរសេរនៅក្នុងបណ្តាំមត៌កនេះ ជាគោលបំណងរបស់ខ្ញុំ នៅពេលដែលខ្ញុំទទួលមរណភាព ។

(ចំណុចនេះ បញ្ជាក់អំពីសមត្ថភាពរបស់ម្ចាស់បណ្តាំនាពេលធ្វើលិខិតបណ្តាំ)

មាត្រា១១៦៩

## ៣. បុគ្គលដែលត្រូវទទួលមត៌ក

អ្នកដែលត្រូវទទួលមត៌ករបស់ខ្ញុំ គឺ កូន... ........................(បញ្ជាក់អំពីអត្តសញ្ញាណរបស់ជនដែលត្រូវទទួលមត៌ក) ។

## ៤. បញ្ជាក់អំពីទំហំនៃទ្រព្យសម្បត្ត

ដីទី១ ដីទី២ ដីទី៣ ដីទី៤ (អត្តសញ្ញាណនៃដី) លុយ (លេខគណនី ឈ្មោះធនាគារ.....) គ្រឿងអលង្កា សិទ្ធិលើបំណុល (ថ្លៃឈ្នួល ភាគហ៊ុន..........) សុរបទាំងអស់ ....................បំណុល ...............................................................................។

## ៥. កំណត់អំពីចំណែកមត៌ក ឬ វិធីបែងចែកមត៌ក

ដីទី១ដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យ កូន A

លុយចំនួន......កំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូន B

ធ្វើអច្ច័យទាន នូវគ្រឿងអលង្ការដែលមានកំណត់នៅក្នុងចំណុចទី៤ ឲ្យទៅកូន A

ភាគហ៊ុនដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូនA ២០ ភាគរយចំនួន កូនB ២០ភាគរយ កូនC ៦០ភាគរយ ។

ដីទី២ ដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូនD ប្រសិនបើ D រៀបការ

(មតកសាសន៍ដែលភ្ជាប់លក្ខខណ្ឌបង្អង់)

មាត្រា១១៩៤

## ៦. កំណត់អ្នកប្រតិបត្តិមតកសាសន៍

មេធាវី ............................................ជាអ្នកប្រតិបត្តិមតកសាសន៍ ដោយទទួលបានកម្រៃ ..........................................។

## ៧. ផ្ដាច់មត៌ក

កូន E មិនទទួលបានចំណែកមត៌ករបស់ខ្ញុំទេ ពីព្រោះ កូន ប្រមាថមើលងាយខ្ញុំ ធ្វើឲ្យខ្ញុំពិបាកចិត្តគ្រប់ពេល

(មាត្រា១១៥២)

## ៨. អច្ច័យទាន

ដីទី៣ ដែលមានកំណត់នៅក្នុងចំណុចទី៤ ខ្ញុំប្រគល់ឲ្យG ជាក្មួយរបស់ខ្ញុំ ប៉ុន្តែដីនោះ ត្រូវគ្រប់គ្រងដោយ ប្អូនស្រីរបស់ខ្ញុំ ...................រហូតដល់ ក្មួយរបស់ខ្ញុំមាននីតិភាព ។

(មាត្រា១១៨៤)

## ៩. ចំនួន ការរក្សាទុក បើក និងប្រកាសបណ្ដាំមត៌ក

បណ្ដាំមត៌កច្បាប់ដើម ធ្វើឡើងចំនួន១ ច្បាប់

បណ្ដាំមត៌កច្បាប់ដើម រក្សាទុកនៅការិយាល័យមេធាវី.....................

បណ្ដាំមត៌កនេះ អាចបើកបាន ២ខែ ក្រោយពេលខ្ញុំទទួលមរណភាព

បណ្ដាំមត៌កនេះ ត្រូវប្រកាស នៅផ្ទះរបស់ខ្ញុំ .....................................................................

## ១០. បណ្ដាំចុងក្រោយរបស់ម្ចាស់បណ្ដាំ

ឪពុកសង្ឃឹមថាកូនចេះស្រលាញ់គ្នា មិនធ្វើបាបគ្នា មិនយកទ្រព្យជាត្រីមុខ បំភ្លេចញាតិភាព ធ្វើឲ្យគ្រួសារក្លាយជាអព្វមង្គល ក្រោយពេលឪពុកស្លាប់។

អ្វីៗដែលឪពុកធ្វើគឺដើម្បីកូន ហើយសង្ឃឹមថាកូនៗ នឹងរស់នៅប្រកបដោយ សុភមង្គល និងបានប្រើប្រាស់ទ្រព្យនេះជាដើមទុន សម្រាប់ជីវភាពទៅអនាគត តាមការចាត់ចែងរបស់ម្ដាយកូន។

(មាត្រា១១៨៧)

**ម្ចាស់បណ្ដាំ**

**ហត្ថលេខារបស់ម្ចាស់បណ្ដាំ និងចុះកាលបរិច្ឆេទ**

មាត្រា១១៧៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតបន្ទេរកេរសាសន៍
# និងការប្រគល់សិទ្ធិឲ្យចាត់ចែងទ្រព្យបណ្តោះអាសន្ន

**ម្ចាស់បណ្ណាំ និងជាអ្នកប្រគល់សិទ្ធិ**

- នាម-គោត្តនាម ៖ **ម្ចាស់បណ្ណាំ** ភេទ៖ប្រុស ជនជាតិ៖ ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ០៧-០៥-១៩៣៧ មុខរបរ៖ ៣
- ទីកន្លែងកំណើត ៖ សង្កាត់ លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ ៖ **វៀ ឡាំ** ម្តាយឈ្មោះ៖ **ឡាំ**
- ស្ថានភាពគ្រួសារ ៖ ពោះម៉ាយពីខ្មោចនាង **តាំង ស៊ីមទៀង** និងមានកូន០៧នាក់
- អត្តសញ្ញាណប័ណ្ណលេខ៖ ០១០៤២៦៨៨៣ (០១)
- សៀវភៅគ្រួសារលេខ៖០១.០២៥១៨២ ចុះថ្ងៃទី១៥-១០-២០១០
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ១៦៩ ផ្លូវម៉ៅសេទុង ភូមិ០៥ សង្កាត់ទួលស្វាយ ព្រៃទី១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ។

**អ្នកទទួលអច្ច័យទាន និងជាអ្នកទទួលសិទ្ធិ**

- នាម-គោត្តនាម ៖ **សន្តិជន** ភេទ៖ប្រុស ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ០១-០៦-១៩៦២ មុខរបរ៖ពាណិជ្ជករ
- ទីកន្លែងកំណើត ៖ សង្កាត់លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ ៖ **ម្ចាស់បណ្ណាំ** ម្តាយឈ្មោះ៖ **តាំង ស៊ីមទៀង**(ស្លាប់)
- ស្ថានភាពគ្រួសារ ៖ ប្រពន្ធឈ្មោះ **ជាសារី** កូន៣នាក់
- កំរិតវប្បធម៌៖ ថ្នាក់ទីបញ្ចប់
- កាន់អត្តសញ្ញាណប័ណ្ណ០១០៧១៨៧២៦(០១)
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ១៦៩ ផ្លូវម៉ៅសេទុង ភូមិ០៥ សង្កាត់ទួលស្វាយ ព្រៃទី១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ។

**សាក្សីទី១៖**

- នាម-គោត្តនាម ៖ ជា ស៊ីថា ភេទ៖ប្រុស ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ០៧-១០-១៩៥២ មុខរបរ៖ ពាណិជ្ជករ
- ទីកន្លែងកំណើត ៖ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល
- ឪពុកឈ្មោះ ៖ ជា លី ម្តាយឈ្មោះ ៖ **ឌូវ**
- ស្ថានភាពគ្រួសារ ៖ ពោះម៉ាយ កំរិតវប្បធម៌៖ ថ្នារ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ ០១០១៤៨០៤៨(០១)

- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ២២៦អ៊ី០ ផ្លូវ៣៥៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សាក្សីទី២៖**

- នាម-គោត្តនាម ៖ **លាង ស្រីមុច** ភេទ៖ស្រី ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ១០/០៣/១៩៨១ មុខរបរ៖ពាណិជ្ជករ
- ទីកន្លែងកំណើត ៖ សង្កាត់លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ ៖ **លាង វ៉ាន់ធុន** ម្តាយឈ្មោះ ៖ **ឈឿង យ៉ុង**
- ស្ថានភាពគ្រួសារ ៖ មានគ្រួសារ កំរិតវប្បធម៌ ៖ បរិញ្ញាប័ត្រ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ ០១០៦៧៥២០៣(០១)
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ២២៨ ផ្លូវលេខ៣៥៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

សាក្សីបានអះអាងថាមិនមែនជាញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្តាំ ។

**សារការីផ្តល់យថាភូតលើលិខិតយថាភូតសាសន៍**

បណ្ឌិត ( **ជាសារការី និងជាប្រធានមន្ទីរសារការី (** មានអាសយដ្ឋាននៅផ្ទះលេខ ១៣៥ CD ផ្លូវ១៩៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។
ទូរស័ព្ទការិយាល័យ ( អ៊ីម៉ែល៖

**I-អត្ថន័យនៃបណ្តាំ និងការប្រគល់សិទ្ធិ**

ម្ចាស់បណ្តាំ និងជាអ្នកប្រគល់សិទ្ធិឲ្យគ្រប់គ្រងចាត់ចែងបណ្តោះអាសន្នរួមទាំងបំណុល និងពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់ខ្លួន បានប្រកាសជាឱឡារិកជម្រាបជូន **សារការី** នូវទ្រព្យសម្បត្តិដែល ជាកម្មវត្ថុនៃបណ្តាំ និងការប្រគល់សិទ្ធិរបស់ខ្លួនរួមមាន៖

ទ្រព្យសម្បត្តិផ្ទាល់ខ្លួន

១ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ទទួលស្គាល់ដោយម.រ.ជ.ន.ស **រាជធានីភ្នំពេញ**

២ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ៖** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ទទួលស្គាល់ដោយម.រ.ជ.ន.ស **រាជធានីភ្នំពេញ**

៣ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ៖** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ទទួលស្គាល់ដោយម.រ.ជ.ន.ស **រាជធានីភ្នំពេញ**

៤ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ** ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ទទួលស្គាល់ដោយម.រ.ជ.ន.ស **រាជធានីភ្នំពេញ**

៥ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ

ទទួលស្គាល់ដោយម.រ.ដ.ន.ស រាជធានីភ្នំពេញ

៦ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ

ទទួលស្គាល់ដោយម.រ.ដ.ន.ស រាជធានីភ្នំពេញ

៧ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ

ទទួលស្គាល់ដោយម.រ.ដ.ន.ស រាជធានីភ្នំពេញ

៨ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ

ទទួលស្គាល់ដោយម.រ.ដ.ន.ស រាជធានីភ្នំពេញ

៩ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ

ទទួលស្គាល់ដោយម.រ.ដ.ន.ស រាជធានីភ្នំពេញ

១០- វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ

ទទួលស្គាល់ដោយម.រ.ដ.ន.ស រាជធានីភ្នំពេញ

១១- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ

ដោយម.រ.ដ.ន.ស ខេត្តស្វាយរៀង

១២- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ

ទទួលស្គាល់ដោយម.រ.ដ.ន.ស ខេត្តកណ្ដាល

១៣- លិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ របស់ឈ្មោះ ចុះ

ទទួលស្គាល់ដោយ

១៤- លិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ របស់ឈ្មោះ ចុះ

ទទួលស្គាល់ដោយ

១៥- លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ របស់ឈ្មោះ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

១៦- លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ របស់ឈ្មោះ

ចុះថ្ងៃទី ទទួលស្គាល់ដោយ

ទ្រព្យសម្បត្តិសហកម្មសិទ្ធិ

១ - ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

២ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

៣ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៤ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៥ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៦ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៧ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៨ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៩ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

១០- វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

**ទ្រព្យសម្បត្តិជាក្រុមហ៊ុន**

**អាជីវកម្ម ក្រុមហ៊ុន**

ម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈជាចុងក្រោយនៅចំពោះមុខសាក្សីមានខ្លឹមសារ ច្បាស់លាស់ថា ម្ចាស់បណ្តាំបានសម្រេចចិត្តធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិជាកម្មសិទ្ធិ និងសហកម្មសិទ្ធិរបស់ខ្លួនដែលមានទំហំ ទីតាំង និងមានឯកសារសម្គាល់ដូចបានបញ្ជាក់ខាងលើនេះ ឲ្យទៅអ្នកទទួលអច្ច័យទានដូចមានអត្តសញ្ញាណខាងលើ ធ្វើជាម្ចាស់កម្មសិទ្ធិ កាន់កាប់ទ្រព្យរបស់ខ្លួនបន្តបន្ទាប់ពីម្ចាស់បណ្តាំទទួលមរណភាព ។ ដោយឡែកចំពោះស្ថានភាពបច្ចុប្បន្នម្ចាស់បណ្តាំស្ថិតនៅក្នុងស្ថានភាពសុខភាពពុំល្អ ហេតុនេះបានសម្រេចចិត្តប្រគល់សិទ្ធិឲ្យអ្នកទទួលអច្ច័យទាន មានសិទ្ធិគ្រប់គ្រងលើអាជីវកម្មក្រុមហ៊ុន ដោះស្រាយបំណុលរបស់ក្រុមហ៊ុន និងចាត់ចែងលើទ្រព្យសម្បត្តិដើម្បីឲ្យក្រុមហ៊ុនដំណើរការបានល្អ ។ ក្រៅពីនេះម្ចាស់បណ្តាំបានអះអាងថាខ្លួនមានកូនចំនួន ដែលតាមច្បាប់មានសិទ្ធិទទួលមរតកពីខ្លួន ក៏ប៉ុន្តែខ្លួនបានសម្រេចិត្តមិនធ្វើការបែងចែកបណ្តាំតាមច្បាប់ទេ គឺបែងចែកបណ្តាំតាមឆន្ទៈរបស់ខ្លួនដោយមានមូលហេតុថា កូនទាំង ផ្សេងទៀតមិនព្រមមកជួយការងាររបស់ម្ចាស់បណ្តាំនៅក្នុងប្រទេសកម្ពុជា ហើយរាល់ការងាររបស់ខ្លួនមានតែអ្នកទទួលអច្ច័យទានម្នាក់នេះប៉ុណ្ណោះ ដែលបានបំពេញការងារ ជួយដល់ម្ចាស់បណ្តាំ លើគ្រប់កិច្ចការទាំងអស់ ។

៣ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៤ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៥ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៦ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៧ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៨ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

៩ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

១០- វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី
ទទួលស្គាល់ដោយ

**ទ្រព្យសម្បត្តិជាក្រុមហ៊ុន**

**អាជីវកម្ម ក្រុមហ៊ុន**

ម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈជាចុងក្រោយនៅចំពោះមុខសាក្សីមានខ្លឹមសារ ច្បាស់លាស់ថា"ម្ចាស់បណ្តាំបានសម្រេចចិត្តធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិជាកម្មសិទ្ធិ និងសហកម្មសិទ្ធិរបស់ខ្លួនដែលមានទំហំ ទីតាំង និងមានឯកសារសម្គាល់ដូចបានបញ្ជាក់ខាងលើនេះ ឲ្យទៅអ្នកទទួលអច្ច័យទានដូចមានអត្តសញ្ញាណខាងលើ ធ្វើជាម្ចាស់កម្មសិទ្ធិ កាន់កាប់ទ្រព្យរបស់ខ្លួនបន្តបន្ទាប់ពីម្ចាស់បណ្តាំទទួលមរណភាព ។ ដោយឡែកចំពោះស្ថានភាពបច្ចុប្បន្នម្ចាស់បណ្តាំស្ថិតនៅក្នុងស្ថានភាពសុខភាពពុំល្អ ហេតុនេះបានសម្រេចចិត្តប្រគល់សិទ្ធិឲ្យអ្នកទទួលអច្ច័យទាន មានសិទ្ធិគ្រប់គ្រងលើអាជីវកម្មក្រុមហ៊ុន ដោះស្រាយបំណុលរបស់ក្រុមហ៊ុន និងចាត់ចែងលើទ្រព្យសម្បត្តិដើម្បីឲ្យក្រុមហ៊ុនដំណើរការបានល្អ ។ ក្រៅពីនេះម្ចាស់បណ្តាំបានអះអាងថាខ្លួនមានកូនចំនួន៧នាក់ ដែលតាមច្បាប់មានសិទ្ធិទទួលមរតកពីខ្លួន ក៏ប៉ុន្តែខ្លួនបានសម្រេចចិត្តមិនធ្វើការបែងចែកបណ្តាំតាមច្បាប់ទេ គឺបែងចែកបណ្តាំតាមឆន្ទៈរបស់ខ្លួនដោយមានមូលហេតុថា កូន នាក់ផ្សេងទៀតមិនព្រមមកជួយការងាររបស់ម្ចាស់បណ្តាំនៅក្នុងប្រទេសកម្ពុជា ហើយរាល់ការងាររបស់ខ្លួនមានតែអ្នកទទួលអច្ច័យទានម្នាក់នេះប៉ុណ្ណោះ ដែលបានបំពេញការងារ ជួយដល់ម្ចាស់បណ្តាំ លើគ្រប់កិច្ចការទាំងអស់ ។

ការអនុវត្តលិខិតបតកសាសន៍នេះ នឹងត្រូវធ្វើឡើងដោយ **មន្ទីរសារការី** តាមនីតិវិធីច្បាប់ ដើម្បីឲ្យអច្ច័យទានទាំងអស់តាមម្ចាស់បណ្តាំទៅអ្នកទទួលអច្ច័យទាន ដោយពេញលេញ និងស្របតាមច្បាប់ ។

ម្ចាស់បណ្តាំបានយល់ព្រមផ្តិតមេដៃលើលិខិតបតកសាសន៍នេះ មុកជាភស្តុតាងតាមច្បាប់ នៅចំពោះមុខសារការី ។

**II-សេចក្តីអះអាងរបស់សាក្សី**

សាក្សីទាំងពីររូបមានអត្តសញ្ញាណដូចខាងលើ ដែលបានយល់ព្រមធ្វើជាសាក្សីក្នុងលិខិតមតកសាសន៍ បានអះអាងដោយប្រាកដថា សាក្សីមិនមានជាប់ពាក់ព័ន្ធជាញាតិលោហិតខ្សែផ្ទាល់ជាមួយនឹងម្ចាស់បណ្តាំឡើយ ហើយយល់ព្រមផ្តល់ចម្លើយជាសាក្សីជូនសមត្ថកិច្ចពាក់ព័ន្ធនៅពេលដែលអនុវត្តខ្លឹមសារ នៃលិខិតមតកសាសន៍នេះថាម្ចាស់បណ្តាំពិតជាបានធ្វើបណ្តាំដោយស្ម័គ្រចិត្ត ដោយមានសមត្ថភាពពេញបរិបូរណ៍ ដោយមានសាក្សីដែលជារូបខ្លួនបានចូលរួមដឹងឮដោយផ្ទាល់ប្រាកដមែន។

**III-អ្នកទទួលអច្ច័យទាន**

អ្នកទទួលអច្ច័យទានដែលត្រូវជាកូនបង្កើតជាមួយម្ចាស់បណ្តាំ បានចូលរួម ការធ្វើបណ្តាំនេះ នៅចំពោះមុខសារការី ហើយក៏បានយល់ព្រមផ្តិតមេដៃ និងទទួលយកនូវអច្ច័យទានជាអចលនទ្រព្យខាងលើ រួមទាំងទទួលសិទ្ធិដោះស្រាយ និងចាត់ចែងអាជីវកម្មក្រុមហ៊ុន និងដោះស្រាយបញ្ហាបំណុល រួមទាំងការចាត់ចែងលើទ្រព្យជាបណ្តោះអាសន្នក្នុងពេលបច្ចុប្បន្នតាមខ្លឹមសារ នៃលិខិតបតកសាសន៍នេះដោយពេញចិត្តពីម្ចាស់បណ្តាំ ។

**IV-ការរៀបចំ និងការផ្តិតមេដៃលើលិខិតមតកសាសន៍**

លិខិតមតកសាសន៍នេះ ត្រូវបានរៀបចំឡើងដោយ**មន្ទីរសារការី** ក្រោមការទទួលខុសត្រូវរបស់ លោក ជាសារការី អមដោយលោក ជាលេខាធិការកត់ត្រា និងវាយអក្សរ នៃបណ្តាំនេះ ។ លិខិតនេះ មានចំនួន ០៣ច្បាប់ ជាច្បាប់ដើម ធ្វើឡើងជាភាសាខ្មែរ និងត្រូវបានផ្តល់ជូនម្ចាស់បណ្តាំ ចំនួន ០១ច្បាប់ អ្នកទទួលអច្ច័យទានចំនួន ០១ច្បាប់ និងរក្សាទុកនៅ មន្ទីរសារការី លុច ស៊ីអេចឌី ចំនួន ០១ច្បាប់ សម្រាប់ប្រើប្រាស់តាមច្បាប់តទៅ ។

លិខិតមតកសាសន៍នេះ បន្ទាប់ពីរៀបចំ និងកែសម្រួលខ្លឹមសារច្បាស់លាស់រួច សារការីបានអានឲ្យម្ចាស់បណ្តាំ អ្នកទទួលអច្ច័យទាន និងសាក្សី ស្តាប់ និងអ្នកទាំង អស់គ្នាបានឆ្លើយតបមកវិញ នៅចំពោះមុខសារការីថា ខ្លឹមសារនៃលិខិតបតកសាសន៍ នេះពិតជាត្រឹមត្រូវតាមឆន្ទៈរបស់ខ្លួនទាំងស្រុង ហើយយល់ព្រមផ្តិតមេដៃលើលិខិតមតកសាសន៍នេះ នៅចំពោះមុខសារការី និងបានសរសេរឈ្មោះរបស់ខ្លួន រៀងខ្លួនៗ នៅលើលិខិតមតកសាសន៍នេះ ដោយសារការីបានចុះថ្ងៃខែឆ្នាំចំណាំតទៅ ។

| ស្នាមមេដៃស្តាំអ្នកធ្វើបណ្តាំ | ស្នាមមេដៃស្តាំអ្នកទទួលអច្ច័យទាន |
|---|---|
| ឈ្មោះ **មាស់បណាំ** | **អច្ច័យលាភី** |
| ស្នាមមេដៃស្តាំសាក្សីទី ១ | ស្នាមមេដៃស្តាំសាក្សីទី២ |

លិខិតមរតកសាសន៍នេះ ត្រូវបានពិនិត្យ និងធ្វើការបញ្ជាក់
ជាលិខិតយថាភូតដោយចុះបញ្ជី

**លេខ**
**នៅមន្ទីរសារការី**
ក្រោមការទទួលខុសត្រូវរបស់
**សារការី**

មានខ្លឹមសារបញ្ជាក់ដូចតទៅ ៖

១. សារការីបានពិនិត្យឯកសារច្បាប់ដើមរួមមាន៖
- អត្តសញ្ញាណប័ណ្ណឈ្មោះ: ម្ចាស់បណ្តាំ
- អត្តសញ្ញាណប័ណ្ណឈ្មោះ: អច្ច័យលាភី
- អត្តសញ្ញាណប័ណ្ណឈ្មោះ: សាក្សីទី១
- អត្តសញ្ញាណប័ណ្ណឈ្មោះ: សាក្សីទី២
- សៀវភៅស្នាក់នៅរបស់ឈ្មោះ: ម្ចាស់បណ្តាំ
  ប័ណ្ណកម្មសិទ្ធិជាកម្មវត្ថុ នៃមរតកសាសន៍នេះ

២. សារការីធ្វើការកត់សម្គាល់បញ្ជាក់ឆន្ទៈរបស់ភាគីពាក់ព័ន្ធថា៖

ម្ចាស់បណ្តាំឈ្មោះ: ម្ចាស់បណ្តាំ និងអ្នកទទួលអច្ច័យទានឈ្មោះ: អច្ច័យលាភី រួមទាំងសាក្សីទាំងពីរនាក់ពិតជាបានយល់ព្រមដោយស្ម័គ្រចិត្តផ្តិតមេដៃលើលិខិតមរតកសាសន៍នេះ ទុកជាចំណាំតាមច្បាប់ តាមឆន្ទៈរៀងខ្លួន នៅចំពោះ មុខសារការី។

៣. **អត្ថបទច្បាប់**

សារការីបានបង្កើតលិខិតមរតកសាសន៍នេះ ដោយផ្អែកតាមមាត្រា ១១៦៩ មាត្រា ១១៧០ មាត្រា ១១៧១ មាត្រា១១៧២ មាត្រា ១១៧៣ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៤. **មន្ទីរសារការី** ទទួលអនុវត្តលិខិតមរតកសាសន៍នេះ តាមសំណើរបស់ ម្ចាស់បណ្តាំ និងរបស់អ្នកទទួលអច្ច័យទាន តាមនីតិវិធី និងច្បាប់ ។

៥. ការបង្កើតលិខិតមរតកសាសន៍នេះ អនុឡោមតាមអនុក្រឹត្យលេខ **(អនុក្រឹត ទទួលស្គាល់មន្ទីសារក** របស់រាជរដ្ឋាភិបាលកម្ពុជា ។

លិខិតមតកសាសន៍នេះមានសុពលភាពអនុវត្ត

ចាប់ពីថ្ងៃ ខែ ឆ្នាំ សំរឹទ្ធិស័ក ព.ស ២៥៦២

ត្រូវនឹងថ្ងៃទី ខែ ឆ្នាំ

**មន្ទីសារការី** (នាមករណ៍)

**សារការី**

(ហត្ថលេខា និងត្រា)

(ឈ្មោះ សារការី)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំរូបមន្តអនុវត្ត

ខ្ញុំបាទឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៦២ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ផ្លូវម៉ៅសេងទុង ភូមិ៥ មានទីលំនៅផ្ទះលេខ១៦៩ (០១)សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**លោកបណ្ឌិត ទូត លុច សារការីនៃមន្ទីរសារការី លុច ស៊ីអេចឌី**

**កម្មវត្ថុ ៖** ស្នើសុំរូបមន្តអនុវត្តនៃលិខិតមតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់**មន្ទីរសារការី** ។

**យោង ៖** - លិខិតមតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់**មន្ទីរសារការី**

- សំបុត្របញ្ជាក់មរណភាពលេខ.......... ចុះថ្ងៃទី............. របស់ឈ្មោះ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាប **លោកបណ្ឌិតសារការី** មេត្តាជ្រាបថា ឪពុកខ្ញុំបាទឈ្មោះ បានទទួលមរណភាពកាលពីថ្ងៃទី............ វេលាម៉ោង ........ ស្ថិតនៅ.... ។ ដោយហេតុថា ឪពុករបស់ខ្ញុំបាទឈ្មោះ បានធ្វើលិខិតមរតកសាសន៍មានខ្លឹមសារប្រគល់នូវទ្រព្យសម្បត្តិដូចមានចែងនៅក្នុងលិខិតមរតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់**មន្ទីរសារការី** នេះស្រាប់ ។

ដូច្នេះ ខ្ញុំបាទស្នើសុំ **លោកបណ្ឌិតសារការី** មេត្តាផ្តល់ជូននូវរូបមន្តអនុវត្តដល់ខ្ញុំបាទ ដើម្បីយកទៅប្រើប្រាស់តាមនីតិវិធីច្បាប់ ។

សូម **លោកបណ្ឌិតសារការី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ពុទ្ធស័ករាជ ២៥៦៤

ត្រូវនឹងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# រូបមន្តអនុបត្ត

**យើង បណ្ឌិត** **សារការីនៃមន្ទីរសារការី**

-**បានឃើញ** មាត្រា ៣៥០, មាត្រា៣៥៤, មាត្រា៣៥៥, និងមាត្រា៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-**បានឃើញ** អនុក្រឹត្យលេខ ចុះថ្ងៃទី០២-០២-២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជា

-**បានឃើញ** សំបុត្រមរណភាព លេខ..... ចុះថ្ងៃទី..... របស់សាលាសង្កាត់....... បញ្ជាក់អំពីមរណភាព ឈ្មោះ

-**បានឃើញ** លិខិតមតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់ **មន្ទីរសារការី**

-**បានឃើញ** ពាក្យសុំ ចុះថ្ងៃទី២៦-១១-២០២០ របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ស្នើសុំរូបមន្តអនុវត្តលិខិតមតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់ **មន្ទីរសារការី**

**សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុបត្តដូចខាងក្រោម ៖**

**ម្ចាស់បំណុលនៃការអនុបត្ត** ឈ្មោះ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ១៦៩ ផ្លូវម៉ៅសេទុង ភូមិ៥ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**អាចអនុបត្តដោយបង្ខំ** តាមលិខិតមតកសាសន៍ លេខ០១៨/១៩ ចុះថ្ងៃទី២២-០២-២០១៩ របស់ **មន្ទីរសារការី** ។

ពី **កូនបំណុលនៃការអនុបត្ត** ឈ្មោះ

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រាស់បង្គាប់មកស្ថាប័នអនុបត្តដោយបង្ខំ ឱ្យអនុបត្តតាមលិខិតអនុបត្តនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុបត្តឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

ថ្ងៃសុក្រ ៤រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ពុទ្ធស័ករាជ ២៥៦៤

ត្រូវនឹងថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០

**មន្ទីរសារការី**

**សារការី បណ្ឌិត**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ: ១៦៧
ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០០២
<u>សាលដីកា</u>
លេខ: ២៧៩
ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០០៣

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ:

១.ឯកឧត្តម .......... ជាប្រធាន
២.លោក .......... ជាចៅក្រម
៣.លោក ............. ជាចៅក្រម
៤.លោក ............. ជាចៅក្រម
៥.លោក ............. ជាចៅក្រម

<u>ក្រឡាបញ្ជី</u>

.លោក ...................

<u>តំណាងមហាអយ្យការ</u>

.លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៧៧ (ឃ) ចុះថ្ងៃទី២៦ ខែវិច្ឆកា ឆ្នាំ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៤៩ ចុះថ្ងៃទី០៩ខែឧសភា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍:

-រវាងដើមចោទឈ្មោះ១. ថជ(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៦៨ឆ្នាំ ជាតិខ្មែរ

២. ថជ(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ របរកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិព្រៃចក ឃុំគោគគង់ខាងលិច ស្រុកកញ្ច្រៀច ខេត្តព្រៃវែង ។ (ផ្ទេរសិទ្ធិឱ្យថ . ជ )។

.និងចុងចម្លើយឈ្មោះ ថជ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ របរកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៦២Eoz ផ្លូវ១៥៤ ក្រុមទី២៤ សង្កាត់ផ្សារថ្មីទី៣ ខ័ណ្ឌ ដូនពេញ ក្រុងភ្នំពេញ ។

- មេធាវីលោក កចរ

*<u>កម្មវត្ថុបណ្តឹង</u>* ប្តឹងទាមទារដីកេរ្តិ៍មរតក

បានឃើញបណ្តឹងសាទុក្ខលេខ ២២ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ របស់ឈ្មោះ ថជ ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៧៧"ឃ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៦៧ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៦ខែតុលា ឆ្នាំ២០០០ របស់ដើមចោទបានប្តឹងទាមទារចែកដីមួយ កន្លែង និង ដីស្រែស្ថិតនៅភូមិព្រៃចក ឃុំគោគគង់ខាងលិច ស្រុកកញ្ច្រៀច ខេត្តព្រៃវែង ជាទ្រព្យ របស់ម្តាយឈ្មោះ ខ ណ ដែលបានបន្សល់ទុកដីពីរកន្លែងនេះ ក្រោយពីគាត់ស្លាប់ទៅ ពុំទាន់បាន ចែក ឬលក់ឱ្យទៅកូនណាទេ ដោយសុំចែកជា៦ចំណែកស្មើគ្នា ដោយមានឈ្មោះថជមួយចំណែក ដែរ ។ កន្លងមកឈ្មោះថជ មិនព្រមចែក គឺលោកយកតែម្នាក់ឯង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១២ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការ ខេត្តព្រៃវែងដែលមានខ្លឹមសារនៃសេចក្តីសម្រេច ដូចតទៅ:

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះថង ធ ឈ្មោះថ ជ ឈ្មោះថ ណ និង ឈ្មោះ ថ គ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០០ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិ ច្បាប់ លើកលែងតែការប្តឹងរបស់ឈ្មោះថ ផ ត្រូវបដិសេធចោលជាអសារបង់តាមមាត្រា១៧២ នៃច្បាប់ភូមិបាលដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១០០ក្រ ចុះថ្ងៃទី១៣ខែតុលា ឆ្នាំ១៩៩២។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០០របស់ដើមចោទឈ្មោះ ថ ណ និងឈ្មោះ ថ គ ឲ្យទៅឈ្មោះ ថ ធ និង ឈ្មោះថ ជ តែបដិសេធមិនទទួល ស្គាល់ការប្រគល់សិទ្ធិរបស់ឈ្មោះថ ផ ។

៣-បដិសេធលិខិតពាក្យបណ្តឹមគេក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៦ ចោលជាអសារបង់ចាប់ពីពេលនេះទៅ

៤-ទទួលស្គាល់តាមច្បាប់ដីភូមិចាស់តាមគំនូសប្លង់ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០និងដីផលិតកម្មកសិកម្មតាមគំនូសប្លង់ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ តាមលិខិតសំណើលេខ ១២៧-២០០០ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០០ ជាទ្រព្យរបស់ខ្មោចលោកយាយ ខ ណ ចាប់ពីពេលនេះទៅ ។

៥-បដិសេធពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩០ដូចគ្នា ចំនួន២ច្បាប់ របស់ចុងចម្លើយ ឈ្មោះដ ធ ចោលជាអសារបង់ចាប់ពីពេលនេះតទៅ ។

៦-បង្គាប់ឲ្យបែងចែកទ្រព្យរបស់ខ្មោច ខ ណ មានដីភូមិចាស់តាមទំហំនៅក្នុងគំនូសប្លង់ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ និងដីផលិតកម្មកសិកម្មតាមទំហំនៅក្នុងគំនូសប្លង់ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ទៅអោយឈ្មោះ ថ ធ ឈ្មោះថ ជ ឈ្មោះថ គ ឈ្មោះថ ណ និង ឈ្មោះថជ ជា៥ចំណែកស្មើគ្នានៅពេលសាលក្រមចូលជាស្ថាពរ ។

៧-បង្គាប់ឲ្យចុងចម្លើយឈ្មោះថជ បង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តីនិងពហ្មឹងចំនួន១.៨០០រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះចំនួ ៥.០០០រៀល បូករួម៧.០០០រៀល ។ ប្រាក់នេះបានកាត់យកពីប្រាក់៧.០០០រៀល ដែលដើមចោទ បានបង់ទុករួចហើយ កាលបើហួសការប្តឹងឧទ្ធរណ៍បង្គាប់ឲ្យ

ឈ្មោះថជ សងប្រាក់ចំនួន៧.០០០៛ ទៅដើមចោទវិញ។ និងឲ្យចុងចម្លើយ បង់ពន្ធសមាមាត្រលើតំលៃដីមួយភាគរយដែលត្រូវប្រគល់ ឲ្យទៅដើមចោទទាំងអស់ ។ ប្រាក់នេះបង់ចូលថវិការដ្ឋ៨០ភាគរយ និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយ ។

៨-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខកូគាគីទាំងសងខាងសម្រេច បើកផ្លូវឧទ្ធរណ៍រយៈពេល៦០ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមនេះទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ០៣ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់ឈ្មោះ ថជ ប្ដឹងសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១២ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការខេត្ត ព្រៃវែង ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦២-យ- ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅៈ

១-ទទួលបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះថជ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ទុកជា ត្រឹមត្រូវតាមទម្រង់ ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១២ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់ តុលាការខេត្តព្រៃវែង ទុកជាបានការតទៅ ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀលដែលដើមបណ្ដឹង ឧទ្ធរណ៍បានបង់ទុករួច គឺពន្ធចុះបញ្ជីក្ដី ពន្ធហ្នឹង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ចំណាយក្នុងកិច្ចប្រគល់ដីកាកោន ៥.០០០រៀល និងចំណាយលើអាជ្ញាធរតុលាការ៥.០០០រៀលសរុប ១៣០០០៛

៤-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខចុងបណ្ដឹងឧទ្ធរណ៍ កំបាំងមុខដើមបណ្ដឹងឧទ្ធរណ៍ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់លេខ៦៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះ ថជ ប្ដឹងទាស់នឹងសាលដីកាលេខ ៦២ -យ- ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៧-យ- ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅៈ

១-ទទួលបណ្ដឹងទាស់របស់ឈ្មោះថជ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ទុកជា ត្រឹមត្រូវតាមចំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ដំកល់សាលដីកាកំបាំងមុខលេខ៦២-យ- ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០១ របស់ សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្ដឹងទាស់បើកផ្លូវសាទុក្ខក្នុងកំណត់

ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២២ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ របស់ឈ្មោះ ថឹង ជិនប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៧៧-យ- ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះថជ ។

បានឃើញសារណាតប ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះថង ជ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: សូមក្រុមប្រឹក្សាជំនុំជំរះសំរេច តាមច្បាប់ ។

បានស្តាប់ចម្លើយរបស់លោកថជ (ជាម្ចាស់បណ្តឹងសាទុក្ខ)អាយុ៤៧ឆ្នាំ នៅពេលជំនុំជំរះ

ថា: បានជាខ្លួនប្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ មកពីសាលាឧទ្ធរណ៍កាត់ក្តីមិនយុត្តិធម៌ ។

នៅឆ្នាំ១៩៧៩ រដ្ឋបានបែងចែករបបតាមគ្រួសាររៀងៗខ្លួន ខ្លួនរស់នៅជាមួយឪពុកហើយកន្លងមកបងៗបានរុកគួនយកផ្ទះលក់អស់ម្តងហើយ ។ ខ្លួនបានយកម្តាយមកនៅជាមួយ រហូតដល់ស្លាប់ក៏បងៗមិនរវល់មកជួយធ្វើបុណ្យដែរ។ ឆ្នាំ១៩៩០រដ្ឋបានចេញលិខិតកាន់កាប់ដីធ្លីមកឱ្យខ្លួន ។ ខ្លួនសុំធ្វើសំណូមពរសុំកាន់កាប់ដីធ្លីដែលខ្លួនធ្លាប់កាន់កាប់តាំងពីឆ្នាំ១៩៧៩មក គាត់មកបង្ខាំងដីខ្លួន៣ឆ្នាំចោលឥតបានធ្វើអ្វីទេ។ ខ្លួនដឹងក្តីពេលណាគឺខ្លួនរស់នៅជាមួយឪពុកម្តាយរហូត ព្រោះខ្លួនជាកូនពៅ។

ឪពុកខ្លួនបានប្រគល់ផ្ទះឱ្យមកខ្លួន តែបងៗរុកគួនលក់ចែកគ្នាអស់ និង ដោយខ្លាចកូន១ឈ្មោះគ្នាម្តាយ

ខ្លួនក៏បានធ្វើបណ្តាំមរតកចែកមកឱ្យខ្លួន ។ ឆ្នាំ១៩៧៩ ក្រោយរបបប៉ុលពត បងៗមិនមកនៅជាមួយទេ គាត់នៅដោយឡែក ។

បានស្តាប់ចម្លើយរបស់ឈ្មោះថឹង ជាង នៅពេលជំនុំជំរះថា ខ្លួនគឺបងគេបង្អស់ គឺមិនបំបាត់កេរ្តិ៍ទេ ខ្លួនជាបងនិយាយថាត្រូវតែចែកគ្នា ព្រោះកេរ្តិ៍នេះ មិនមែនឪពុកម្តាយខ្លួនទុកតែចែកឱ្យថង ជ ទេ ។ ខ្លួនសុំចែកតែដីស្រែ និងភូមិចាស់ប៉ុណ្ណោះ កេរ្តិ៍ដែលចែកហើយខ្លួនមិននិយាយទេ។ ស្រាប់តែគេយកដីនេះប្រគល់ឲ្យជន្លងគេ គ្រាន់តែខ្លួនបេះផ្លែឈើហូបបន្តិចបន្តួចជន្លងគេជេរខ្លួន និងដឹកក្របីកាត់ក៏មិនបានដែរ ។ មេឃុំត្រូវគេសួរនៅសាលាឧទ្ធរណ៍ ថា បណ្តាំមរតក ផ្តិតមេដៃនឹងចង្កៀងប្រេងកាត ។ ចំពោះបញ្ហាដី គឺស្រុកខ្លួនគេមិនវាស់ចែកគ្នាទេ គឺ ដីកេរ្តិ៍អ្នកណាអ្នកហ្នឹងទទួលម្ចាស់ដីយករៀងៗខ្លួន ម្តាយខ្លួនជួលដីនេះឱ្យគេធ្វើស្រែ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកចរជាមេធាវីការពារចុងចម្លើយ នាពេលសវនាការថា: ដីនេះជាដីកេរ្តិ៍មរតកពីសង្គមចាស់ ថិ ជ និង ម្តាយរស់នៅជាមួយគ្នាលើដីនេះតែម្តង ហើយ ថជ ក៏មានកូនដែរ ហេតុអ្វីបានជាយកដីយាយ ណ និង ថជ មកចែកគ្នា ។ ចំណែកបងៗសុទ្ធតែមានដីដែលរដ្ឋបានចែកឱ្យហើយ ។ ឆ្នាំ១៩៩០ ថជ បានដាក់ពាក្យសុំកាន់កាប់ដីហើយមេឃុំ ខ ហ បានទទួលស្គាល់ ពេលនោះក៏គ្មានអ្នកណាប្តឹងដែរ ដល់ឆ្នាំ២០០០ ទើបប្តឹង ។

សូមឯកឧត្តមប្រធានមេត្តាពិនិត្យពិចារណា និង កាត់ក្តីឱ្យ ថជ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សេចក្តីសន្និដ្ឋានមេធាវីការពារចុងចម្លើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ របស់ឈ្មោះថជ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះនបានតាមមាត្រា១៤នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍បែងចែកដីទំនាស់ជា៥ចំណែកស្មើគ្នានោះ ដោយ សំអាងហេតុថាជាមរតករបស់សពយាយ ខ ណ នោះពុំមានលក្ខណៈត្រឹមត្រូវឡើយ ព្រោះថា ពុំទាន់មានភស្តុតាងណាបញ្ជាក់ច្បាស់លាស់ថា ដីទំនាស់នោះជាកម្មសិទ្ធិផ្តាច់មុខរបស់សពលោកយាយ ខ ណ តែម្នាក់ឯងនោះទេ ។

+ក្រោយឆ្នាំ១៩៧៩ លោកយាយ ខ ណ នឹង កូនឈ្មោះថជ បានចូលមក កាន់កាប់ដីទំនាស់រហូតដល់សព្វថ្ងៃ ហើយឈ្មោះថជ មានពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លីពីកន្លែងចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩០ ទៀតផង ។

- យល់ឃើញថា សាលដីកាលេខ៧៧-យ- ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច សេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី ចំពោះមុខគូភាគី

១. ទទួលបណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៥ ខែមករាឆ្នាំ២០០០ របស់ឈ្មោះថជ ទុកជាត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ ។

២.ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៧៧-យ- ចុះថ្ងៃទី២៦ ខែវិច្ឆិកាឆ្នាំ២០០១របស់ សាលាឧទ្ធរណ៍ទាំងមូល ។

៣. បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៦៧ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០២របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះនជាថ្មីឡើងវិញ ។

៤.រឹបអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះថ ជ បានបង់នៅតុលាការកំពូលចំនួន១៩០០០៛ គឺ

– ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០០៛ សម្រាប់ ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៥.សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ ។

ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ១២៤

ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤　　**គោរពនាមប្រជារាស្ត្រខ្មែរ**

<u>សាលដីកា</u>　　**តុលាការកំពូល**

លេខ : ២៥៤　　បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤

ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤　　ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម　　ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២-លោក　　ជាចៅក្រម

៣-លោក　　ជាចៅក្រម

៤-លោក　　ជាចៅក្រម

៥-លោក　　ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក

តំណាងមហាអយ្យការ

លោក　　ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ១៧៦ "ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤៨២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះថា <u>ន ចា</u> (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ៣២ ក្រុមទី១១៧ មណ្ឌល៨ ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះជំ ហ "រ" ម្តាយឈ្មោះស គ ហ "រ" ប្តីឈ្មោះ ទ ថ ។

មានមេធាវីលោក ស ច ន ជាតំណាង ។

ចុងចម្លើយឈ្មោះ <u>ខ ឈ</u> (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៧៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ៣២ ក្រុមទី១១៧ មណ្ឌល៨ ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

ផ្ទេរសិទ្ធិឱ្យលោក ខ ស ថ ។

មានមេធាវីលោក ផ ព ស ។

ចម្លើយឆ្លើង : ប្តឹងសុំចំណែកលើបណ្តាំមរតករបស់លោក ខ ថ .

បណ្តឹងតប : ប្តឹងសុំបដិសេធលិខិតចែកមរតក ចុះថ្ងៃទី១១-១០-២០០១ .

បានឃើញបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោក ស ច ឌ ជាមេធាវីតំណាងឱ្យឈ្មោះជំ គ ហ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១២៤ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមបណ្តឹងចុះថ្ងៃទី១៣-១២-២០០១ ដើមចោទ អ្នកស្រី ជំ គ ហ ថា : ខ្ញុំនសុំចំណែកលើបណ្តាំមរតក របស់សពលោកតា ខ ថ ចុះថ្ងៃទី១១-១០-២០០១ ដែលបានប្រគល់ឱ្យខ្ញុំនជាប្រពន្ធ និងជាអ្នកបំរើ មើលថែលោកតា ខ ថ និងបានមើលថែជំងឺលោកតា ខ ថ តាំងពីឆ្នាំ១៩៩៨ បានរស់នៅជាមួយគ្នារហូតមក ។ ក្នុងការបំរើលោកតា ខ ថ សព្វសារពើនេះ គាត់តែងនិយាយថា អាណិតស្រលាញ់ខ្ញុំនណាស់ បើគាត់ស្លាប់ទៅ មិនឱ្យខ្ញុំនលំបាកទេ តែខ្ញុំនមិនចាប់អារម្មណ៍ និងសំដីនេះឡើយ ។ នៅថ្ងៃទី១៥-១០-២០០១ លោកតា ខ ថ បានប្រគល់ស្រោមសុំបុត្រ១មកឱ្យខ្ញុំន ដោយប្រាប់ថា នេះជាភស្តុបន្តិចបន្តួច សំរាប់ឱ្យខ្ញុំនចិញ្ចឹមជីវិតបានដោយខ្លួនឯង នៅពេលអត់ពីគាត់ទៅ ដល់ថ្ងៃបន្ទាប់លោកតា ខ ថ មានជំងឺធ្ងន់ ខ្ញុំនក៏បញ្ជូនទៅមន្ទីរពេទ្យកាល់ម៉ែត្រ ដល់ថ្ងៃ២៥-១១-២០០១ វេលាម៉ោង ៦:០០ព្រឹក តា ខ ថ ទទួលមរណៈ-ភាព ខ្ញុំនរៀបចំធ្វើបុណ្យតាមប្រពៃណីដោយមានញាតិមិត្ត បងប្អូនជួយជ្រោមជ្រែង ។

នៅថ្ងៃទី១១-១២-២០០១ ចៅសង្កាត់ស្រះចក បានអញ្ជើញលោកស្រី ព យ ដែលជាប្រពន្ធមុន បានបួសនៅវត្តតាំងពី១០ឆ្នាំមកហើយ និងកូនដើមរបស់តា ខ ថ ចំនួន០៣នាក់ មកស្តាប់នូវសេចក្តីមរតក ពួកគាត់យល់ព្រមតាមសេចក្តីនេះដោយទទួលស្គាល់ថា ពិតជាអក្សររបស់លោកតា ខ ថ មែន ដូចមានកំណត់ហេតុរបស់ចៅសង្កាត់ស្រះចកស្រាប់ ដោយខ្ញុំនជួបការលំបាក ខ្វះថវិកា ខ្ញុំនសុំឱ្យតុលាការសំរេចតាមបណ្តាំ ចុះថ្ងៃទី១១-១០-២០០១ របស់លោកតា ខ ថ ។

តាមបណ្តឹងតបចុះថ្ងៃទី០៨-០២-២០០២ លោក ខេព ស៊ុនថា តំណាងឱ្យលោកយាយ ព យ (ប្រពន្ធសព) ថា ខ្ញុំន និងបង១៦នាក់ទៀត មានឈ្មោះ ខ ណ ក, ខ ណ ល .

ទ . មឆ. ទ វង៉ៃ. ទ វង៉ៃ. ទ វង ដែលត្រូវជាកូនបង្កើតរបស់សពលោកតា ទ ថ និងជាទាយាទ សុំមប្តឹងបដិសេធលិខិតចែកមរតក ចុះថ្ងៃទី១១-១០-២០០១ ដែលភាគីដើមចោទប្តឹងទាមទារ ដោយហេតុថា លិខិតនេះ បានធ្វើឱ្យខូចខាតសិទ្ធិជាទាយាទក្នុងការទទួលមរតក និងធ្វើឱ្យបាត់នូវចំណែករបស់ពួកខ្លួន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៨"ក" ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងសុំ និងចម្លើយប្តឹងសុំរបស់លោកយាយ ព យ និងលោក ខ ស ថ ជាតំណាងទាយាទនៃសពលោក ទ ថ ដែលមានលោកមេធាវីជាត់ពៅ-សាង ចំណាយក្តីផង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹង និងចម្លើយតវ៉ារបស់អ្នកស្រីជ គ ហ ផ្ទេរសិទ្ធិឱ្យអ្នកស្រី ជ សជ មានមេធាវី ស ច ឧ និងក ស ថ ចំណាយក្តីផង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈនូវលិខិតបណ្តាំចែកមរតក ចុះថ្ងៃទី១១-១០-២០០១ របស់សពលោក ទ ថ តាមគោលការណ៍ច្បាប់ ។

៤-បង្គាប់ឱ្យអ្នកស្រី ជ គ ហ ចែកផ្ទះលេខ ៣៣AE1 ស្ថិតនៅផ្លូវលេខ ៣៣៦ ភូមិ១ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ពាក់កណ្តាលឱ្យមកទាយាទនៃសពលោក ទ ថ មានលោក ខ ស ថ ជាតំណាង មានមេធាវីជ ព ស ចំណាយក្តីផង ។ បើចែកមិនដាច់ស្រេចឱ្យលក់ឡាយឡុងយកប្រាក់ចែកជាពីរភាគស្មើ(មាត្រា ១៦៨ និងតទៅនៃច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ ) ។

៥-បង្គាប់ឱ្យឈ្មោះនាងជ ន អ និង លោក ល សវ និងគ្រួសារព្រមទាំងអ្នកដទៃទៀត ចុះចេញពីផ្ទះលេខ៣៣AE1 ភូមិ១ សង្កាត់ផ្សារដើមគរ ។

៦-ទុកជាមោឃៈនូវលិខិតលក់ដី ផ្ទេរកម្មសិទ្ធិចុះថ្ងៃទី១២-៤-២០០១ នូវដីទំហំ ៤៧៥០ម[២] តំលៃ ២៨៥០$ និងលិខិតលក់ដីផ្ទេរកម្មសិទ្ធិចុះថ្ងៃទី១៨-១០-២០០១ ទំហំ ៧៨៨៥ម[២] តំលៃ ៤.៧៣១$ ដែលស្ថិតនៅភូមិព្រៃជ្រាយក្របៅ២ ឃុំរកាអារ ស្រុកកងមាស ខេត្តកំពង់ចាមពីឈ្មោះអ្នកស្រី ជ គ ហ ឱ្យទៅឈ្មោះទ ច រ និងប្រពន្ធ ជ សជ (មាត្រា១៦៨ និង ១៧១ នៃច្បាប់ភូមិបាលថ្មី និងមាត្រា ៣៥ នៃច្បាប់កិច្ចសន្យាលេខ ៣៨) ។

៧-បង្គាប់ឱ្យអ្នកស្រី ជ គ ហ ផ្ទេរសិទ្ធិឱ្យអ្នកស្រី ជ សជ មានមេធាវី ស ច ឧ និងក ស ថ ចំណាយក្តីផង ចែកដីទំហំ ៤៧៥០ម[២] តម្លៃ ២.៨៥០$ ដែល

ទិញពីអ្នកស្រីឈ គ ស តាមលិខិតលក់ដីផ្ទេរកម្មសិទ្ធិកាន់កាប់ចុះថ្ងៃទី១៤-៤-២០០១ ពាក់កណ្ដាលឱ្យទៅទាយាទ នៃសពលោក ទ ថ និងដីទំហំ ៧៨៨៥ ម² ដែលទិញពីឈ្មោះឈ វ ប្រពន្ធឈ្មោះវ ស តំលៃ ៤.៧៣១៖ ដែលទិញតាមលិខិតលក់ដីផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី១២-៤-២០០១ ស្ថិតនៅភូមិជ្រោយក្របៅ២ ឃុំរការអារ ស្រុកកងមាស ខេត្តកំពង់ចាម ពាក់កណ្ដាលឱ្យទៅទាយាទនៃសពលោក ទ ថ ។ បើចែកគ្នា មិនដាច់ស្រេចឱ្យលក់ឡាយឡុងយកប្រាក់ចែកគ្នាស្មើ ចាប់ពីពេលដែលសាលក្រមនេះ ស្ថាពរ (មាត្រា១៦៨-១៧១ នៃច្បាប់ភូមិបាលថ្មី) ។

៨-ឱ្យអ្នកស្រី ជ គ ហ បង់ប្រាក់ប្រដាប់ក្ដី ២១.០០០៛ ដែលបានកាត់យកពីប្រាក់ប្រដាប់ក្ដីរបស់ទាយាទនៃសពលោក ទ ថ ក្នុងសំណុំរឿងលេខ ១៥៣៣ ចុះថ្ងៃទី១៩-១២-២០០១ និងសំណុំរឿងលេខ ១២២ ចុះថ្ងៃទី២៣-០១-២០០២ ចំនួន ១៤.០០០៛ និងសំណុំរឿងលេខ ១៥២៥/១៨-១២-២០០១ ចំនួន ៧.០០០៛ របស់អ្នកស្រីជ គ ហ ដាក់ថវិការដ្ឋ និងចំណាយផ្សេងៗរួចហើយ និងឱ្យអ្នកស្រី ជ គ ហ មានអ្នកស្រីជ សុផ ជាតំណាងបង់ពន្ធសមាមាត្រ១% នៃតម្លៃនៃរឿងក្ដីនេះ តែត្រូវឱ្យអ្នកឈ្នះក្ដីបង់ជាមុន ហើយតម្រូវឱ្យអ្នកស្រី ជ គ ហ សងប្រាក់ប្រដាប់ក្ដីចំនួន ១៤.០០០៛ និងប្រាក់ពន្ធសមាមាត្រនេះទៅទាយាទនៃសពលោកទេព ថុំ វិញ ។

៩-សាលក្រមនេះ សម្រេចសេចក្ដី និងប្រកាសជាសាធារណៈ ចំពោះមុខជ - សផ មេធាវីស ច ឌ លោក ទ ស ថា មេធាវីផ ព ស បើកផ្លូវប្ដឹងឧទ្ធរណ៍កំណត់ ០២ខែ គិតពីថ្ងៃសម្រេចសេចក្ដី ។

បានឃើញបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១១ខែមិថុនា ឆ្នាំ២០០៣ របស់លោក ស ច ឌ តំណាងឱ្យអ្នកស្រី ជ គ ហ មិនសុខចិត្តនឹងសាលក្រមលេខ១៨"ក" ចុះថ្ងៃទី១២-៥-២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១២៩"ឈ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-៦-២០០៣ របស់លោកមេធាវី ស ច ឌ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៨"ក" ចុះថ្ងៃទី១២-៥-២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលឈ្មោះ ព យ បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្សីង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០រៀល ។

កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះជិន គីមហោ សងប្រាក់ ១៣.០០០រនេះ ឱ្យទៅឈ្មោះ ព យ វិញ ។

៤-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៦-៨-២០០៣ ចំពោះមុខតំណាងចុងចម្លើយ និងមេធាវីចុងចម្លើយ កំបាំងមុខដើមចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥-៩-២០០៣ កំបាំងមុខគូក្តី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ១១៥ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៣ របស់លោក ស ច ឌ មេធាវីតំណាងក្តីឱ្យដើមចោទ ប្តឹងទាស់នឹងសាលដីការដ្ឋប្បវេណីលេខ១២៥"ឈ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី៣០-៩-២០០៣ របស់លោកមេធាវី ស ច ឌ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ១២៥"ឈ"ចុះថ្ងៃទី០៥-៩-២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី២៨-១១-២០០៣ ចំពោះមុខមេធាវីតំណាងគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥-១២-២០០៣ ចំពោះមុខមេធាវីតំណាងចុងចម្លើយ កំបាំងមុខមេធាវីតំណាងដើមចោទ តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោក ស ច ឌ ជាមេធាវីតំណាងឱ្យឈ្មោះជិ គ ហ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះជិ គ ហ

បានឃើញសារណាតបចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះ ព យ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ១៧៦ ឈ ចុះថ្ងៃទី០៥-១២-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ និងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់អ្នកស្រី ជិន គីមហោ នៅពេលសវនាការ ។

បានស្តាប់ចម្លើយរបស់លោក ទ ស ថ តំណាងឱ្យអ្នកស្រី ព យ ជាចុងបណ្តឹងសាទុក្ខ នៅពេលសវនាការថា : ចំពោះបណ្តាំមរតក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ចំពោះខ្លួន និងក្រុមគ្រួសារ ខ្លួនគិតថា មិនត្រឹមត្រូវទេ ហើយក្រុមគ្រួសារទាំងមូលមិនមានអ្នកណាម្នាក់បានដឹងទាល់តែសោះ ។ ចំពោះខ្លួន អ្នកស្រីជិ គ ហ មិនមែនជាប្រពន្ធរបស់ឪពុកខ្លួនទេ អ្នកស្រី ជិ គ ហ គាត់ទទួលប្រាក់ខែពីឪពុករបស់ខ្លួន ព្រោះថាជាកាតព្វកិច្ច ដូចជា ការបោកគក់អាចម៍នោម គឺជាភារកិច្ចរបស់អ្នកស្រីជ គ លា ព្រោះអ្នកស្រីជិ គ ហ ជាអ្នកបំរើរបស់ឪពុកខ្លួន។ ម្យ៉ាងទៀត អ្នកស្រី ជិ គ ហ គាត់បានទទួលចំណែកពាក់កណ្តាលហើយ នៅមានដីជាច្រើនកន្លែងទៀតដែលក្រុមគ្រួសារខ្លួនមិនទាន់បានរកឃើញ ។ ខ្លួនសុំតំកល់សាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសោម ច័ន្ទឪណា ជាមេធាវីការពារ និងតំណាងឱ្យអ្នកស្រីជិ គ ហ ជាម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសេចក្តីសន្និដ្ឋានថា :បើពិនិត្យលើបណ្តាំមរតកមួយច្បាប់ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ គឺជាសំណេរអក្សរផ្ទាល់ដៃរបស់ឈ្មោះទ . ថ ដែលជាម្ចាស់ទ្រព្យដោយបានសរសេរដោយផ្ទាល់ដៃ ក្នុងលិខិតបណ្តាំនេះ បានសរសេរយ៉ាងច្បាស់លាស់អំពីឈ្មោះរបស់ម្ចាស់ទ្រព្យ ហើយបានបញ្ជាក់ពីគោលបំណងដែលម្ចាស់បណ្តាំចង់ប្រគល់អោយ ។ លោកតា ទ ថ បានធ្វើការបែងចែកជាពីរចំណែកយ៉ាងច្បាស់លាស់ គឺទី១ លោកយាយ ព យ ទី២ គឺកូនក្តីខ្លួន តាមការបែងចែកលោកតា ទ ថ បានបញ្ជាក់ពីទីកន្លែង និងប្រវែងច្បាស់លាស់ ទី៣ ទៀតលិខិតបណ្តាំនេះ បានចុះថ្ងៃ ខែ ឆ្នាំ និងបានចុះហត្ថលេខា និងមានស្នាមមេដៃបញ្ជាក់យ៉ាងច្បាស់លាស់ ។ លិខិតបណ្តាំនេះ បានដាក់ក្នុងស្រោមត្រឹមត្រូវហើយ លោកតា ទ ថ បានប្រគល់ឱ្យចៅសង្កាត់ឈ្មោះ ឆ ធរ ដោយបានចុះលេខរដ្ឋបាលយ៉ាងត្រឹមត្រូវ ។ បើសិនជាពិនិត្យលើអត្ថបទច្បាប់វិញ បណ្តាំមរតក គឺជាសន្តតិកម្ម ដែលជាការផ្ទេរនូវបេតិកភ័ណ្ឌនៃបុគ្គលដែលស្លាប់ឱ្យជនម្នាក់ ឬច្រើននាក់ ដែលរស់នៅ ហៅថា សន្តតិជន ។ ការផ្ទេរនេះ គឺធ្វើទៅតាមឆន្ទៈរបស់ម្ចាស់ទ្រព្យ ។ ខ្លួនសំណូមពរ សូមឯកឧត្តមប្រធានតុលាការកំពូល លោកចៅក្រមមេត្តាផ្តល់ភាពយុត្តិធម៌ដល់កូនក្តីខ្លួន ដោយបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះសារជាថ្មីឡើងវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកផ . ព ស ជាមេធាវីការពារឱ្យចុងចំលើយ បានធ្វើសេចក្តីសន្និដ្ឋានថា ៖ ខ្ញុំសូមជំរាបថា អ្នកស្រីជ គ ហ មិនមែនជាប្រពន្ធរបស់សពលោកតា:ទ ថ ទេ គឺជាអ្នកបំរើក្នុងមួយខែ ១០០ដុល្លារអាមេរិក អ្នកស្រីជ គ ហ គាត់បំរើតបស្នងទៅលោកតា ទ ថ វិញ ព្រោះអ្នកស្រីជ គ ហ ទទួលប្រាក់ ១០០ដុល្លារអាមេរិក ក្នុងឋានៈអ្នកស្រីជ គ ហ បំរើមនុស្សចាស់ ។ ជាពិសេសបណ្តាំមរតកសរសេរនៅថ្ងៃទី១១ ខែតុលា ឆ្នាំ ២០០១ លោកតា:ទ ថ មានសតិអារម្មណ៍មិនហ្មឹងនរ ។ តាមគតិច្បាប់ការបែងចែកមរតកសាស្ត្រ សន្តតិជនជំបូងគេបង្អស់គឺកូន កូនមិនបានទទួលបែរជាអ្នកស្រីជ គ ហ បានទទួលពាក់កណ្តាលទៅវិញ គាត់មិនបែងចែកឱ្យទៅទាយាទ គឺជាមោឃភាពរបស់បណ្តាំមរតក។បណ្តាំមរតកសរសេរនៅក្នុងសតិវិលវល់ ។ ចំណែកផ្ទះលេខ៣៣AE, មានស្នាមមេដៃរបស់លោកតា ទ ថ និងដីពីរកន្លែងទៀត ក៏ដាក់ឈ្មោះលោកតា ទ ថ ទៀត បើលោកតា ទ ថ មិនចេញប្រាក់ទេ ហេតុអ្វីបានដាក់ឈ្មោះលោកតា ទ ថ ។ ខ្ញុំសូមសំណូមពរក្រុមប្រឹក្សាជំនុំជំរះ តម្កល់សាលដីកាសាលាឧទ្ធរណ៍លេខ១៧៦ "ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណាដើមចោទ ចម្លើយតំណាងចុងចម្លើយ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី.
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០០៤ របស់លោកមេធាវី ស ឲ ឪ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ៖ ការដែលមេធាវីដើមចោទ លើកឡើងនៅពេលសវនាការនេះថា មរតកសាសន៍ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ធ្វើឡើងតាមគន្លងច្បាប់ជាលិខិតបណ្តាំ ធ្វើក្រោយគេ ហើយជាប្រភេទលិខិតបណ្តាំឯកជន សរសេរដោយដៃម្ចាស់ទ្រព្យផ្ទាល់ដែលគប្បីមានអានុភាពតាមផ្លូវច្បាប់ ហើយថា បើទោះបីជាអ្នកស្រីជ គ ហ មិនមែនជាសហព័ទ្ធរបស់សពលោកតា ទ ថ ក៏អ្នកស្រីអាចទទួលអច្ច័យទានបានដែរ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា បច្ចុប្បន្នយើងពុំទាន់មានច្បាប់ស្តីពីមរតកទេ ហើយតាមលិខិត ចុះថ្ងៃទី១៤-០២-២០០១ របស់សព បាន

បញ្ជាក់ច្បាស់ថា បានប្រគល់ផ្ទះចែកកូន៧នាក់ ដោយមានតម្លៃតបស្នងផង ។ ម្យ៉ាងទៀត បណ្តាំចុះថ្ងៃទី១១-១០-២០០១ ធ្វើឡើងពេលដែលលោកតា ខ ថ មានជំងឺធ្ងន់ ហើយខ្លឹមសារនៃលិខិតបណ្តាំចុះថ្ងៃទី១១-១០-២០០១នេះ ពុំបានចែងថា ឱ្យលប់ចោលនូវបណ្តាំមុនៗទេ ។

- យល់ឃើញថា តុលាការក្រុងភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ពុំបានទទួលស្គាល់អ្នកស្រីជ ត ហ ជាសហព័ទ្ធស្របច្បាប់របស់សពលោកតា ខ ថ ឡើយ តែបែរជាទទួលស្គាល់ផ្ទះលេខ ៣៣ AE1 ស្ថិតនៅផ្សារដើមគរ និងដីនៅស្រុកកងមាស ខេត្តកំពង់ចាម ដោយសំអាងលើលិខិតផ្ទេរសិទ្ធិមានឈ្មោះអ្នកស្រី ជ ត ហ និងសពលោកតា ទ ថ ជាទ្រព្យរួមនោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា បុគ្គលពីរនាក់ដែលមិនមែនជាសហព័ទ្ធនឹងគ្នា មានសិទ្ធិលើវត្ថុតែមួយ មិនអាចមានន័យថា ជាទ្រព្យរួមឡើយ ។

- យល់ឃើញថា ដើមចោទ បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះ កំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ហើយ លើកលែងតែចំណុចទី៤,៥,៦,៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ដែលសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ ត្រូវទុកជាមោឃៈ ។

ដោយហេតុនេះ

វិនិច្ឆ័យសេចក្តីចំពោះមុខ ខ

កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោកមេធាវី ស ប ឱ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែចំណុចទី៤,៥,៦, និងទី៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១២៤ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ត្រង់ចំណុចទី៤,៥,៦ និងទី៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ។

៤-វិបអ្នសប្រាក់ប្រដាប់ក្តីដែលអ្នកស្រី ព យ បានបង់នៅតុលាការកំពូល ចំនួន

១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វីងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០រៀល

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង កាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៤ ។